# រឿង
# ទុំទាវ



# រឿងខ្ញុំអាច

ព្រះបទុមត្ថេរ សោម

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស.២៥១៤

# សេចក្ដីផ្ដើម

ដើម្បីរក្សាការពារកេរដំណែលវប្បធម៌ អក្សរសាស្ត្រជាតិ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ បានទទួលការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា អោយបោះពុម្ពរឿង **"ធុំទាវ"** ដែលជាស្នាដៃនិពន្ធរបស់ព្រះបទុមត្ថេរ **សោម** ឡើងវិញដើម្បីបំពេញសេចក្ដីត្រូវការរបស់ប្រិយមិត្តអ្នកអាន និងសិស្សានុសិស្ស ។ ក្នុងការបោះពុម្ពផ្សាយឡើងវិញនេះយើងខ្ញុំបានរក្សា អត្ថន័យ អត្ថរស ខ្លឹមសារ និងឃ្លោងឃ្លា នៅដដែលទាំងស្រុង ។

យើងខ្ញុំរីករាយនឹងរង់ចាំទទួលនូវការរិះគន់កែលំអ ក្នុងន័យស្ថាបនាពីសំណាក់ប្រិយមិត្តអ្នកអាន និងសិស្សានុសិស្ស ដើម្បីធ្វើអោយការបោះពុម្ពផ្សាយលើកក្រោយៗកាន់តែសុក្រឹតថែមទៀត ។


បោះពុម្ពផ្សាយឡើងវិញតាមច្បាប់ដើម
ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ
នៃក្រសួងអប់រំ យុវជន និងកីឡា

ព.ស ២៥៦២ គ.ស ២០១៨

# អារម្ភកថា

## របស់ពុទ្ធសាសនបណ្ឌិត្យ

រឿងទុំទាវនេះ មិនមែនជារឿងព្រេង និងមិនមែនជារឿងជាតកទេ គឺជារឿងមួយកើតឡើងពីការដកស្រង់នៃបញ្ហាជីវិតខ្មែរយើង ដែលធ្លាប់មានពិតប្រាកដក្នុងសម័យទីក្រុងលង្វែក ដូចមានសេចក្តីពិស្តារក្នុងផ្ទៃរឿងនេះជាភ័ស្តុតាងស្រាប់ ។

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានស្រាវជ្រាវរកឃើញនូវ រឿងទុំទាវនេះ មានពីរបែប គឺ :

១. ច្បាប់របស់លោកគ្រូព្រះបទុមត្ថេរព្រះនាម **សោម** ចៅអធិការវត្តកំព្រៅ ឃុំកំព្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង តែងក្នុងព.ស.២៤៥៨ គ.ស.១៩១៥ រជ្ជកាលព្រះបាទស៊ីសុវត្ថិ រៀបរៀងជាកាព្យពាក្យ៧ ពីដើមដល់ចប់ ។

២. ច្បាប់របស់លោកឧកញ៉ាវិបុលរាជសេនា នូ-កន តែងជាកាព្យពាក្យ៨ ក្នុង ព.ស.២៤៨៥ គ.ស.១៩៤២ រជ្ជកាលព្រះបាទនរោត្តមសីហនុ តែច្បាប់របស់លោក នូ-កន ប្រែឈ្មោះថា “**រឿងទាវឯក**” ទៅវិញ ព្រមទាំងបញ្ចូលគំនិតផ្ទាល់ខ្លួនជាច្រើនផង ។

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានចាត់ការចម្លងយករឿងទុំទាវចេញពីច្បាប់សាស្ត្រាស្លឹករឹត របស់លោកគ្រូព្រះបទុមត្ថេរព្រះនាម **សោម** ដែលមាននៅក្នុងបណ្ណាល័យរបស់វិជ្ជាឋាននេះ មកពិនិត្យផ្ទៀងផ្ទាត់ ហើយចាត់ការបោះពុម្ពឡើង ដើម្បីរក្សាស្នាដៃកវីនិពន្ធខ្មែរសម័យបុរាណទុកជាកេរ្តិ៍តទៅ កុំឲ្យបាត់បង់ និងដើម្បីឲ្យអ្នកអាន ៖

ក) បានស្គាល់ច្បាស់ថា ជាតិខ្មែរយើងមានកេរមតិកអក្សរសាស្ត្រច្រើនបែប ពិសេសជាបែបប្រលោមលោក ប៉ុន្តែសរសេរជាពាក្យកាព្យ ។

ខ) បានស្គាល់ព្រឹត្តិការណ៍អក្សរសាស្ត្រខ្មែរសម័យបុរាណ ។

គ) បានចេះចាំរឿងនិទាន និងពាក្យខ្មែរបុរាណច្រើន បែកប្រាជ្ញាអាចធ្វើការចរចា និងការនិពន្ធរបស់ខ្លួន ឲ្យមានសម្រស់ ។

ឃ) បានប្រៀបធៀបវោហារពាក្យពេចន៍សម័យចាស់ និងសម័យថ្មីហើយធ្វើសេចក្ដីនិពន្ធរបស់ខ្លួនឲ្យមានលម្អ ឲ្យត្រូវគ្រប់សម័យ ។

ការចម្លង និងការពិនិត្យផ្ទៀងផ្ទាត់នេះ បានទុករឿងនិងពាក្យកាព្យក្នុងផ្ទៃរឿងឲ្យនៅតាមច្បាប់ដើម ឥតកែប្រែ, គ្រាន់តែសម្រួលពាក្យខ្លះដែលយល់ច្បាស់ថា គក់ដោយការចម្លងតៗគ្នាជាច្រើនតំណមកហើយ ឲ្យត្រឹមត្រូវតាមច្បាប់ដើមវិញ និងគ្រាន់តែប្រើអក្សរតាមវចនានុក្រមខ្មែរសម័យបច្ចុប្បន្នប៉ុណ្ណោះ ។

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ សង្ឃឹមថា សៀវភៅរឿងទុំទាវនេះនឹងបានជាកម្លាំងមួយ អាចជួយពង្រីកអក្សរសាស្ត្រជាតិ ឲ្យមានវឌ្ឍនាការជាភិយ្យោភាពតទៅ ។

**លាច - ហ៊ាំបរាន**

នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

# អារម្ភបទ

# របស់រឿងទុំទាវ

## (បទពាក្យ៧)

១. នេះនឹងថ្លាថ្លែងតែងចរចា　លើកល្បងល្បែងល្បាយកាយកាព្យ
តាំងតែដំណាលកាលមុនជា　និទានយូរយារឃ្លាឃ្លាតឆ្ងាយ ។

មិនទៀងល្អៀងល្អក់តក់ឃ្លាឃ្លាត　សង្ខាតផ្ទៀងផ្ទាត់បទបរិយាយ
យើងកែជាថ្មីផែនដីអាយ　ស្រង់ស្រាយតទុកទៅមុខទៀត ។

ខិតខំសន្សំកែគិតជួស　ក្រែងហួសកិរៈស្ម័គ្រប្រឹងឆ្លៀត
កុំមានវោហារថាចោលម្សៀត　បែរបៀតត្រូវកាលដំណាលកើត ។

នាមានាមំតាំងជាថ្មី　ក្នុងដែនលោកិយគន់គិតគ្នេរ
គិតគ្នាន់ក្នុងអង្គផ្គង់កាយេ　គិតយកមកផ្ទេរផ្ទៀងទៀងទុក ។

៥. ឲ្យអស់មហាជនជាតិប្រុសស្រី　ក្នុងដែនលោកិយដឹងទៅមុខ
គ្រាន់ជាលំហែកែអផ្សុក　វិតក្កកាលណាក្លារីករាយ ។

យើងនឹងថ្លែងនាមតាមបញ្ហា　ដើមថាតាមឈ្មោះចំពោះងាយ
តួ ស រាប់រៀបធៀបនិយាយ　ទើបទាយប្រកបរាប់រៀងទៅ ។

ទាញយារ ស សព្ទប្រកប ម　បាំងឈើលើ ស ទើបបានត្រូវ
ឈ្មោះដើមដូចនឹងពីម៉ែឪ　ឥឡូវនាមបែកចែកដោយគុណ ។

ចូលមកសំណាក់សំណាងមាន　ព្រះគុណឲ្យទានទុកជាទុន
ជាទីគ្រាន់បានប្រាណរស់ជន្ម　ដោយបុណ្យវ័តន៍ត្រៃសព្វថ្ងៃពឹង ។

ចូលមកសំណាក់បួសគង់នៅ ទីវត្តកំព្រៅស្មោះសរភ្លឹង
កាត់សង្សារវដ្តវាសវាងនឹង នឿយព្រួយព្រោះប្រឹងប្រាថ្នាផល ។

១០. នាមនោះចំពោះឧបជ្ឈាចារ្យ ដូចផ្កាក្រអូបផុំប្រាសខ្យល់
ព្រះបទុមត្ថេរបែរបានផល កំណត់កុសលសាងសីលទាន ។

ស្តេចសង្ឃមេត្តាត្រាប្រណី សម្រេចលើដីលោកិយគ្មាន
នាយកខាងសង្ឃក្នុងក្រុងមាន សង្ឃផងស្រែកឃ្លានមានបញ្ញា ។

ចូលទៅដែនក្រុងផ្ទង់ស្មោះស្ម័គ្រ ប្រាថ្នាពឹងពាក់តាមប្រាថ្នា
រៀនសូត្របាលីអត្ថបញ្ហា ចិន្តាផ្គាប់ផ្គុនបុណ្យបារមី ។

ទ្រង់ប្រោសប្រទានឲ្យមានឈ្មោះ ចំពោះជាបានដូចសេចក្តី
ប្រាថ្នាការងារឬគិតអ្វី ប្រណីប្រោសប្រាណប្រទានមក ។

តាំងព្រះឧបជ្ឈាយ៍ងារព្រះស- ង្ឃរៈវក្សគង់នឹងពឹងពន្លក
ពន្លឺលោកិយនិស្ស័យជ្រក ចូលមកកាលណាបោះត្រាឲ្យ ។

១៥. កាន់ដើររកស៊ីទៅឆ្ងាយជិត មិនមានភ័យភិតនឹងថីបោយ
ប្រកាន់ផែកនេរទីដីដោយ គ្មានកាតថ្ងោះផ្ដោយឲ្យលើកដី ។

យើងលើកកាព្យកាលពុទ្ធសាសនា ពីរពាន់វស្សាផ្សំសិរី
បួនរយហាសិបប្លាយប្រាំបី ថ្ងៃចន្ទដប់បួនរាប់នូវខែ ។

កន្លងបានបួនជួនភទ្របទ មួយកើតកំណត់វស្សនេ្ត
ឆ្នាំថោះសប្តស័កមិនហួរហែ សល់ទៅទៀតឯមុខមិនថ្លែង ។

ទុកឲ្យអ្នកក្រោយទោះលោកណា មែនមានប្រាជ្ញាចេះតុបតែង
គិតចុះសល់ទុកមិនសម្តែង ចេះអ្វីតែឯងក្រែងគេថា ។

ចារចែងសម្តែងរិះរៀបរាប់ ទុកជាសណ្តាប់ក្នុងសាសនា
សូមលើកករផ្ទង់នមស្ការ ដល់ព្រះសម្មាសម្ពុទ្ធស្ស ។

២០. នូវគុណព្រះធម៌ធំទូលាយ ប្រាំបីម៉ឺនប្លាយបួនពាន់ខ្ពស់
ជ្រៅច្រើនក្រវើនត្រាច់ប្រោសប្រោះ សត្វមនុស្សដាក់ដល់ថ្កល់និញ្វន ។

នូវគុណព្រះសង្ឃអង្គសាវ័ក លោកភ័យផ្អើលភ្ញាក់មិនស្រេកឃ្លាន[១]
ចាកសង្សារវដ្តប្រាកដមាន ទុកដាក់ផ្ញើទានមានសង្ឃស- ។

ឋិតិឋិតធួនថែក្នុងសាសនា ប្រៀបដូចភេត្រារិះរៀបចំ
រៀនគន្ថធុរៈជាក់ឧត្តម ប្រឹងខំក្រែងខុសផ្លោះវិន័យ ។

សូមគុណព្រះឧបជ្ឈាយាចារ្យ មាតាបិតានូវព្រះពៃ-
ស្រពស្រង់រួចរស់រូបទីទៃ ឥតអ្វីប្រៀបផ្ទឹមត្រឹមស្មើបាន ។

នូវគុណព្រះកម្មវាចា អនុស្សាវនាបង្ហើតប្រាណ
គុណព្រះវិន័យព្រះកម្មដ្ឋាន ជាត់ច្រានផុតទុក្ខសុខសួគ៌ា ។

២៥. គុណព្រះអគ្គីវារីឫទ្ធិ ព្រះអាទិត្យធរណីព្រះចន្ទ្រា
ព្រះពាយតារាទេពទេវា ឋិតគុកគុហាសោឡសស្ថាន ។

ព្រះកាលព្រះយមរាជា ចតុលោកបាលឋិតសម្រាន្ត
គង់ចាតុម្មហារាជស្មោះស្មាន កំសាន្តគង់នៅតាវត្តិង្សា ។

ព្រះឥន្ទ្រាទ្រង់គង់សោយរាជ្យ រិទ្ធីអំណាចមានចេស្តា
ទាំងសោឡសសួគ៌ទេវតា ព្រះវិស្សុកម្មាប្រតិស្ឋាន ។

សូមសុំតេជះលោកទាំងគ្រប់ ជាម្លប់គ្រាន់ជ្រកកោនសម្រាន្ត
សម្រេចជៀសទុក្ខសុខក្នុងប្រាណ ឲ្យបានដូចចិត្តគិតប្រាថ្នា ។

ទោះទាំងរោគាព្យាធិអ្វី កុំបីឲ្យមានក្នុងកាយា
សូមជ្រះស្រឡះអង្គរូបា ភ្លឺថ្លាត្រចង់ដូចវង់ខែ ។

---

១. គួរថា លោកមិនផ្អើលភ្ញាក់ភ័យស្រេកឃ្លាន ។


T. CHEAT.

# រឿងទុំទាវ

(បទពាក្យ៧)

៣០. ថ្លាថ្លែងសម្ដែងដើមឈ្មោះទុំ　　នៅខេត្តបាភ្នំដែនដីស្រែ
កើតកបទំនៀមមានឪម៉ែ　　ប៉ុន្តែហេតុត្បិតឥតសម្ដែង ។
កើតឡើងលុះធំល្មមប្រមាណ　　ឆ្នាំច្រើនសោតបានម្ដាយតុបតែង
យកទៅឲ្យរៀនចោលគ្រឿងល្បែង　　ស្វះស្វែងនៅវត្តវិហារធំ ។
លោកគ្រូទទួលស្រួលព្រះទ័យ　　ប្រិតប្រៀនទុំវៃខាងអាគម
អាចគាប់ដោយប្រាជ្ញប្រឹងជញ្ជុំ　　ខិតខំចង់បួសផ្នួសសាមណេរ ។
សំណាក់ឋិតថេរចំណោរលង់　　មាននេនមួយអង្គគ្រាន់បើដែរ
នាមឈ្មោះនេនពេជ្រលេចក្រសែ　　នេនទាំងពីរកែតែគោកលក់ ។
៣៥. ទុំមានវោហារប្រាជ្ញាផ្សេង　　មានទាំងសម្លេងរូបខ្ចីល្វក់
ល្អទ្រង់អង្គកាយសាយទឹកមុខ　　រួចទុកនេនពេជ្រស្រេចជាប្អូន ។
នេនពេជ្រចេះស្រេចខាងផ្លុំប៉ី　　ឈ្លាសវៃប្រសប់ភ្លេងមាំមួន
អ្នកនេនពីរពិតគិតគុំកួន　　ចំណោះក្នុងខ្លួនប្រហែលគ្នា ។
ធ្វើគោកធ្វើទុកលក់ដាច់ខ្លះ　　នៅផ្ទះទៀបវត្តជាមីងមា
លុះដល់រដូវត្រូវរងា　　ព្រឹប្រុងអង្គាជាទុក្ខព្រួយ ។
អកុសលដល់គ្របសង្កត់កាយ　　ជួបនេនពេជ្រវាយដូចខ្លួនមួយ
ថានេនពេជ្រអើយចូរគាត់ជួយ　　យើងលក់គោកមួយៗយូរហើយ ។
វាគ្មានចំណេញជំនួញទាល់　　កុំឆ្ងល់ដូចពាក្យបុរាណឆ្លើយ
ថានៅរៀងអាយជិតបង្កើយ　　លំហែលំហើយតែប្អូនស្រី ។

បុរាណលោកថាមិនខុសសោះ ខ្លួនយើងកម្លោះក្នុងលោកិយ
បួសស៊ីបាយបាត្រមិនចេះអ្វី នៅថ្ងៃចោលម្សៀតឆ្លៀតដើរឆ្ងាយ ។

៤០. គិតស្រេចព្រមព្រៀងមៀងមើលគ្រប់ ខំទប់មិនឈ្នះរៀបខ្វល់ខ្វាយ
ទៀនធូបបានស្រាប់ប្រញាប់កាយ ឡើងដាក់អង្គថ្វាយបង្គំគាល ។

លោកគ្រូពុំយូរមានពុទ្ធដីកា ថានេនទៅណាដូចពីភាល់
នេនទូលពុទ្ធដីកាថាទាំងទាល់ ក្រាបទូលកុំឆ្ងល់សូមមេត្តា ។

ព្រោះយើងទាំងសងប៉ងបង្គំ លាព្រះគុណធំខ្ញុំករុណា
ទាំងពីរនាក់នឹងចរយាត្រា ប្រោសប្រាណមានការទៅស្រុកឆ្ងាយ ។

នៅវត្តប្រាកដជាអផ្សុក ជាទុក្ខគ្មានល្ហែក្នុងអង្គកាយ
ខ្ជិលណាស់ព្រះគុណមិនសប្បាយ ក្រហល់ក្រហាយខ្វល់ចង់ដើរ ។

ដោយសារត្រូវខ្យល់ដល់រដូវ លាព្រះគុណទៅក្រែងប្រសើរ
ប្រសិនដឹកតោកយកទៅផ្ញើ គ្រាន់បើនៅអាយចាយមិនដាច់ ។

៤៥. លោកគ្រូពុំយូរមានពុទ្ធដីកា ថាអើតាមអាប្រាថ្នាត្រាច់
ថាលាអញទៅលក់ដូរស្រេច ចាំបាច់សាស័ព្ទប្រាប់អញថ្វី ។

ទៅចុះគាប់ខុសប្រយ័ត្នណា៎ កុំរ៉ុយអីអាឃើញរូបស្រី
បត់បួចឡូកលេងមិនគប្បី ដំនៀលអប្រិយដល់មកគ្រូ ។

គេរឺខ្មាសនិន្ទានាលោកិយ ខុសពីវិន័យព្រះសព្វញ្ញូ
បើទៅលក់អស់កុំនៅយូរ គិតគួរថ្លៃថោកមកវិញឆាប់ ។

នេនទាំងពីរកាយថ្វាយបង្គំ លាលោកគ្រូធំចុះប្រញាប់
ប្រញាយប្រញីកនឹកឃើញស្រាប់ យកតោករៀបផ្កាប់ផ្គងបម្រុង ។

ផ្ទុកក្នុងរទេះរិះរកបាយ បានខ្ជប់ខ្វល់ខ្វាយរកការុង
បង្ការច្រកស្រូវក្រែងផ្លូវផុង ត្បិតក្នុងរដូវត្រូវភ្លៀងផ្គរ ។

៥០. នេនរៀបបម្រុងការុងបាយ បង្ការទៅឆ្ងាយផ្លូវត្រាច់ចរ
ប្រឹងអូសរទេះមកបញ្ឈរ ដឹកគោនឹកបរចរចេញទៅ ។
ពារពេលប្រហែលម៉ោងប្រាំបី សូរ្យសែងរង្សីភ្លឺសន្ធៅ
សន្ធោពីទិសបូព៌ច្រាលផ្តៅ បរដល់វាលនៅក្នុងខេត្តខណ្ឌ ។
មើលមានទឹកស្មៅខាងផ្លូវស្រាប់ ប្រញាប់ដោះគោចងនេនឆាន់
គោស៊ីស្មៅស្រេចផឹករន្ទាន់ ប្រកាន់ចូលនឹមទឹមបរទៅ ។
ដល់ស្រុកភូមិស្ថានបានលក់គោក បាសកទិញយកខ្លះសល់នៅ
សល់ខានប៉ុន្មានលក់តាមផ្លូវ ខំបរដល់ទៅខេត្តត្បូងឃ្មុំ ។
៥៥. ប្រទល់ដែនដល់ខេត្តទទឹង- ថ្ងៃតែងឈប់នឹងដ្បិតជនជុំ
ចង់ទិញគោកនេនខ្លះគន់គុំ សម្លឹងនេនទុំសមរូបឆោម ។
ខ្លះថាអើម្ល៉េះប្រសិនណា បានអញប្រវាឱបប្រលោម
ប្រឡែងតាមចិត្តគិតចង់ចោម មៀងមើលព្រីព្រមប្រឈមឈប់ ។
បៀតបែរស្នេហ៍ស្និទ្ធជិតអណ្តូង ជ្រួលច្រូងស្រើបស្រួលទីទួលម្លប់
ឈ្មោះពោធិ៍ជើងខាលត្រកាលគ្រប់ មើលសព្វស្រីប្រុសស្រុះស្រើបស្រាល ។
នេនដាក់ស្នាក់ស្និទ្ធជិតភូមិស្ថាន ប្រមាណបាសកជួយឃើផ្គាល
លក់ដាច់ដោយយល់ឃើញត្រអាល បណ្តាលបណ្តោយឲ្យយូរនៅ ។
ឈប់រង់អង់ខានបានច្រើនថ្ងៃ អាល័យអ្នកនេនមិនឲ្យទៅ
ចាកទីដែននោះព្រោះយល់ត្រូវ រដូវដល់ដែលប្រហែលថា ។
៦០. ប្រមាណដោយគិតគំនិតអ្នក ដែលឲ្យនេនស្នាក់ប៉ងប្រាថ្នា
ប្រយោជន៍ឲ្យនេនមើលសាស្ត្រា នេនមានប្រាជ្ញាចេះលេបខាយ ។
សម្លេងផ្អែមល្ហែមស្រួយពីរោះ ស្តាប់ទាំងកម្លោះចាស់មេម៉ាយ
ក្រមុំត្បូងឃ្មុំរត់ប្រញាយ ប្រញាប់ចង់ស្តាប់ស័ព្ទភាសា ។

កាលនោះនាងនោជាភីលៀង	នាងទាវបានឈៀងចរយាត្រា
កាន់ក្អមថ្មិតថ្មមនឹកប្រាថ្នា	ចូលទៅស្តាប់ការណ៍ដឹងសេចក្តី ។
ឈរទ្រឹងរឹងខ្លួនពួនចាំស្តាប់	ពីរោះហាក់ផ្តាប់មុខដល់ដី
ស្រងាកស្រងោចស្រងល់ស្រី	នោនឹកបេតីមិនស្តីសោះ ។
ចាំទៅដល់ផ្ទះប្រាប់ទាវគ្រប់	ទាវនៅក្នុងម្លប់សមស្រណោះ
នាងជាម្តាយទាវមានរបស់	កូនស្រស់រូបស្រេចដាច់ស្រីផង ។

៦៥. នានឹកក្នុងចិត្តគិតស្រេចស្រាប់	ដងទឹកទូលឆាប់ដើរផ្អៀងផ្អង
ដល់ផ្ទះនោឡើងទៅជាម្តង	សាសងរ៉ាយរាប់ប្រាប់ទៅថា ។
ទាវអើយទាវស្រីសេចក្តីនេះ	លោកនេននោះចេះមើលសាស្ត្រា
សម្លេងស្រួយស្រាប់ស្តាប់ភាសា	ដូចសត្វសារិកាពិសាចេក[១] ។
ទាវទៅនៅយូរគួរពិភាល់	មិនសល់គេប្រាប់ជាក់ហើយត្រេក
ត្រង់ណោះកុំឆ្ងល់បានដឹងពេក	តម្រេកចង់ស្តាប់ហ៊ានប្រាប់ម្តាយ ។
ចេញមកក្រៅក្រាបទៀបមាតា	ទាវថាម៉ែអើយអើម៉ែអាយ
អាណិតកូនម្តងទើបកូនរាយ	បាសកយើងអាយឆ្ងាយវត្តឋាន ។
មិនដែលស្គាល់សោះកម្លោះលោក	មិនដឹងថាមកពីថ្កាន
ឮនោគេថាពីរអង្គប្រាណ	សម្រាន្តកាយយក់លក់តោកលេង ។
ថាមកពីឆ្ងាយដល់អាយស្នាក់	ផ្ទះគេមួយជាក់ជានេនក្មេង
ពីរោះមែនដឹងផ្សឹងតាមឈ្វេង	នោថាសម្លេងមានគ្រាន់បើ ។

៧០. នាងជាម្តាយទាវផ្ទៀងស្តែងស្តាប់	ឮទាវកូនប្រាប់ឆ្លើយថាអើ
លូកដៃយកស្បៃដណ្តប់ដើរ	ញ៉ាំងញ៉ើផ្អៀងឈ្មងទំនងចាស់ ។

---

១. បោះលើកមុនថា“សត្វសារិកាឬល្វាចេក”តែនេះ កែតម្រូវតាមសាស្ត្រាដើមវិញ ។

បានដល់យល់មនុស្សស្រុះជៀវនោ
ម្តាយទាវថាឱមែនជាក់ច្បាស់
ឡើងទៅឃើញនេនតូចល្អណាស់
ផ្ទឹហត្ថសំពះក្រាបបង្គំ ។

ហើយទូលសួរថាករុណាម្ចាស់
និមន្តទៅផ្ទះសត្វជាខ្ញុំ
ឆាន់ស្លាបានម្តងហើយយើងសុំ
និមន្តលោកកុំខានណាម្ចាស់ ។

នេនទុំបានស្តាប់ស័ព្ទញោមមន្ត
ភ្នែកតែងគយគន់មើលឲ្យច្បាស់
ឆ្លើយថាបើមន្តញោមរហ័ស
ទៅផ្ទះរៀបរួចអាចក្តីទៅ ។

ម្តាយទាវវិលដល់ផ្ទះម្ចីម្ចា
លាតលាកន្ទេលក្រាលដោយនូវ
យកកែបកល់កើយខ្នើយពូថៅ
សខ្មៅគ្រីបប៉ាក់ដាក់ដង្ហែ ។

៧៥. នេនពេជ្រនេនទុំជំនុំព្រម
នេនពេជ្រថាល្មមឆាន់ទៅដែរ
ទុំថាចុះគោនៅក្នុងស្រែ
ដាច់ខ្សែស៊ីស្រូវត្រូវសងគេ ។

នេនពេជ្រគេចថាអើទៅចុះ
បើខុសឆាន់រួចខ្លួនទទេ
ក្រែងវិលទៅវត្តលោកគ្រូជេរ
ថាឯងវេះវេរដើរចង់ស្រី ។

កាត់ដើរគ្រប់ខេត្តហេតុទាំងម្ល៉េះ
អាងមានតម្រិះក្នុងលោកិយ
ហៅឆាន់រំលឹកមិនគប្បី
ទំនៀមចាស់ស្តីមិនចេះខុស ។

ថាដើរមានប្អូនខ្លួនជាសង្ឃ
ទើបបានត្រូវត្រង់ឥតមានមោះ
បើដើរទៅក្តីបាសកសោះ
គេរកោះថ្លោះឆ្លោយឲ្យមានប្រាំ ។

នេះទៅម្នាក់ឯងក្រែងគេថា
បាសកសិកាគេមកផ្តាំ
ឲ្យមន្តទៅលេងឆាន់ស្លាថ្នាំ
មន្តចុះឆាន់ចាំគោម្នាក់ឯង ។

៨០. នេនទុំងឿងងំជញ្ជុំគិត
ព្រួយចិត្តត្បិតពេជ្រលេចសម្តែង
យកសព្ទទំនៀមមកថ្លាថ្លែង
រួចទុំតុបតែងស្បង់សង្ឃាដី ។

សឹងព្រៃសូត្រសុទ្ធសាច់ល្អស្អាត
ឈាំងកែម៉ូតម៉ាតពណ៌លឿងខ្ចី
សម្បុរស្រៀបស្រស់ឆ្អុះរស្មី
នៅថ្មីភ្លឺទែងកន្សែងស ។



ស្លៀកពាក់គ្រលុំធុំរមៀត យកផ្លិតសិកសៀតរូបឆោមល្អ
យាមឈ្មងទំនងលើកបង់ក ស្រេចចរចាកទីលីលាទៅ ។

ដល់ផ្ទះម្ដាយទាវចុះមកឆាប់ ដល់ជីឱនក្រាបប្រណម្យនៅ
ថាទានលោកម្ចាស់និមន្តត្រូវ ឥឡូវឈប់រង់ស្រង់ទឹកអាង ។

ទឹកអប់ត្រឡប់ធុំគន្ធរស សាប៊ូជូតដុសជ្រះសន្លាង
ក្រអូបសាប៊ូក្លិនដោយយ៉ាង ដោយយល់សំណាងសាមណោរនេន ។

ស្រង់ស្រេចផ្លាស់ស្បង់អង្ស័កពាក់ ឡើងផ្ទះដល់ដាក់អង្គពន់ពេន
លើកបាទបត់បែបកែបប្រគេន ប្រគល់លោកនេនប្រគេនស្លា ។

ប្រាកដចេះបទយ៉ាងម្ដេចខ្លះ កុំអន់អៀនខ្មាសសូមមេត្តា
និមន្តស្នូត្រឬមើលសាស្ត្រា យើងខ្ញុំប្រាថ្នាចង់ស្ដាប់ម្ដង ។

ឲ្យអស់ចំណោះចេះយ៉ាងណា តាមលោកមេត្តាស្រាយចំណង
ចំណាំម្ដេចខ្លះខ្ញុំប៉ុនប៉ង សន្ដានមកផងស្ដាប់រាល់គ្នា ។

រួចនេនស្ដាប់ជាក់ភ្ញាក់ព្រើតប្រឹង ភ្នែកគន់សម្លឹងទៅមាត់ទ្វារ
យល់ទាវឈរស្ទុះបដើរវេរា ស្ទុះស្ទាចូលក្នុងស្លុងចេញក្រៅ ។

៩០. អើតអើមដកកច្រហមាត់ ចង់ចេញប្រាកដគ្មានគេហៅ
ស្លុតស្លឹងម្នាក់ឯងដោយក្មេងសាវ ស្ទុះចូលយកអាវពាក់ពានា ។

នេនយល់ដូច្នោះក្នុងពោះព្រួច កាន់ក្ដួចកើតទុក្ខចុកឱរា
ឱរូបហ្នឹងហើយទាវពុំងា មិនងាកបំពារបំពេរន ។

តាំងថានមោតស្សបីបទ ពីរោះប្រាកដខ្លះក្រាបឱន
ស្នូត្រក័ណ្ឌមទ្រីកាលជ្រកកោន លំទោនលាព្រះលះចូលព្រៃ ។

ត្រាច់កាត់ក្នុងដងដែនបព្វតា រកបេះផលាពនាល័យ
មានរុក្ខទេវាផងដទៃ បំភ័យស្លុតស្លន់ភ័ន្តភាំងភិត ។

ដល់ដួលដាក់អង្គទ្រង់វិយោគ ទួញយំខឹនឈ្ងោកគួរអាណិត
អនាថត្រជាក់ហើយល្ងចឥត លោកណាជួយគិតជីវិតខ្ញុំ ។
ប្រាសព្រះព្រោះលះមកឆ្ងាយហើយ អម្ចាស់ថ្លៃអើយម៉្លេះក្រាលក្រំ
ព្រួយប្រឹងគិតកូនខានចង្រ្កម កូនយំទាររកយកអ្វីឲ្យ ។
៩៥. ស្រែកឃ្លានគ្មានសល់ផលផ្លែឈើ ម៉្លេះហើយទ្រង់ដើរក៏ដង្ហោយ
ហៅខ្ញុំពីព្រឹកនឹកខានសោយ សមដោយតាមកូនសួន្យស្ងប់ស្ងាត់ ។
នេនស្នូត្រប្រូតកាត់កែទំនង រម្លងយកខាងរឿងបរមត្ថ
ឈប់ឆាន់ស្លាម្លួយយូរតិចក្តាត់ បាសកប្រតិបត្តិសត្វញ្ញាតិញោម ។
បាសកកាលនោះស្រុះស្រួលស្រេច ខ្លះស្តាប់គាំងដាច់ទាំងជុះនោម
ពីរោះស្រណោះផ្អើលជៀវចោម ប្រឈមឈរឈប់ម្លប់មុខផ្ទះ ។
ហើយថាមេត្តាប្រាយប្រោសសត្វ ខ្លះខិតចូលជិតគិតចង់ឈ្នះ
លើកហត្ថទាំងសងផ្គងសំពះ សូមមន្តអម្ចាស់ច្បាស់រឿងអ្វី ។
មេត្តាកុំលាក់ជាក់ជាចេះ ទុំមានតម្រិះត្បិតឃើញស្រី
ទាវយកផាហ៊ុមព្រែកម្ទី ជន្លាប់ទិញថ្មីបារីស្លា ។
១០០. បត់បែរតែងស្រាប់ចាប់លើកផ្គង បិទទូលបីដងប៉ងប្រាថ្នា
ថាសូមតេជះព្រះករុណា សូមដូចសច្ចាចិន្តាផ្សង ។
សូមជួយឲ្យជួបរួបរួមកាយ កុំឲ្យឃ្លាតឆ្ងាយដូចបំណង
ជាតិនេះជាតិណាសត្យាប៉ង បានដូចបំណងចងមេត្រី ។
ទាវរៀបផ្គងស្រេចចាប់កាន់ដើរ ដល់មកជិតស្មើនឹងនោស្រី
ថាហាកនោបងចូរប្រណី ប្រគេនបារីស្លាផាហ៊ុម ។
ឲ្យខ្ញុំជាគុណជាបុណ្យខ្លះ កុំឲ្យខ្ញុំខ្វះទ្រព្យចូលជុំ
ជាតិនេះជាតិក្រោយឲ្យមានធំ កុំបីឲ្យខ្ញុំក្រតទៅ ។

នែនទុំទទួលគ្រឿងបរិក្ខារ ស្រេចស្រាយយកស្លានាន់រួចនៅ
ឈប់អង់បន្តិចសែកប្រេងម្សៅ រំលឹកដល់ទៅមន្តសារិកា ។

១០៥. លិនថោងករវិករំលឹករក សម្តលីហៅយកមណីចិន្តា
លូកយកប្រទាលឆាន់នឹងស្លា ស្លូត្រសាគ្រប់សព្វចប់ជាម្តង ។

រួចនែនទុំស្ទូត្រស្រូតបង្ហើយ ស្លូត្រហើយនឹករករឿងប្អូនបង
ឃើញត្រង់ព្រាហ្មណោចោរកន្លង នាំកុមារចងនឹងវល្លិវ៉ៃ ។

បណ្តើរដឹកទៅគួរអាណិត ទួញយំគន់គិតថាឱថ្ងៃ
នេះហើយព្រាហ្មណោចោរចង្រៃ វាយក្ស័យហើយណាំមាតាខ្ញុំ ។

ចរចេញចាកចេរពីសាលា អ្នកម្តាយប្រាថ្នារកសន្សំ
បេះផ្លែឈើបានអ្នកបារម្ភ ខិតខំព្រោះកូនស្ងួនមកអាយ ។

កុមារតូចៗដូចនែនទុំ ស្ទូត្របានផាហ៊ុមរុំមិនស្រាយ
យកជាបន្ទាល់ទាវមិនស្តាយ ស្ទូត្រចប់រាប់វាយរួចភត្តា ។

១១០. បាសកសំពះខ្លះអ្នួតទុំ លំនៅត្បូងឃុំខ្ញុំរក្សា
សុំជាកូនធម៌ខ្ញុំករុណា មេត្តាអធ្យោគលោកប្រណី ។

នែនស្ទូត្រស្លូត្រចប់ត្រឡប់សួរ ញោមអើយគាប់គួរត្រូវអាចក្តី
លាអស់ញាតិញោមទាំងប្រុសស្រី ត្បិតថ្ងៃទន់ទាបរយាបយប់[១] ។

ត្បិតទុកនែនពេជ្រនៅម្នាក់ឯង ចំបែងចិត្តចែកបែកទាំងគ្រប់
ខ្លាចចិត្តគេដែរថែមិនឈប់ គិតសព្វគេសោតនែនដូចគ្នា ។

នែនទុំនាំហេតុនិយាយប្រាប់ បាសកផងស្តាប់ហើយលាកលា
ចរចុះដើរដល់នែនពេជ្រជា ប្អូនអើយម្ចីម្នាជាដូចដើម ។

---

១. រយាប=ទាបទៅ, ជិតដល់ : រយាបយប់=ទៀបនឹងយប់ ។

ចូលជិតទុំគិតនិយាយលេង ឲ្យពេជ្របានឈ្វេងអួតទាវឆ្នើម
ថានេនពេជ្រប្អូនប្រុសថ្លៃថ្លើម ទុំផ្តើមប្តេជ្ញាសិកាទាវ ។
១១៥. ថាល្អណាស់ណាំប្អូនសំឡាញ់ ឥឡូវបងកាញ់គិតចង់នាវ
ស្តីគេទៅសួរគួរព្រាងព្រាវ ឲ្យដឹងសុំជាវអ្វីបញ្ចាំ ។
ចិត្តទាវឲ្យនឹងទ្រឹងឈប់រង់ យើងទៅហើយគង់តែដល់ឆ្នាំ
លាលោកគ្រូសឹកត្បិតយើងផ្តាំ ទាវទុកចំណាំនឹងវិលមក ។
នេនទាំងពីរពិតគិតស្រេចហើយ ពុំលង់យូរឡើយនេនទុំភ្នក
ប្រាប់ថាពេជ្រប្អូនល្មមយើងរក ប្រមូលស្រូវយកច្រកការុង ។
លើកដាក់រទេះកុំស្លេះឈប់ ល្មមវិលត្រឡប់ត្បិតនៅសុង
នៅសុខស្រុកអាយឆ្ងាយអន្លង់ យើងកុំបង្អង់រង់មិនបាន ។
នេនទាំងពីរពិតគិតវិលវិញ ព្រឹកព្រាងចរចេញមិនមានខាន
រួចលាញាតិញោមទាំងប៉ុន្មាន ចរថ្កានដល់ដានដងមាគ៌ា ។
១២០. បរកាត់ត្រូវត្រង់បង្អង់ឈប់ នេនទុំជ្រុលជ្រប់ជ្រកវេទនា
គ្រៀមក្រំខំទប់សញ្ចប់ជា ទុក្ខណាស់ភ្នកភ្ញារកស្រាយ ។
បង្វេចវេចរុំធុំក្លិនផ្កា ហត្ថាទាញយកមកជិតកាយ
រួចយល់ដើមឈើផងទាំងឡាយ រាប់រាយរៀបរាប់ផ្តាប់តម្រូវ ។
ឱដើមទន្លាប់ទន្លាមក ដើមធ្លកទុំសោកសព្វតាមផ្លូវ
ដើមថ្វាន់បានថ្វបដល់ឥឡូវ ប្រាសទាវឲ្យនៅតែម្នាក់ឯង ។
ឱក្លិនផ្កាអ៊ីអឺដល់ម្លេះ ក្រអូបផ្កាម្លិះឬផ្កាស្លែង
អប់នៅផាហ៊ុមទាវតុបតែង ដាក់នៅកន្សែងចំបែងបង់ ។
ចាកចោលទាវស្រីសេចក្តីទាល់ មិនដែលឃើញស្គាល់ទុំជាសង្ឃ
ហ៊ានកាត់ចិត្តជ្រៀតឆ្លៀតតម្រង់ បួជាផ្ចិតផ្ចង់ភ្ជាប់ប្រាថ្នា ។

១២៥. ដន្លាប់ក្រមួនធូនពាសពេញ ទាវអើយទុក្ខអញម្ញេញខ្លោចផ្សា
កើតទុក្ខទៀតថ្មីបារីស្លា ទាវស្រីស្នេហាប្រគេនមក ។

ឥឡូវយល់សត្វច្រវាត់ទំ ឈ្មោលញីយាសយំហើយហើររក
ចឹកចាប់ផលាប្រាថ្នាយក ដល់កូនចូលជ្រកក្នុងរូងរន្ធ ។

បញ្ចុកកូនគាប់អភ័ព្វអញ ម្ល៉េះទាវគ្នាន់ក្នាញ់ជាទុក្ខធ្ងន់
ទុក្ខមិនថ្ងបស្បើយល្ហើយស្រាក់ស្រន់ បួជាបែរបន់ទេវារ័ក្ស ។

សូមសុំប្រាថ្នាថាឲ្យអញ វិលវិញត្បិតទាវនាងស្មោះស្ម័គ្រ
ឥឡូវអាចក្តីមកឈប់ស្នាក់ ធុរៈក្នុងអង្គស្រយង់យំ ។

ស្រេចហើយនេនពេជ្រគេចហៅថា ទុំកុំសោកាគិតបារម្ភ
ទុក្ខអ្វីស្រីទាវនាងរៀបចំ នរណាហ៊ានបំព្រាត់ទាវទៅ ។

១៣០. រួចយកគោមកទឹមរទេះ បរវេះវាងរកកាត់តម្រូវ
តម្រង់ដោយដានលំអានផ្លូវ បរត្រូវត្រង់ភ្នំជ្រិស្រឡៅ ។

ស្រទ្បាំងភាំងភិតគិតទៅទៀត ចង្អៀតឱរាផ្សាខ្លោចក្តៅ
ស្រងាត់ស្រងោចស្រងូតសៅ បងមើលឃើញស្មៅស្មាប់ត្រាច់ត្រស់ ។

ឱឈើទាលត្រង់អង្គអញបែក នាងផ្អែកអញផ្អូកភ្នកស្រណោះ
ដើមផ្ដៀកអញផ្កាសប្រាសប្លែកសោះ កកោះក្រគិតឥតមានស្បើយ ។

គគីរគរគោកដូចរោគអញ ក្តួលក្តៅពោរពេញចុកណែនហើយ
ហៅថានេនពេជ្រសំឡាញ់អើយ ពេជ្រគ្មានឆ្លងឆ្លើយកន្តើយទប់ ។

ជាទុក្ខជួសទុំយំទាំងសង ខំថាសាសងទុំអើយឈប់
ចាំដល់វត្តស្ថានបានយូរយប់ យើងគិតគោរពបង្គំលា ។

១៣៥. ទូលលោកគ្រូយើងទំនើងថា លាសឹកមានការព្រោះវេទនា
កុំហាកថាញាតិញោមមិនជា កើតព្យាធិ៍រោគាជាទុក្ខធ្ងន់ ។

អ្នកនេនទាំងពីរនិយាយគ្នា បរស្រូតម្នីម្នាពារពេលពន់
ទេរទាបត្រជាក់អ្នកគយគន់ មើលព្រះសូរិយ័នក៏ទន់នៅ ។

បៀតបែរបាំងបាត់សត្វចរចូល ជិតជិះកំពូលគិរីនៅ
ទីទិសបស្ចិមបែរសំដៅ ឈ្មោះហៅសុមេរុរាជគិរី ។

បរបានដល់វត្តប្រាកដឈប់ ល្មមពេលព្រលប់ចូលក្នុងទី
ឈប់ឈរដោះគោលែងទាំងពីរ ឲ្យស៊ីស្មៅខ្ចីក្នុងទីស្ថាន ។

ហើយនេនពេជ្រទុំជំនុំនៅ នេនផងចូលទៅទាំងប៉ុន្មាន
សន្ទនាសួរគ្នាថាសុខប្រាណ លក់ដូរតើបានស្រូវឬប្រាក់ ។

១៤០. ឬយកកាក់លុយប្រថុយថា ប្រាប់ផងករុណាឲ្យត្រង់ជាក់
ត្រូវចិត្តត្បិតនេនពីររាក់ទាក់ ថាបានប្រឡាក់ប្រឡូកព្រម ។

ជាស្រូវជាស្រីជាល្អីច្រែង ជាជ័រជាស្នែងជាផ្ទាំងក្អម
ជាឈ្នួតផាហ៊ុមទឹកឃ្មុំល្មម កន្សែងសោតព្រមតែថ្លៃតោក ។

ហើយនេនគិតគួរពុំយូរលង់ នាំគ្នាតម្រង់ឡើងទៅរក
ថ្វាយបង្គំគ្រូជូនជាក្រោក តើនគង់ឈោងយកទឹកលុបភ័ក្ត្រ ។

នេនពីរក្រាបឱនលំទោនទាប សុភាពខ្លាចគ្រូទើបតើនភ្ញាក់
បារម្ភក្រែងខ្វាល់លោវាយធាក់ ស្រេចហើយបែរភ័ក្ត្រទតទៅសួរ ។

ពុទ្ធដីកាថានេនពេជ្រទុំទៅ លក់ដូរដោយន្ទូវតាមសមគួរ
បាសកឯនាយវាឆ្មើងជួ ឬវាទិញដូរទៅរាល់ខ្លួន ។

១៤៥. នេនឆ្លើយសងសបតបទូលទៅ ក្រាបទូលបានស្រូវគ្រប់ចំនួន
ចំណេញតោកស្មានជាបីបួន សមសួនល្មមកែតែគ្រាន់ចាយ ។

នេនក្រាបទូលគ្រូគួរសព្វគ្រប់ រួចលាត្រឡប់វិលប្រញាយ
ដើរដល់កុដិស្ថានសម្រាន្តកាយ ប្រះប្រាណនឿយណាយនឹកទាវទៀន ។

ថ្លែងថាអនិច្ចាជាកម្មអ្វី ទុក្ខកើតជាថ្មីទ្រូងចង្អៀត
លូកយកផាហ៊ុមដែលរុំសៀត ទុំឆ្លៀតថើថែប្រែប្រះប្រាណ ។

ក្លិនក្លែបអែបអប់ត្រឡប់ផ្កា ទុំយកហត្ថាក៏កាន់បាន
យកមកទទូរគ្របគិតស្មាន ថាបានគ្រាន់តែលំហែទុក្ខ ។

ទុំថាឱផ្កាបុប្ផាផង ធរធុំល្អប់ល្អងបងគ្មានសុខ
ធុំផ្កាំរំចេកដេកមិនលក់ ពិដោរគ្រប់មុខចុកឱរា ។

១៥០. ឱវែងស្រមៃវិស័យនៅ ជួបពៅជួនបានក្សាន្តចិន្តា
ម៉ែមន្តបងស្មូត្រមទ្រីបាពី ប្អូនបានបូជាផ្កាឈើផង ។

បូជាព្រះធម៌ធុំសាយសព្វ ប្អូនអប់ផាហ៊ុមប្រគេនបង
បូជាពុំងានាងទាវផ្សង ឲ្យជួបអញផងបងប្រាថ្នា ។

ឥឡូវអាចក្ដីឃ្លាតទាវហើយ ទាវអើយទល់ទុក្ខខ្លាំងខ្លោចផ្សា
ទាវទប់មិនឈ្នះអន្ទះសា មិនមានហើបហានិយាយស្ដី ។

បងអ្នកប្រមាណទាវបាននោ គាត់[១] ជួយគិតគួរលំហែស្រី
រំលឹកមិនឲ្យទាវចុះដី ក្រែងខ្លាដីរីសត្វអ្វីខាំ ។

ឬទាវលួចរត់ប្រាកដមក តាមបងជ្រុលជ្រកមិនបានផ្ដាំ
គ្រាន់តែសម្គាល់បន្ទាល់ចាំ ដោយថ្នាំដោយស្លាដោយផ្កាឈើ ។

១៥៥. ដោយបានបូជាផាហ៊ុមមក ឥឡូវបងភ្នកគ្រប់អន្លើ
លន្លន់លន្លោចត្រមោចស្មើរ មិនរស់ទេតើទុក្ខអង្គអញ ។

លង់លុះដល់ដាច់រដូវមួយ ទុំព្រួយរីងរីតតែស្រឡាញ់
ឃើញអស់កូនគេមកខ្ទួលខ្ទាញ់ ពាសពេញចូលវត្តសន្មតត្រូវ ។

---

១. ច្បាប់ខ្លះថា: បើបានខ្លួនបងនិត្យនៅយូរ គ្រាន់ជួយគិតគួរ... ។

មកបុណ្យមកបួសមកបិណ្ឌភ្ជុំ មកដល់ជំនុំជាច្រើនផ្លូវ
មករាប់បាត្រប្ញជាតម្រូវ តម្រង់រដូវចេញវស្សា ។
នេនទុំទុក្ខធំធំគ្មានស្បើយ ទុក្ខហើយហៅពេជ្រមកប្រាប់ថា
នេនពេជ្រប្អូនអើយបងឈឺផ្សា ដូច្នេះប្រាថ្នានៅមិនបាន ។
នេនពេជ្រទទួលស្រួលសងសប ថាទុំអើយថ្ងបឲ្យធូរក្សាន្ត
ទំរាំពារពេលយើងប្រមាណ ចូលថ្កានលាគ្រូធូរព្រះទ័យ ។
១៦០. នេនទាំងពីរពិតគិតថ្មោះស្រេច បែរគេចយកទៀនធូបឆាប់ខ្មី
ដើរទៅបានដល់ឡើងកុដី ដាក់អង្គគង់ខ្មីក្រាបបីដង ។
អុជទៀនអុជធូបក្រាបវន្ទា សូត្រចប់ចូលលាហើយសាសង
ថាសូមទានប្រោសអត់ទោសម្តង បំណងមកលាព្រះគុណធំ ។
លាចែកលាចាកសិក្ខាបទ សន្មតព្រះគុណប្រោសយើងខ្ញុំ
ទាំងពីរនាក់នឹងថ្វាយបង្គំ សូមសុំករុណាត្រាប្រណី ។
ត្បិតខ្វល់ដល់មានការធុរៈ ញាតិញោមដល់ថ្នាក់គាត់កើតអ្វី
រោគធ្ងន់ទុរន់មិនគប្បី ញោមស្រីដល់ស្រែបែរបន់ថា ។
អង្វររកជួរតួខ្មោចព្រៃ ដោយភ័យណាស់ហើយគាត់សច្ចា
សំពះអស់ខ្មោចនៅរក្សា ចំណាំជូនតាបង្ការសព្វ ។
១៦៥. គ្រោះថ្នាក់ជំពាក់ញោមស្រីបន់ ថាអន់ឲ្យខ្ញុំលាត្រឡប់
សឹកទៅឲ្យជាស្បើយកុំថប់ ជួបចប់ដល់ចាស់ឈ្មោះទាំងព្រម ។
លោកគ្រូស្តាប់ជាក់កន្ត្រាក់ក្តារ- ឆ្នួនបួកលេខហារថាតែហោង
កុហកអញទេអាកន្ទ្រម ស្រីចោមស្រូតចោលបោលមកលា ។
អញវាយលេខលុបគ្រប់ជើងហារ លេខឆ្លើយឡើងថាអាកុំពារ
កុំពុះទម្លុះក្រែងវេទនា ឃើញថានេនពេជ្រគេចគ្រាន់បើ ។

នេនពេជ្រសឹកចុះខែបុស្សបាន ទុំឯងឈប់ខានទើបប្រសើរ
ចាំដល់ពិសាខសិនសឹមដើរ សឹកហើយត្រូវលើបានជាធំ ។
លង់លុះដល់ត្រវរដូវខែ មិគសិរត្រូវខ្យល់ខ្វល់ជញ្ជ្រំ
រហើរហាល់ដល់នេនទុំ ក្រាបយំក្រុំយល់អំពល់ពីរ ។
១៧០. ដំណើរមួយព្រួយប្រាណមិនបានសឹក មួយទៀតព្រួយនឹកទាវនៅទី
នៅទាល់ត្បូងឃ្មុំសមស្រីនី- រាសប្អូនបានគេទេដឹងអើយ ។
នេនទុំនេនពេជ្រគេចបង្វិល ថាចាំថ្ងៃសីលក្រោយទៀតហើយ
យើងចេះតែលាណាពេជ្រអើយ ពេជ្រឆ្លើយថាកុំខំមិនបាន ។
នេនទុំទុក្ខងំកើតទៀតថ្មី ស្តាយស្រីស្តាយស្រស់ផ្ទស់គ្មានក្សាន្ត
អត់បាយចំណីស៊ីមិនបាន តិចណាស់មួយចានបានបីម៉ាត់ ។
លង់លុះគម្រប់ចប់ជួលជា វេលាខែបុស្សព្យុះខ្យល់ផាត់
រហើយត្រជាក់ភ្ញាក់ព្រឺប្រាត់ ផាយផាត់ពពកមកដេរដាស ។
ដង្គោលដង្គំប្រជុំជិត ងងឹតពេញស្ថានដានអាកាស
នេនពីរពង្សពិតគិតច្រឡាស ច្រឡើសមិនខ្មាសផ្តាសជាងគេ ។
១៧៥. នេនពេជ្រចូលលាពារប្រថុយ គិតថាខុសអុយបើលោកជេរ
ឡើងទៅដល់ដាក់អង្គកាយេ លើកហត្ថទាំងទ្វេប្រណម្យនៅ ។
លោកគ្រូសាកសួរគួរវិញថា ពេជ្រសឹកថ្ងៃណាក៏សឹកទៅ
ក្នុងខែបុស្សបានទំនួលត្រូវ សឹកចុះធ្វើស្រូវរដូវស្រួល ។
នេនទុំសម្ងំលបចាំស្តាប់ ពេជ្រគេសឹកឆាប់បានទំនួល
ឮថ្មោះហើយទុំក៏អាក់អួល ខ្មាញ់ខ្នួលរឹងរឹតជញ្ជឹងចាំ ។
រួចថាអញនៅមិនបានឡើយ ព្រះគុណខ្ញុំអើយហេតុតែកម្ម
ជាកាលណានឹងប្រឹងទ្រទ្រាំ ម៉្លេះសមស្លាប់ខ្លួនមួនមែនពិត ។

មិនស្តាយផ្អូសប្រាណបានប៉ុនសក់ កម្មនាំកញ្ឆក់ឲ្យងងឹត
មោហ៍បាំងឆ្នាំងគ្របក្រសោបរឹត គ្មានគិតគ្មានគួរលោកគ្រូខ្វាល់ ។
១៨០. នេនពេជ្រលាសឹកព្រឹកនេះទៅ ទុំនៅក្រៀមផ្អស់ស្ទុះទៅគាល់
បណ្ឌិតពេជ្រឃាត់ថាកុំអាល ចាំស្រាលព្រះទ័យភ័យថ្វីពេក ។
យើងស្លេះទុំពេជ្រគេចសម្តែង ស្រីទាវចំបែងរែងវិវេក
កើតទុក្ខមួនមាំក្រំសញ្ចែក រារែករឹតរឹងទន្ទឹងទុំ ។
ថាឱអញស្តាយក្រហាយប្រាណ មិនក្សាន្តធ្ងន់ខ្លួនប្រៀបហាក់ភ្នំ
រលើងបព្វតាផ្ការលំ សង្កត់សៀតក្រំរណ្តំខ្លាំង ។
ខ្លោចផ្សាក្តៅក្តួលខ្នួលក្នុងថ្លើម ដង្ហើមផុតៗស្លុតភាន់ភាំង
ម្លេះហើយលោកអើយប្អូនមរណំ ខ្លួនស្លាំងស្តាំងស្តមទ្រមវេទនា ។
ពីដួចរូចអ្នកចាកចោលទៅ ទុកខ្ញុំប្អូននៅឲ្យកំព្រា
កំព្រោនព្រួយប្រាណពុំបានជា ទាវរារកមើលព្រើលស្រមៃ ។
១៨៥. ហាក់ដូចឮស័ព្ទចាប់ដល់ទុំ លោកស្មូត្រស្តាប់ជុំណាំអ្នកថ្លៃ
សូរស័ព្ទសម្លេងគួរអាល័យ ទាំងរូបប៉ប្រែប៉ប្រិមប្រែ ។
សម្បុរយល់ចាប់ប្រដាប់ស្បង់ ត្រចង់ដូចវង្សព្រះច័ន្ទដែរ
ត្រចះភ័ក្ត្រមូលស្រួលដូចខែ ដូតខាត់ដុសបែរជាបែកបាត់ ។
ជាបានប្រាណប្រុសមកវិញដែរ ឬមួយជាបែរដោយឈើថ្កាត់
ធ្វើម្តេចបានដឹងដំណឹងស្ងាត់ ជួលគេឲ្យស្កាត់រង្គាត់គន់ ។
មិនដឹងជាផ្លូវទៅត្រង់ណា ខ្លួនអើយខ្លោចផ្សាជាទុក្ខធ្ងន់
ពាប់ពៀបដូចទូកដូចទឹកជន់ ដោយទន់ដល់ទៀបហៀបក្សិណក្ស័យ ។
រួចទាវហៅទៅនាងនោថា នោអើយជួយរ៉ាជួយរាប់ដៃ
ជាយូរឬឆាប់ដោយស្រមៃ នោស្មានខែថ្ងៃប៉ុន្មានមក ។

១៩០. នាងនោភីលៀងបញ្ចៀងឲ្យ ថាចាំខែក្រោយមើលពពក
សាត់ពីទិសទីភ្លៀសានជ្រក ពពួនសមភ្នកមកទាវស្រី ។
ខ្យល់ផាត់ត្រជាក់ធ្លាក់សន្សើម ជ្រួលជ្រើមក្នុងចិត្តគិតប្រណី
ប្រឹងនឹកមកទាវចង់បេតី ហេតុអ្វីប្រដល់ទាល់ជាសង្ស័ ។
សព្វថ្ងៃព្រួយដែរតែគ្មានសុខ ម្ល៉េះសឹងមិនលក់ត្បិតបោះបង់
បែរបែកត្បិតបានប្រាថ្នាផ្ដង់ សាងសីលស្មោះត្រង់តម្រង់កាយ ។
តម្រេកទុំគិតចង់ស្និទ្ធស្នេ- ហាហេតុព្រោះតែខ្លួននៅឆ្ងាយ
មិនយូរប៉ុន្មានទេទាវអាយ លោកស្រាយសិក្ខាប្រាថ្នាជាក់ ។
កុំទុក្ខទួញយំសុំឃាត់នាង សមគេមិនរាងកុំផ្ដើលភ្ញាក់
ក្រែងជាមិនជាកើតធុរៈ ដឹងដល់ម្ដាយជាក់ជេរផ្ដាសា ។
១៩៥. ថាកូនមិនសុទ្ធពុតដូចគោ សន្ដានគេហៅគេសើចថា
កូនមានពូជពង្សមានវង្សា ព្រោះឥតកិរិយាស្រីចង្រៃ ។
ហៅបងរំលឹកកុំនាងខឹង បងនឹងទទឹងទេណាថ្លៃ
នឹកធ្លាប់ដឹងចិត្តមកសព្វថ្ងៃ វិស័យដូចពាក្យបុរាណថា ។
ធម្មជាតិជានំគេផ្ដុំបាន ដាក់ក្នុងនាឡិចានតាមចិន្ដា
មិនដែលនំធំលើសប៉ុនណា ទាវអើយបងមហាថប់ថៃធួន ។
ក្រែងគេមិនមករកទាវទេ ទាវប្អូនកុំជេរបងក្រែងជួន
រំលឹកទៅចុះក្រែងគ្រោះខ្លួន ត្បិតអីព្ធដ្ឋូនគេកួនគុំ ។
សមគេជាកូនចៅហ្វាយស្រុក បុណ្យគេធំស្ដុកនាម៉ឺនជុំ
ឈររក្សាខេត្តខាងត្បូងឃុំ ទុំរាស្ត្រទាំងផ្ដាសដូចគេឯង ។
២០០. បងប្រាប់ទាវទៅពៅកុំអាក់ កុំអន់ថ្នាំងថ្នាក់ចិត្តចំបែង
មិនបានប្រមាណទេទុំស្វែង មកដល់មិនលែងកន្លែងស្រាប់ ។

ទាវឆ្លើយថាមែនដូចនោថា		នោមានប្រាជ្ញាវៃចំណាប់
ថាត្រូវសមទុំមកដល់ឆាប់		នោប្រាប់អរព្រឹសលើសសព្វដង ។
ដឹងហើយទាវស្បើយប្រាណបានតិច		ប្រះប្រាណដេកផ្ទេចលក់ជាម្តង
លុះភ្ញាក់ព្រើតប្រឹងរំពឹងបង		អុជទៀនធូបផ្សងដល់នេនទុំ ។
ស្លេះរឿងទាវទៀតឆ្លៀតសម្តែង		ដំណើរទុំតែងយកជាហ៊ុម
គ្របគ្រងកាយាពិដោរធុំ		ក្រអូបពិតពុំមានរសាយ ។
លុះជួបជូនយប់យន់ស្ងប់ស្ងាត់		ព្រួចព្រើប្រមាត់រន្ធត់កាយ
រន្ធត់ថែថប់ជ្រប់ខ្វល់ខ្វាយ		មិនស្តាយចង់សឹកនឹកទាវស្រី ។
២០៥. ព្រឹកព្រាងឡើងច្បាស់ព្រះសូរ្យសែង		ចាំងថែងពីបូព៌ារស្មី
ចំហាយដល់អង្គពុំលង់ខ្មី		ទុំចុះដល់ដីដើរចេញទៅ ។
លង់លុះបានដល់សកលស្ថាន		ផ្ទះម្តាយទុំបានជួនជួបនៅ
ម្តាយសោតយង់យល់កូនដល់ទៅ		ត្រេកអរថៅរ៉ៅចុះម្ទីម្នា ។
មកពិតទូលថានេនបាបុត្រ		មន្តមកពីកុដិថ្មើរណោះណា
ចុះកូនពន្លកមកនេះជា		ទុក្ខព្រួយវេទនាឬសុខសាន្ត ។
នេនទុំយំយែកទឹកភ្នែកស្រក់		គិតភ្ញួតកុហកព្រោះមិនក្សាន្ត
ចំរើនពរញោមឆាន់មិនបាន		អាចក្តីប្រមាណប្រាណមិនស្រួល ។
ឆៀបឈឺក្នុងពោះលោះថ្ងៃតិច		ដូចគេខ្វារក្តិចស្មានដូចម្ជុល
ដូចម្ជុត្រសំបោរក្តៅខ្នាញ់ខ្នួល		រំដួលព្រឺព្រួចរួចខានសឹង ។
២១០. នឹងផ្ទេចមិនលក់ទេញោមអើយ		ពូកកែបកល់កើយដេកស្លូកស្ពឹង
ប្រះប្រាណដល់ខ្មើយជំលើយរឹង		ដូចខឹងខំអត់សង្កត់ទុក្ខ ។
អាចក្តីដំណាលកាលថ្ងៃមុន		ឡើងលាព្រះគុណគ្មានមើលមុខ
ពិតថាមិនស្រួលម្ជួលសៀតចុក		ថាខ្លួនមិនសុខមិនសូវជា ។

លោកគ្មានបើកសោះបណ្ដោះពេជ្រ ឯងទូលដូចម្ដេចលោករាំងរា
ឃាត់ទុក្ខធ្វើអ្វីឲ្យវេទនា ញោមទៅបំពារលាឲ្យផង ។
មេម៉ាយម្ដាយទុំយំតាមកូន គាត់ក្រាបអង្គឱនហើយសាសង
ថាម្ចាស់ម្ដាយអើយកូនសព្វដង មិនដែលមានហ្មងផ្គងនឹងអ្វី ។
លោកគ្រូរាប់អានជាងគេគាប់ ប្រគល់អស់ទ្រព្យទោះចាស់ថ្មី
ឲ្យបាថែទាំស្លាបារី បាយទឹកចំណីស៊ីតាមចិត្ត ។
២១៥. ចុះមានបើហេតុម្ដេចម្ដងណេះ ម្ដាយវែងត្រេកត្រិះគួរអាណិត
អាសូរកូនគូស្មើជីវិត ឥឡូវទុក្ខឥតនរណាដឹង ។
ពីតូចដល់ទុំធំម្ល៉េះហើយ កូនអើយម្ដាយពួតែដំណឹង
ដំណាលទៅចុះក្រែងខុសផ្សឹង បើម្ល៉ឹងធ្វើម្ដេចសុំម្ដាយទៅ ។
នេនទុំពួម្ដាយរសាយទុក្ខ ចូរអង្គបានសុខសាន្តដោយនៅ
ដោយអ្នកម្ដាយស្រីគាត់ស្ដីត្រូវ តាមផ្លូវខុសខូចរួចទុំលា ។
ថាញោមអាចក្ដីទៅវត្តឋាន ញោមតើថ្មើរម៉ានឆាប់ម្ទីម្នា
រួសរាន់ប្រញាប់កុំរេរា ទាន់អាចក្ដីជាអន់អង្គប្រាណ ។
ហើយមួយស្មានដូចខ្មោចដូនតា តែងនៅរក្សាទាំងប៉ុន្មាន
ដូច្នោះជួយផងបើម៉ែបាន ទៅលាគ្រូក្សាន្តស្រួលព្រះទ័យ ។
២២០. មេម៉ាយម្ដាយទុំជញ្ជឹងគិត យល់ដោយគំនិតរហ័សវៃ
លូកហាត្ថាចាប់ម្លូស្លាខ្ចី ទៀនធូបយកស្បៃដណ្ដប់ដើរ ។
ចរចុះល្វតល្វន់ស្រទន់ស្រេច ទើបគាត់ចរត្រាច់ចូលទៅស្នើ
នឹងគ្រូសូត្រមួយអង្គគ្រាន់បើ ថាយើលោកម្ចាស់ខ្ញុំខ្មាសគេ ។
អ្នកផងអឹងកងទាំងក្មេងចាស់ គេសរសើរណាស់ឥឡូវប្រែ
ព្រះទ័យព្រះគុណមិនធូន់ដែរ ថាលោកគ្រូកែគិតបទណា ។

នេនទុំកូនខ្ញុំថ្វីលោកម្ចាស់ គាប់ណាស់ម្តេចគួរលោកមេត្តា
កូនខ្ញុំទៅប្រាប់ដល់ម្តាយថា លាចាកសិក្ខាសញ្ញាកូន ។
ជាអកុសលតម្កល់ទប់ មិនបានជាឈប់នៅសុខសួន្យ
ជាសាមណេរទេណាំលោកប្អូន ដោយខ្លួនជាស្រីសេចក្តីទាល់ ។
២២៥. ទើបនាងម្តាយទុំបង្គំលា ចាកទីនោះណាលីលាដល់
ឡើងកុដិលោកគ្រូបង្គំគាល់ លើកហត្ថតម្កល់លើសិរសា ។
ហើយពិតថាខ្ញុំសូមក្រាបទូល បើគួរមិនគួរប្រោសករុណា
ប្រណីខ្លួនស្រីឥតសិកា[១] ចេះអ្វីហ៊ានថាវាចាជួស ។
នេនទុំកូនខ្ញុំមន្តទៅដល់ ផ្ទះហើយមិនសល់ថាទ្រាំផ្នួស
ចង់ចាកសិក្ខាប្រាថ្នាបួស នៅយូរក្រែងជ្រួសជ្រលួសលេង ។
ឲ្យខុសផ្ដោះផ្ដោយដោយខ្លួនពាល នៅស្រាលតម្រេកពេកនឹងល្បែង
ខ្ញុំម្ចាស់ព្រួយណាស់មួយគិតក្រែង ចំបែងឈឺមួលមិនស្រួលខ្លួន ។
មែនឬព្រះគុណធូន់ដូចថ្ម ក្រែងឲ្យឆាន់ស្ករនំចិនយួន
នោមយប់ថាស្ទះធូរដោយជួន ជុះយប់ដេកពួនពុំបានសោះ ។
២៣០. លោកគ្រូពុំយូរមានពុទ្ធដីកា ថាទេសិកាទុំកម្លោះ
លាទៅលក់តោកក៏ដាច់អស់ មកដល់ក្រៀមក្រោះស្រណោះស្រី ។
ខាងខេត្តត្បូងឃ្មុំក្រមុំច្រើន សៀបស្រស់ស្រវើនក្មេងលីវថ្មី
ឥឡូវចចើងចង់បានប្តី ហេតុហ្នឹងអាចក្តីយល់ពុំគាប់ ។
ពុំគួរបណ្តោយឲ្យសឹកទៅ វាយលេខឃើញត្រូវពានលើងាប់
ទំនាយនេនទុំថាអភ័ព្វ ឃាត់ជាប់ទំរាំដាច់ឆ្នាំហ្នឹង ។

---

១. ច្បាប់ខ្លះថា ខ្ញុំជាសិកា ។

នាងជាមេម៉ាយម្ដាយនេនទុំ ស្ដាប់លោកគ្រូធំគន់សម្លឹង
សម្លក់មកគាត់ឃាតរីតរឹង ពុទ្ធដីកាក្រញឹងដូចខឹងខ្លាំង ។
រួចគាត់លាចុះមកដល់ដី ថាកូនពិសីកុំតតាំង
ទល់តបធ្វើម្ដេចប្រៀបដូចច្បាំង ត្រូវដូចបារាំងអាងកាំភ្លើង ។
២៣៥. តែលោបាញ់បាត់មិនបាត់ស័ព្ទ ទៅត្រូវសត្វស្លាប់ដូចខ្លួនយើង
បើលោទាយថាផ្ការរលើង រលំបាក់ជើងដួលដល់ស្លាប់ ។
ហេតុនោះឈប់ទៅឬពៅម្ដាយ បើក្ដៅក្រហាយកូនក្រឡាប់
ក្រឡេករកទឹកផឹកលុបឆាប់ ស្រង់ស្រស់រួចចាប់ចារសរសេរ ។
រៀនសូត្រធម៌អាចធ្វើការអ្វី ចរចេញពីក្ដីទើបបិតថេរ
ប្រៀបដូចសំពត់រហែកដេរ ប៉ាក់ថ្មេររៀបចំខំបោសឋាន ។
ទើបនេនទុំឆ្លើយថាណ្ហើយឈប់ ញោមកុំប្រៀបសព្វទប់មិនបាន
អញ្ជើញទៅផ្ទះប្រះសម្រាន្ត ញោមទ្រាំកំសាន្តកុំសោយសោក ។
ចាំមើលដល់ព្រឹកនឹកថ្មីទុំ យកតែជាហ៊ុមទាវឲ្យមក
ដើរទៅចូលព្រៃប្រស្រ័យជ្រក ស្ងាត់ហើយទុំក្រោកឈរវន្ទា ។
២៤០. ថ្វាយបង្គំព្រះសំពះគ្រូ ផ្លាស់ស្បង់ពុំយូររួចលីលា
សឹមចរចូលទៅក្នុងព្រះវិហារ ស្មាលាទោសទុក្ខមុខជាបាប[១] ។
នេនទុំជំនុំតែនឹងម្ដាយ ក្រហាយក្នុងខ្លួនដូចឈឺដាប
ឈឺហ្នឹងឈឺចិត្តផ្អិតមិនសាប សូមក្រាបលាកលាឃ្លាឃ្លាតហើយ ។
ព្រះគុណថ្លៃខ្ញុំកុំប្រកាន់ កុំយកទោសឆាន់ករុណាឡើយ
សូមស្មោះពិតស្មោះដោះឲ្យស្បើយ ដល់ត្រើយផុតទុក្ខទៅមុខទៀត ។

---

១. ច្បាប់ខ្លះ ចូលព្រះវិហារហើយស្មាលា ទោសទុក្ខនានាដែលជាបាប ។

នេនទុំគិតស្រេចគេចស្មោះភ្លឹង ម្នោម្នះដោយខឹងលះស្លង់ស្មៀត
ចាប់យកសំពត់ផ្គត់វេចសៀត កណ្ដៀតដើរដល់យល់ព្រៃធំ ។
សូមស្នួនពួនជ្រកយកបណ្ណា ភ្ញីផ្កាទៀនធូបចំណីនំ
បូជាទេវាស្រេចនេនទុំ ផ្គងផ្គុំលើកហត្ថប្រណិប័តន៍ថ្វាយ ។
២៤៩. សូត្រថា **ឧកាសសត្ថេ** **កាមំកាមេ** នៅដែនអាយ
**ចរូបេ** ប៉ងបំណងកាយ **តិរិ** សឹកស្រាយមិនស្ដាយសោះ ។
វន្ទាវន្ទះអ្នកកុំឃាត់ ផ្លាស់ស្បង់ចោលម៉ត់មិនស្រណោះ
រួចស្លៀកសំពត់ហូលល្អស្រស់ លើកអស់អង្សកដាក់ទុកទើរ ។
ព្រឹក្សាប្រគាបទាបជិតដី បណ្ឌិតទុំថ្មីគាត់ហ៊ានធ្វើ
សឹកស្រេចចរត្រាច់ដើរលលើ អំពើពុតខូចមិនរួចខ្លួន ។
ដើរដល់សកលឋានបន្តិច វេះវាងរកពេជ្រស្រេចជួបជួន
បណ្ឌិតពេជ្រសើចហើយជ្រកពួន ទុំចាប់អង្រួនអង្រន់លេង ។
គ្រានោះពុំលង់រង់យូរថ្ងៃ ទុំនឹកអាល័យទាវហើយឈ្វេង
ជ្រុលជ្រប់ស្រយុតស្លុតវង្វេង នឹកណាស់កន្លេងកន្លែងដែល ។
២៥០. ស្រមៃដូចហាក់ភ្ញាក់ប្រវា ចាប់ដៃសិកាថាប្រហែល
ដូចទាវនាងសាវធំគ្រាន់ក្រែល ដំណែលដំណើរទេណាំស្រី ។
ស្រណោះស្រស់នួនស្ងួនស្ដាប់បង ស្នូត្រឲ្យអ្នកផងញាតិនៅដី
នៅដែនត្បូងឃ្មុំជុំថ្មីៗ មិនមានភ្លេចក្ដីស្និទ្ធស្នេហា ។
បណ្ឌិតទុំទើបនឹងសឹកថ្មី ប្រាប់ពេជ្រថាវ៉ីពេជ្រខ្ញុំថា
ឲ្យប្អូនអាណិតត្បិតបេក្ខា ចិន្ដាប៉ុនប៉ងបំណងនឹក ។
ភ្នកដល់ស្រីទាវនាវទុកស្រាប់ បានឲ្យជន្លាប់ទើបរលឹក
សម្ងត់ផាហ៊ុមផុំក្លិនភ្លឹក រាល់ពេលយប់ព្រឹកទាន់សឹកហើយ ។

បណ្ឌិតពេជ្រប្រុងរង់ចាំស្ដាប់ ឆ្លើយថាខរ៉ាប់[១] មែនទុំអើយ
បើថ្មោះទុំដើរពុំទាន់ស្បើយ ទៅឡើយព្រោះខ្លួនមួនមិនសុខ ។

២៥៥. នៅទោសត្បិតអីឯងមានថ្នាក់ គ្រោះបួសជៀងជាក់ជាកុលបុត្រ
គ្មានជឿព្រះគុណធ្ងន់បំផុត ហ៊ានរត់ទៅសឹកមិននឹកស្ដាយ ។

ទុំថាបើថ្មោះពេជ្រជូនទៅ យើងរកគ្រឿងគ្រៅភោជន៍ទាំងឡាយ
ប្រគេនលោកគ្រូលាទោសស្រាយ ទើបបាត់ក្រហាយក្នុងព្រះទ័យ ។

បណ្ឌិតពីរពិតគិតឃើញស្រេច ចរត្រាច់ទៅផ្ទះរួសរាន់វៃ
រកអស់ភោជ្យផលផ្លែឈើព្រៃ បានស្រេចទុំស្ពីពេជ្រជូនដល់ ។

ចូលដល់ក្នុងឋានបានឡើងកុដិ លោកគ្រូគង់ផ្ដត់ផ្អែកខ្នើយខ្នល់
ទុំពេជ្រដាក់អង្គលើកករកល់ ភ្ញុំភ្ញិត[២] ផ្ទឹមផ្ទាល់លើសិរសា ។

លោកគ្រូឆ្មៀងភ័ក្ត្រជាក់ប្រាកដ ថាទុំកម្សត់មកមានការ
រកអញថ្មីទៀតមារយាទអា ណ្ហើយចុះមិនថាធម្មតាសង្ឃ ។

២៦០. មិនដែលគ្រូណាផ្ដាសាសព្វ មិនមានខឹងស្អប់លោកស្មោះត្រង់
បើសិស្សរអិលល្អៀងផ្អៀងតម្រង់ តម្រែក្នុងអង្គប្រុងប្រដៅ ។

ឲ្យកើតកេរ្តិ៍យសខ្ពស់ក្រដាច បើសិស្សណាខ្លាចហើយល្ងង់ខ្លៅ
លោកប្រឹងបង្ហាត់កុំឲ្យនៅ រកហៅរៀនសូត្ររហូតចេះ ។

ពេជ្រទុំប្រណម្យក្រាបស្ដាប់គ្រូ ប្រដៅគ្រប់ផ្លូវនៅកកេះ
ក្រចកដកកអៀនស្រមេះ រួចរិះឆ្លើយឆ្លងសងពុទ្ធដីកា ។

---

១. ច្បាប់ខ្លះ ឆ្លើយឆាប់ថាអើ ។
២. ច្បាប់ខ្លះថា ផ្ទុំដៃ ។

សូមទានយើងខ្ញុំសុំទោសទុក្ខ ប្រោសប្រាណទៅមុខទ្រង់ករុណា
ព្រះគុណអត់អស់នូវទោសា មេត្តាគង់កើតថែវរៀងទៅ ។
ខ្លួនខ្ញុំខុសឆ្គងហ្មងម្ដេចក្ដី សូមសុំព្រះទ័យប្រោសឲ្យនៅ
ជាសិស្សព្រះគុណទុកជាខ្លៅ ដោយក្ដៅតណ្ហាសង្សារសត្វ ។
២៦៥. លោកគ្រូមានពុទ្ធដីកាឆ្លើយ ថាអើមែនហើយដូចឯងកាត់
ស្ដីនោះចំពោះត្រូវពេញមាត់ ប៉ុន្តែប្រយ័ត្នថ្កាត់ដល់ខ្លួន ។
អញអត់ទាំងអស់ទោសចាស់ថ្មី ក្នុងនាលោកិយកុំឲ្យជួន
ទុក្ខពីមុនមកនឹងជ្រកពួន មិនរួចត្បិតក្បួនច្បាប់ប្រាប់ច្បាស់ ។
ព្រះអង្គសម្ដែងតែងមានទុក្ខ ក្សិណប្រែជាសុខរៀងដល់ចាស់
ឯថ្នាក់មរណំតាំងស្រឡះ[1] ព្រះពុទ្ធដីកាព្រះត្រាស់ទេសនា ។
បណ្ឌិតពេជ្រទុំបង្គំនៅ ចាំស្ដាប់ប្រដៅព្រះពុទ្ធដីកា
លោកគ្រូអាណិតសិស្សសូត្រថា **កត្តាវត្ថុ** បទទាំងបី ។
ពរព្រះជាម្ចាស់ទុកទូន្មាន សត្វណាស្រេកឃ្លានទាំងប្រុសស្រី
ធម្មតាកើតមកក្នុងលោកិយ សួស្ដីមង្គលយល់ស្រោប់ហើយ ។
២៧០. ពេជ្រទុំប្រណម្យស្ដាប់លោកគ្រូ សូត្រចប់ឲ្យពរទទួលឆ្លើយ
ជាសាធុសូមឲ្យបានសៀយ ល្ហៃល្ហើយដូចពរអរទទួល ។
លើកហត្ថប្រណិប័តន៍ផ្ទិតទាំងសង ក្នុងចិត្តប៉ុនប៉ងត្រូវទំនួល
ដំណើរលើខ្លួនត្រេករំជួល ស្រាកស្រួលព្រឺសព្រើធ្វើហាក់រាយ ។
ទើបទូលលាលោកថាសូមសុំ ព្រះគុណប្រោសខ្ញុំត្បិតនិយាយ
នឹងអស់បាសកនៅស្រុកនាយ រួចរាយរាល់គ្នាថាឲ្យទៅ ។

---

១. ច្បាប់ខ្លះថា ក្រែលក្រាស់ ។

សន្មតប្រាកដមិនឲ្យខាន　　សន្តានផ្ដាំនោះចំពោះត្រូវ
ប្រមាណបណ្ដាក់តោកជាស្រូវ　　អង់នៅក្រែងខុសអស់សញ្ញា ។
បាសកត្បូងឃ្មុំទទឹងថ្ងៃ　　ពួនពឹងអាស្រ័យព្រៃបន្លា
នូវមន្តអាគមវិជ្ជាការ[1]　　ខ្មោចព្រាយអ្នកតាគោបាធ្មប់ ។

២៧៥. ហើយមានតម្រិះចេះសុខុម　　វាគិតផ្សំផ្គុំទុំឲ្យឈប់
ផ្គងនឹងនាងទាវទើបចូលម្លប់　　យើងខ្ញុំដូចស្អប់វេះវាងមក ។
លោកគ្រូផ្គងស្ដាប់ស័ព្ទទុំពេជ្រ　　ឆ្លើយគេចកែថាឯងគិតភ្នក[2]
មិនមែនទេតើអាកំព្រក　　ធម្មតាទុក្ខសោកសព្វបណ្ដា ។
មនុស្សក្នុងលោកិយទាំងស្រីប្រុស　　មិនដែលស្អប់អស់ស្រីទេណា៎
កុំភូតកុហកអញដឹងការណ៏　　ប៉ុន្តែមិនថាដូចផ្ទុញផ្ទាល់ ។
ហើយឯលោកគ្រូគួរគិតឲ្យ　　បណ្ដោយតាមចិត្តមិនមានសល់
ថាអាទៅចុះកុំខ្វាយខ្វល់　　ខ្លួនទ័លស្គាល់គេឲ្យថេរលង់ ។
កុំអាងប្រាជ្ញាក្លាគ្មានកោត　　ខ្លាចគេចាក់ដោតព្រោះខ្លួនផុង
ស្រដីមិនកោតគេពូជព-　　ង្សាវតារគេគង់ប្រុងកិរិយា ។

២៨០. កុំអាទាហានរានទីទៅ　　ដំបូចកូនចៅគេផ្ដាសា
ប្រពន្ធគេធំកុំរុឺយអា　　ប៉ុនប៉ងប្រាថ្នាស្រវាចាប់ ។
ប្រកៀកប្រកាន់កំណាន់នឹង　　ធម្មតាស្រីរឹងចង់ដោយឆាប់
វារកកម្លោះថ្លោះចំណាប់　　ប្រញាប់ទាន់ចិត្តឥតគិតក្រែង ។

---

១. ច្បាប់ខ្លះថា គេមានអាគមមន្តគាថា ។

២. ច្បាប់ខ្លះថា ឆ្លើយគេចកែថាឯងលៃលក ។

ដំណាលដំនៀលដល់មកគ្រូ អង្គព្រះសព្វញ្ញូទ្រង់សម្ដែង
ថាបាបដរាបដាច់សង្វែង ផុតលែងកបកើតកំណើតទៀត ។
ឯអញគ្រូឯងអត់ទោសា មិនប្រកាន់ថាឲ្យចង្អៀត
អញឲ្យពរអ្នកចូរបែរបៀត មកគ្រូនឹងឆ្មៀតសម្ដែងធម៌ ។
លោកគ្រូកាន់ផ្ចិតបិទព្រះភក្ត្រ សូត្របានឮជាក់ឲ្យត្រេកអរ
**អាយុវណ្ណំ** សុខស្មោះសរ **សុខំ** ឲ្យបរិបូណ៌បានបុណ្យ ។
**ពលាពលំ** ទាំងពីរនាក់ ឲ្យមានយសសក្តិប្រាក់ទ្រព្យធន
កម្លាំងប្រាជ្ញាមិនអាប់អន់ ប្រពន្ធក្រមុំព្រហ្មចារី ។
កេរ្តិ៍ឈ្មោះល្បីល្បាយសាយអំណាច អ្នកផងកោតខ្លាចទាំងប្រុសស្រី
នៅចុះព្យាបាលទាំងទឹកដី ស្រុកស្រីទាវនៅទៅឲ្យបាន ។
កូនសិស្សបណ្ឌិតពិតពីរពេញ អម្នេញពេញម្នះអស់ពីប្រាណ
ឥតអ្វីយកមកប្រៀបប្រមាណ ស្មោះស្មើដូចបានស្ថានសួគ៌ា ។
ស្រេចហើយបណ្ឌិតក្រាបស្ដាប់គ្រូ លោកគ្រូឲ្យពរអភិវា[1]
អភិវាទលើកហត្ថបង្គំលា ចរចុះម្ទីម្នាដើរចេញទៅ ។
ឡើងដល់លើផ្ទះដាក់អង្គកាយ ស្រដីប្រាប់ម្ដាយថាឥឡូវ
អ្នកម៉ែយើងនេះសន្មតថាត្រូវ ដោយនូវដំណើរតើអ្នកម្ដាយ ។
២៩០. ជាបើកឲ្យកូនឬអ្នកឃាត់ ត្បិតជួបសន្មតយើងឯអាយ
គេថាបើបានសុខក្នុងកាយ សប្បាយជានាថាឲ្យទៅ ។
ម្ដាយអ្នកបណ្ឌិតគិតចង់ឃាត់ ទើបគាត់ស្រដីថាកូនពៅ
ម្ដាយនេះសព្វថ្ងៃដូចមិនស្ងួវ សុខសាន្តដោយនូវត្រូវរោគា ។

---

១. ច្បាប់ខ្លះថា តួពីរអង្គា ។

ចាស់ខ្លួនជូនដល់កុសលត្រូវ នឹងពឹងរកហៅញាតិផងគ្នា
មិនដូចជាកូនស្ងួនពុំងា ម្ដាយនឹងរាំងរាពេលាបាន ។
ថាកូនប្រាកដសន្មតត្រូវ អ្នកនឹងចេញទៅនឹងឈប់ខាន
វាបង់នាទីពីបុរាណ កូនស្មានប្រយ័ត្នណាំថ្លៃម្ដាយ ។
ទើបឯបណ្ឌិតពិតពីរប្រាណ អរបានដូចគ្នាទាំងពីរកាយ
ស្មោះសរត្រេកអរពេកអម្បាយ ក្រហាយដូចម្ដេចក៏គេចហើយ ។
២៩៥. បណ្ឌិតពេជ្រទុំជំនុំគ្នា បែរភ្នានិយាយផ្លាស់ឆ្លងឆ្លើយ
ថាយើងទៅដើរសម្លាញ់អើយ ពេលពន់នៅឡើយមិនទាន់រក ។
ថ្មើរមាណដើរបានប្រាណមានជ័យ មានលាភគ្មានភ័យពេលាជោគ
សិរីទ្ធិយាឬតាមលោក ទាំងពួងបែងបូកយកស្លោកសូន្យ
កាកបាទមិនស្អាតខាតទ្រព្យា ចេញដើរខុសពារវេទនាខ្លួន
ដើរត្រូវសូន្យពីរឬសូន្យបួន ចរជួនលាភៈជាក់ប្រាកដ ។
បណ្ឌិតពីរពេញស្រឡាញ់ពេល ប្រហែលចេញដើរដោយសន្មត
ពេលព្រឹកភ្លឺស្វាងបំព្រោងព្រាត់ ទើបគាត់ទាំងពីរលីលាចេញ ។
ចាកចរជួបផ្លូវត្រូវវាលស្រែ យល់ញាតិដើរហែងាកវិលវិញ
គំនាប់សន្ដានទាំងពួងមិញ មីងមាថាអញខ្ញុំប្រណិប័តន៍ ។
៣០០. ក្រាបលារាល់គ្នាទៅត្បូងឃ្មុំ មីងអើយកុំយំខ្ញុំមិនកាត់
ចោលស្រុកភូមិស្ថានទេវិលថ្វាត់ មីងមាកុំផាត់ទាត់ម្ដាយខ្ញុំ ។
អាណិតគាត់ផងបងប្អូនស្រាប់ តាមដោយសណ្ដាប់ជួយថែទាំ
ក្រែងមានធុរៈរោគមកផ្សំ ក្រាលក្រំចុកញាត់ហាត់ហឹតហៀវ ។
សន្ដានទុំពេជ្រគេចឆ្លងឆ្លើយ ថាអើក្មួយមុខអីយទ្រង់ខៀវ
បែរខ្វាកចេញចាកវិលរួសរៀវ ទុក្ខទាវដូចទឹកនឹកដល់ទុំ ។

ទើបឯបណ្ឌិតពីរលីលា ធ្លាក់ដល់មាគ៌ាស្រុកត្បូងឃ្មុំ
ដើរហើយអល់ឯកនឹកភូមិឃុំ ពេជ្រទុំរិះរែងចម្បែងចិត្ត ។
ទើបទុំដល់ជ្រៃឈើរបោះ នឹកដើមស្រណោះឆ្អល់ឆ្អែតឆ្អិត
ស្រក់ស្រោកទឹកភ្នែកនឹកនោមស្និទ្ធ ទាវអើយបងគិតឥតឧបមា ។
៣០៥. មកយល់វាលវែងត្រែងដួលដុះ ផ្កាសត្រសុសផ្លេកភ្លឺថ្លា
ដូចរូបសម្បុរពណ៌កនិដ្ឋា ដូចផ្កាត្រែងត្រស់ស្រណោះពេក ។
មៀងមើលទឹកជ្រៅស្មៅត្រកៀត ចិត្តបងចង្អៀតរីងរិវេក
ត្រកួនដូចខ្លួនបងឈប់ដេក ឈប់ដោយម្លប់មែកត្របែកព្រៃ ។
យាប្លងដូចបងភ្លាត់ឃ្លាតឆ្ងាយ ព្រៃព្រួយមកអាយយូរឃ្លាតឃ្លៃ
ស្រងេះស្រងូតរហូតវៃ ម្លេះសមប្អូនភ័យមមៃគិត ។
ហើយអ្នកពីរប្រាណបានដល់ព្រៃ ដល់ព្រឹករំពៃព្រួយរីងរឹត
ទុំរាប់ដើមឈើប្រើបណ្ឌិត ពេជ្រឲ្យឈោងយឹតត្បិតស្រេកឃ្លាន ។
បេះផលពិសិស៊ីពិសា ទុំនឹកដើមថាពេជ្រអើយមាន
ផ្លែព្ទួចដូចពេលទាវនាងហ៊ាន នាងហាក់ដូចមានចិត្តចេតនា ។
៣១០. មើលមានផ្លែចន្ទន៍សិរមាន់ព្រីង ដូចទាវស្រីឈ្ងៀងនឹកសង្ស័រ
សង្ស័យស្រមៃមិនបានថា ដូចចន្ទផលាផុតចាកឆ្ងាយ ។
ស្រគំស្រគត់រលត់ធាតុ ព្រួសព្រើលមារយាទមើលយល់ស្វាយ
យល់ស្វាទាំងហ្វូងលោតប្រញាយ ព្រោះញាតិនៅឆ្ងាយចាយសម្តី ។
សម្តែងវាចាថាប្រោកដ នាវនាងទាវបទបានហេតុអ្វី
ជាបងឃ្លាឃ្លាតសង្វាតខ្វី គោគេរិលវេរបែរបែកបង់ ។
បងមើលមានផ្លែឈើទុំខ្ចី ស្វាយព្រៃស្វាយព្រាតដូចឃ្លាតស-
ង្សារសាច់ចរត្រាច់ស្មោះតម្រង់ តម្រេតក្នុងអង្គផ្គង់មិនភ្លេច ។

បងមើលគុណគាប់ប្រថាប់ផ្លែ ប្រៀបដូចទាវស្នេហ៍មិនបែរគេច ។
របស់បញ្ចាំផ្តាំទុំពេជ្រ ឥឡូវចរគ្រាច់មិនលេចព្រៃ ។

ក១៥. នៅឆ្ងាយវាលវែងចម្បែងចិត្ត ចំជាបងគិតត្បិតសត្វរៃ
សត្វរីតតែយំទុំមមៃ មមាលឧទ័យថ្ងៃល្ងាចហើយ ។

ល្ងាចហួសជ្រុលជ្រួលវង្វេងផ្លូវ ដើរពានត្រង់ត្រូវឬនៅឡើយ
នៅលង់ក្នុងព្រៃរ៉ុពេជ្រអើយ រកថ្ងបផ្អែកកើយលំហើយខ្លួន ។

ពេជ្រឆ្លើយថាអើបើដូច្នោះ យើងរកចន្លោះណាមាំមួន
ប្រយ័ត្នក្រែងមានខ្លាក្រាបពួន ខាំខ្លួនអសារជីពជន្មជាតិ ។

ដើរមកឈប់ជ្រកពុំគប្បី ព្រោះស្រីព្រួយស្រើបទើបឱហាត
ពេជ្រទុំជំនុំក៏គិតស្អាត ឡើងចង្អុរត្នោតឃ្មាតខិតខំ ។

លុះឡើងដល់មែកល្មមដេកបាន ប្រះប្រាណមិនមានព្រួយបារម្ភ
ឮសូរសត្វយំទុំសម្ងំ រៀបចំប្រុងប្រាណប្រមាណពេល ។

ក២០. ក្រឡេកក្រលៀងផ្ទៀងមើលព្រះ ចន្ទចែងភ្លឺច្បាស់រះប្រហែល
ម៉ោង១០យន់យប់យូរជ្រៅក្រែល នឹកដែលនឹកដល់ស្រងល់ងោក ។

ព្រះពាយផាយផាត់ស្ងាត់ត្រជាក់ រហើយដល់ផ្លាក់សន្សើមស្រោក
ស្រប់ស្រស់ចុះចំបំព្រំជោក ជាប់ជាំដើមធ្លកឱ្យឡោកបេង ។

សូរស័ព្ទសត្វស្រងាត់យំ ឆ្លើយគ្នាទីមទុំព្ឋល្វើយល្វេង
បណ្ឌិតពេជ្រទុំបារម្ភក្រែង ព្រួយព្រឺសង្រែងចំបែងបង់ ។

ថាឱយើងអើយមិនគប្បី ដើរដេកក្នុងព្រៃព្រួយព្រោះស-
ង្សារសត្វពន្ធព័ទ្ធរាល់រូបអង្គ តម្រង់តម្រូវមិនត្រូវច្បាប់ ។
ប្រសិនខ្លួនខ្ពស់រស់ត្រដូច ប្រសិនបើខូចខុសសណ្តាប់
មានពាក្យដំនៀលដៀលអឹងអាប់ ស៊ូស្លាប់ព្រោះស្រីអប្រិយប្រាណ ។

៣២៥. ណាព្រួយលោកត្រូយូរពេលជ្រាប ថាឯងតូចទាបផៅសន្តាន
ថាសិស្សគ្រាន់បើលោករាប់អាន ឲ្យពរស្មោះស្មានក្សាន្តព្រះទ័យ ។

ដល់លោកជ្រាបការថាឯងព្រើល ងងើលដើរដេកដោយដងព្រៃ
ស្លាប់ខ្លួនអសារក្នុងពនាល័យ ព្រះគុណនឹងភ័យស្តាយស្រណោះ ។

គ្រានោះគ្រោះជាវេលាយប់ ភ្លឺស្វាងមើលគ្រប់ឃើញប្រលោះ
ល្មមចរចាកចេរលីលាដោះ ដើរចេញចាកចុះមកដល់ដី ។

ទុំពេជ្រគេចយល់សកលឋាន ល្មមស្មានដល់ភូមិផ្ទះពីរបី
ចរចូលរកសុំបាយចំណី ស៊ីឆ្អែតដូចចិត្តចេតនា ។

ស្រេចហើយចេញចាកលាកលោកទៅ កាត់ដើរសំដៅយល់បក្សា
បក្សីឈ្មោលញីទុំរុក្ខា ទុំមានវាចាសាកសួរពេជ្រ ។

៣៣០. ថាអូនមើលសត្វច្រវាត់ទុំ មៀងមុំទីទុយហើរលលេច
លលកហើរជ្រកដើមព្រូសព្រេច ពពេចហើរគេចដើមពពូល ។

សេកយំទុំវែងចំបែងគិត ដល់ទាវឆោមស្និទ្ធមិនមិត្រមូល
មិនទាន់ដល់ទៅទាវនាងចូល ចិត្តចាំអនុកូលឬទេសោះ ។

ដូចឆ្កួតរួតរឹតខឹងខំដើរ នឿយព្រួយដំណើរប្រឹងផ្លេះផ្លោះ
ទៅដល់ទាវយល់គ្មានស្រណោះ ក្រៀមក្រោះអស់មានទេដឹងអើយ ។

ដើរទៅពីទិសនោះឆ្ពោះដល់ ដែនដងថ្នាក់ថ្នល់ជិតបង្កើយ
ក្រឡេកយល់ក្មេងហៅមិនឆ្លើយ អង្វរវាហើយណាស់នឹងស្តី ។

វានូវគូកនទាំងប៉ុន្មាន រូបប្រាណធុំក្លិនអាចម៍ក្របី ។
ទុំពេជ្រនិយាយថាវ៉ឺយវ៉ឺ អាឯងកុំភ័យនឹងអ៊ីឡើយ ។

៣៣៥. យើងចង់ជួលអាឲ្យលុយកាក់ កុំឲ្យសល់ម្នាក់ថាឲ្យហើយ
ឲ្យហ៊ានទាំងអស់ប្រុងចាំឆ្លើយ ក្មេងអើយអញសួរគួរឯងប្រាប់ ។

ក្មេងផងហើយហាថាសួរម្តេច បើចង់ដឹងកិច្ចគួរដោយច្បាស់
ដោយច្បាស់សុខចិត្តតាមសណ្តាប់ គិតខ្លាចដឹងស័ព្ទចាប់សម្តី ។
ទុំពេជ្រលោលេចមានវាចា ថាបើអាវ៉ាយើងគប្បី
ឯផ្ទះនាងទាវល្អប្រិមប្រិយ ឆ្ងាយណាស់ពិសីទើបដើរដល់ ។
ទាវមានប្តីហើយឬទេនាង ប្រាប់បងកុំវាងពិតតាមស្គាល់
ឲ្យអស់ស្មោះត្រង់តាមយោបល់ ឬលីវទេទាល់សល់ទទេ ។
ក្មេងផងសាសងប្រាប់វិញជាក់ ផ្ទះទាវបើស្នាក់នៅមានគេ
តែឆ្ងាយប្រមាណព្រះសុរិយេ ទាបទន់ជ្រៀតជ្រែទើបទៅដល់ ។
៣៤០. គាត់មានតែម្តាយមេម៉ាយស្អាត មានខ្ញុំសង្វាតខាងកុសល
ចិត្តជាអ្នកធម៌ធ្វើមគ្គផល តម្កល់ចិត្តជឿដើរទៅឆ្ងាយ ។
ទុកទាវជាកូនឲ្យទំនេរ ចាំផ្ទះឋិតថេរតែរៀងអាយ
នៅនឹងភីលៀងលេងលែបខាយ សប្បាយសងស៊ានមិនមានហ្មង ។
អើយើងជម្រាបសភាពពិត ជាញាតិឆ្ងាយជិតឬអ្នកបង
មេត្តាប្រាប់ណាំឲ្យដឹងផង បំណាងចង់ជាក់កុំអាក់អន់ ។
ទុំប្រាប់ទៅក្មេងលេងសម្តី ថាអើឯងអ៊ីយើងមកបន់
ល្បីទៅថាទាវចេះថ្នាំស្កន់ ថ្នាំស្ងូវគ្រេចក្លនកមប្រមេះ ។
ទើបអ្នកពីរប្រាណបានឮស័ព្ទ ក្មេងផងប្រាយប្រាប់ដោយសំណេះ
ខំស្រូតដល់ភូមិទុំពេជ្ររិះ ថានេះឬម្តេចពេជ្រផ្ទះទាវ ។
៣៤៥. ពេជ្រឆ្លើយទុំអើយកុំបារម្ភ កុំរួសបង្ខំក្រែងអ្នកក្រៅ
គេនឹងប្រកាន់វង្សព្រោះព្រាវ រកផ្ទះដែលនាវនាងទាវទុក ។
ត្បិតកាលយើងមកគាត់រ៉ាប់ការ ម្តាយធម៌ម្តាយអាចិថាទំនុក
សមគេសម្គាល់ចំណាំមុខ ទីសុខយើងសេពអែបរកគ្មេរ ។

និយាយគ្នាស្រេចបាច់ខំដើរ　　ពើបពានអ្នកថ្មើរទុំវេះវេរ
មិនហ៊ានស៊ើបសួរខ្លាចលោះជេរ　　វិះវេរបែរយល់ស្គាល់មិនជាក់ ។
ទើបទុំលើកហត្ថប្រណិប័តន៍សួរ　　ថាគួរមិនគួរសូមទានអ្នក
ផ្ទះហ្នឹងម្ដាយធម៌ខ្ញុំកុំលាក់　　ខ្ញុំ ធ្លាប់ពឹងពាក់សំណាក់នៅ ។
ទើបអស់អ្នកផងសាសងឆ្លើយ　　ថាអើមែនហើយចូលតាមផ្លូវ
ផ្លាច្រករបងកន្លងត្រូវ　　រួចទៅដល់ផ្ទះច្បាស់មែនហើយ ។
៣៥០. បណ្ឌិតទាំងពីរលីលាដល់　　មើលស្គាល់ប្រាកដពុំលង់ឡើយ
ហាហៅម្ដាយធម៌អរឆ្លាស់ឆ្លើយ　　កូនអើយបាត់យូរក្រមកដល់ ។
ទុំពេជ្រអរស្រេចគេចឡើងផ្ទះ　　លើកដៃសំពះឱនកាយកល់
នាងជាម្ដាយធម៌នៅជិតផ្ទាល់　　សួរសុខទុក្ខទាល់មិនសល់សព្វ ។
សួរសាកម៉ែឪនៅភូមិស្រុក　　ថាម៉ែមើលមុខមិនហ៊ានស្អប់
ទើបនាងម្ដាយធម៌ថាដូចថប់　　កូនដើមមកជ្ជប់ផ្សៀងនៅអាយ ។
ទុំឆ្លើយថាខ្ញុំសុំប្រណិប័តន៍　　ទាន់ស្វាត់ជម្រាបរៀបរាប់រាយ
ខ្លួនខ្ញុំសូមសុំឲ្យលោកម្ដាយ　　ចិត្តពុំនឿយណាយចាយសម្ដី ។
ភរភូតកុហកឡុកលាក់បាំង　　មកនេះខ្ញុំអាងត្បិតទាវស្រី
ប្ដេជ្ញាបណ្ដាមានសាក្សី　　ទន្លាប់បារីស្លាផាហ៊ុម ។
៣៥៥. យើងនឹងឈប់ស្លេះបង្អង់នៅ　　រឿងពេជ្រទុំទៅដល់ត្បូងឃ្មុំ
នឹងថ្លែងដំណើរអរជូនជំ-　　នុំនឹងភរិយាជាប្រពន្ធ ។
ថានែប្អូនស្ងួនន្ទួនខ្ចីមចិត្ត　　យើងគួរបីត្បិតបងមានបុណ្យ[1]
មានបុត្រស្រីប្រុសរបស់ធន　　បណ្ដាមបាជនជុំក្រាស់គ្រួន ។

---

១. ច្បាប់ខ្លះថា សព្វថ្ងៃនេះត្បិតយើងមានបុណ្យ ។

បងឮអស់រាស្ត្រប្រជាជាក់ និយាយមិនលាក់ដូចមាំមួន
ប្រាយប្រាប់ដោយស័ព្ទសក្តិសមសួន កូនគេផងខ្លួនដូចងួនយើង ។
នាងនោះមានម្តាយមេម៉ាយសោះ ប៉ុន្តែរបស់តាមទំនើង
មែនបានបាវព្រាវប្រើលាងជើង ថ្មីថ្មើងគ្រប់សព្វចប់ដល់ចាស់ ។
ប្រពន្ធបានស្តាប់ចាប់ចិត្តចាំ ជឿជាសួនសមមិនទាន់ច្បាស់
ជម្រាបទៅប្តីថាអម្ចាស់ ខ្ញុំស្តាប់ប្រសាសន៍លះគុំកួន ។
១៦០.ថាគិតផ្គងផ្តុំផ្សំកូនគេ ស្រែឬទន្លេដែលមានខ្លួន
ចិន្តាលោភគិតឲ្យម៉ឺនងួន ចំណាយចំនួនឆ្នាំខែថ្ងៃ ។
អរជូនជញ្ជីងរង់ចាំស្តាប់ ប្រពន្ធសាស័ព្ទនៅសង្ស័យ
ទើបគាត់ប្រាប់ថាប្អូនមាសថ្លៃ បងឮសម័យដោយប្រជា- ។
នុរាស្ត្រនរៈអ្នកប៉ុន្មាន ដែលបានមកដល់ជំនុំគ្នា
សរសើរពីរូបទាវសោភា នៅនាខាងក្បែរស្រែទេស្រី ។
នេះបើប្អូនសួនទួនខ្លីមចិត្ត យើងគួរអាណិតបុត្រភ្ញាប្រិយ
គួរយើងរិះរកនំចំណី ភោជ្យផលអ្វីៗត្រីសាច់សត្វ ។
រួចរើសរកអ្នកជាក់ចេះដឹង មែនមានជំណឹងរឿងបរមត្ថ
ស៊ុំស្ទាត់បែបបទចេះវោហារ ដែលតែងប្រសប់ធ្លាប់តែកាត់ ។
១៦៥.អធិប្បាយនិយាយខាំងថែចូវ ជាអ្នកនាំផ្លូវតាមដូនតា
ឲ្យទៅស្រដីខាងមេបា នាងទាវតើថាប្រការម្តេច ។
ប្រពន្ធអរជូនជំនួនស្រាប់ ភ្ញុំគ្នាប្រញាប់រាន់រំពេច
យកសព្វភោជ្យផលថ្កល់និងវេច រៀបរួចស្រាប់ស្រេចត្រាច់ចរចេញ ។
លីលាលយលង់ដានដងផ្លូវ ត្រូវត្រង់មាគ៌ាឃ្មាតខ្នួលខ្មាញ់
ខំស្រូតរូតរះកាត់គ្រោកគ្រាញ់ អរញ្ញវាព្រៃរំពៃយល់ ។

ក្រឡេកក្រលៀងផ្ទៀងពីអាយ ច្បាស់ជានាងម្ដាយទាវនិមល
នេះគឺមិនអ្នកដទៃទាល់ ទៅជិតទៀបស្គាល់ដល់ជាម្ដង ។
នាងនោះស្ទុះឡើងលើគ្រឹះស្ថាន ប្រមាណត្រូវមាត់ជាដន្លង
ថាអ្នកអញ្ជើញមកប៉ុនប៉ង បំណងបំណាច់ត្រាច់ទៅឆ្ងាយ ។
៣៧០. ឬមួយជាមករកយើងខ្ញុំ សូមសុំប្រសាសន៍សងរ៉ាប់រ៉ាយ
ឲ្យដឹងកិច្ចកលអធិប្បាយ ចែងចាយកុំលាក់ឲ្យឡើងមក ។
អ្នកទាំងប៉ុន្មានបានដល់ផ្ទះ ម្ដាយទាវអរណាស់ទើបរៀបស្លក
នំដាក់តុស្ពានរន្ទាន់យក ឡើងមកលើផ្ទះសំពះសួរ ។
ថាយើងខ្ញុំមកដោយចិត្តស្នេហ៍ ទទួលធុរៈគួរមិនគួរ
ទោះបីមោះហ្មងសូមលន់តួ ឆ្មើងជួដូចម្ដេចសូមមេត្តា ។
ត្បិតលោកចៅហ្វាយនូវអ្នកស្រី ទាំងពីរទាំងបីមានវាចា
ចាត់ប្រើយើងខ្ញុំនាំបណ្ណា- ការមកប្រាថ្នាចងមេត្រី ។
ប្រៀបដូចផ្ទល់ស្ពានឈានរត់ដើរ[១] សុំស្នើសុំស្នាក់អ្នកថាអ្វី
ដណ្ដឹងកូនអ្នកត្បិតឮល្បី កូនស្រីស្ដីផ្សំចំម៉ឺនងួន ។
៣៧៥. នាងជាមេម៉ាយម្ដាយទាវស្ដាប់ ចំណាប់ចំណងត្រូវចិត្តជួន
ទទួលថាអើសរសើរខ្លួន អ្នកអើយច្បាប់ក្បួនកូនកបលក្ខណ៍ ។
វិស័យសព្វថ្ងៃលំបាកដែរ គេមកហួរហែដូចឥតអាក់
ប៉ុន្តែខ្ញុំថាកូនធុរៈ ញាតិផងប៉ងស្នេហ៍មកច្រើនគ្នា ។
មិនដឹងទាន់ព្រមល្មមមេត្រី ឲ្យទៅមន្ត្រីរាស្ត្រប្រជា
ព្រោះតែយើងរាស្ត្រគួររាំងរា ឥឡូវទើបពារលើលោកធំ ។

---

១. ច្បាប់ខ្លះថា ឈានដោយស្នេហ៍ ។

ឧកញ៉ាអរជូនម្ហូបមាំពេក ធម្មតាក្រោមមេឃទាបជាងភ្នំ
មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី ។
គួរហើយខ្ញុំសុំជម្រាបញាតិ ទៅសំពះបាទលោកប្រុសស្រី
ថាបើលោកចង់ចងមេត្រី គប្បីចាំខ្ញុំលបសួរកូន ។
៣៨០. នាងអ្នកស្ដាប់ជាក់ចាំរាល់គ្នា រួចលើកភស្ដុភារជាជំនូន
ប្រគល់ម្ដាយទាវស្រេចអង្គឱន លំទោនលើកហត្ថប្រណិប័តន៍លា ។
ចរចុះវិលទៅលំនៅស្ថាន ទាំងអស់ប៉ុន្មានចរលីលា
ឡើងប្ដឹងអរជូនជុំភរិយា ចាំជាបែបបទប្រាកដណាស់ ។
វេលាក្រោយនោះចំពោះជា ម្ដាយទាវម្ទីម្នាដូចអរណាស់
ឃើញនំភ័ស្ដុផលថ្កល់តុថាស រហ័សរៀបចំសន្សំទុក ។
ហើយសួរទៅកូនថាមាសម្ដាយ សមយើងសប្បាយថ្លាវិកមុខ
ម្ដាយឲ្យទៅកូនចៅហ្វាយស្រុក បានសុខដោយបុណ្យដោយបានថ្កើង ។
អំណាចខ្លបខ្លាចមានស័ក្តិយស ចំពោះជាត្រូវបុណ្យកូនឡើង
ម្ដាយប្រាប់ប្រដៅកូនកុំឆ្មើង ចចេសចចើងណាំថ្លៃម្ដាយ ។
៣៨៥. ទាវឮម្ដាយប្រាប់ចាប់ចាំទុក ស្មើរធ្លាក់ថ្លើមក្ដុកពុំរសាយ
ទើបមានវាចាថាម៉ែអាយ ខ្ញុំកូនដូចស្ដាយបាយចំណី ។
ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី
លើកឲ្យគេទៅទោះពីរបី តាមម៉ែមេត្រីឲ្យថ្វីខ្ញុំ ។
ទទួលទទូចខ្វូចការហើយ ខុសសោះហ៊ានឆ្លើយថាម៉ែកុំ
ម៉ែមានកូនគួររៀបផ្សំផ្គុំ ឃើញលោកបុណ្យធំលើកខ្ញុំឲ្យ ។
នាងម្ដាយចាំស្ដាប់ស័ព្ទទាវឆ្លើយ ប្រាប់ថាទាវអើយគួរបណ្ដោយ
បន្ទន់អន់អត់មើលមុខក្រោយ ធ្វើខ្សោយសិនចុះកុំផ្ចញ់ផ្ចាល់ ។

គិតក្រែងបែកបាក់ធ្លាក់ថ្លោះធ្លោយ ពងមាន់មកឲ្យមានអំពល់
ប្រមៀលត្រូវថ្មល្អិតគ្មានសល់ ហ៊ានទល់ផ្ទាល់ផ្ទញ់សង្កុញខឹង ។

៣៩០. នៃទាវទំនៀមព្រេងប្រៀបស្រាប់ ថាកូនមិនស្តាប់ចចេសរឹង
លោកយកទាញមករកសន្ទឹង របឹងរបាញសាញចណ្ណាល ។

មិនដែលសោះឡើយទាវអើយនំ ប្រឡើសបើសធំម្តេចជាងនាឡិ
កូនគោកាចកៀចដោយព្រៃវាល រោលរាលឈឺខ្លួនជួនដល់ស្លាប់ ។

ស្លេះឈប់សម្តែងថែងដំណាល ម្តាយទាវរាលដាលជាលំដាប់
និយាយពីទុំនៅជុំស្រាប់ ដឹងសព្ទចាប់ព្រួយតែមួយប្រាណ ។

មួយប្រៀបឧបមាចិន្តាទុំ ជំនុំនឹងពេជ្រស្រេចស្មោះស្មាន
ថាប្អូនពេជ្រអើយយើងមកបាន សម្រាន្តយូរថ្ងៃវិស័យបង ។

ស្មើរបែកប្រមាត់ខ្ចាត់ពីរបី ទុក្ខបងបែកស្រីទាវយូរផង
មិនទាន់បានជួបនឹងនួនល្អង នេះម្តងសមឃ្លាតយូរថ្ងៃហើយ ។

៣៩៥. ពេជ្រឲ្យបងទៅឬឲ្យឈប់ ខានប៉ុន្មានយប់ទៀតពេជ្រអើយ
កុំនៅបង្អង់ឲ្យលង់ឡើយ ចូរឆ្លើយចូរឆ្លៀតសង្កេតគិត ។

ប្រសិនជាបងមិនបានទាវ ដែលនាវដល់នឹងក្ស័យជីវិត
បើបងឃើញប្រាណស្មានក្នុងចិត្ត នោះឥតកុំដឹងនឹងនៅអាយ ។

ផ្ញើអស់អង្គប្រាណលើមាសថ្លៃ វិស័យខ្លួនបងដូចទន្សាយ
បានជ្រកគុម្ពោតកំពស់ឆ្ងាយ ឱនកាយខ្វាយទុក្ខសុខតទៅ ។

ពេជ្របានស្តាប់ទុំជំនុំផង ឆ្លើយថាចូរបងទុំខ្ញុំទៅ
អ្នកឯងប្រយ័ត្នក្រែងដោយផ្លូវ សត្រូវធ្វើកលផ្តល់ផ្តាច់ជន្ម ។

កុំទុក្ខចិត្តស្រីស្តីមាយា មារយាទមួយវាចិត្តមិនធូន់
ថាយើងចង់បានធ្វើប្រពន្ធ ទំរន់រកទ្រព្យងាប់អសារ ។



៤០០. ទុំបានស្តាប់ពាក្យពេជ្រប្រដៅ ថាអើនេះហៅមានប្រាជ្ញា
តែប្អូនកុំភ័យស្រីណាៗ ទើបវាប្រាថ្នាចង់ឲ្យស្លាប់ ។
នាងទាវល្អល្អងបងស្រឡាញ់ ចិត្តមូលលើអញទើបហ៊ានភ្ជាប់
របស់បញ្ចាំផ្តាំផ្តូផ្តាប់ យើងរាប់រឿងចិត្តត្បិតទាវស្ម័គ្រ ។
លង់លុះពេជ្រទុំជំនុំស្រេច ទុំលាពេជ្រត្រាច់ចង់ជួបជាក់
ថាឱប្អូនស្ងួននួនវរល័ក្ខណ៍ នួនអ្នកភ្លេចហើយឬចាំនៅ ។
គិតហើយចេញដើរតែម្នាក់ឯង កើតទុក្ខកណ្តែងកណ្តាលផ្លូវ
លន្លង់លន្លោចខ្លោចផ្សាក្តៅ ដើរជិតទៀបទៅផ្ទះទាវស្រី ។
គ្រានោះម្តាយទាវគាត់មិននៅ ចរចេញដើរទៅមុខឆ្ងាយក្រៃ
ទុំដើរហើយឈប់ឈរសង្ស័យ ទាវឃើញថាហៃបងនោស្រី ។
៤០៥. បងទៅសួរគាត់ឲ្យបានជាក់ ក្រែងមានធុរៈមករកអ្វី
នោពួទាវប្រាប់ទៅឆាប់ខ្មី អ្នកអើយរកអ្វីអញ្ជើញមក ។
ទុំស្តាប់សាស័ព្ទនៅសម្ងំ ឮនោហៅចំទើបទុំក្រោក
ឈានឡើងលើផ្ទះហើយនោភ្ញក សួរថាអ្នកមករកការអ្វី ។
ទុំស្តាប់សាស័ព្ទពាក្យនោសួរ ទុំប្រាប់ដោយគួរជាមេត្រី
បងមករកទាវទេណាស្រី ត្បិតនាងទាវស្រីស្តីសញ្ញា ។
នោឆ្លើយអ្នកអើយគួរពិភាល់ ប្អូនខ្វល់ឆ្ងល់ឆ្ងាយក្នុងចិន្តា
ទុំថាឆ្ងល់អ្វីកុំសង្កា បានមើលសាស្ត្រាស្នូត្រឲ្យស្តាប់ ។
ឥឡូវធ្វើឆ្មើងថាមិនស្គាល់ មានជាបន្ទាល់នៅដៃស្រាប់
ប្រាថ្នាមានឈ្នួតនិងដន្លាប់ ឲ្យបងសឹកឆាប់កុំយូរឡើយ ។
៤១០. ទាវឮពាក្យទុំថាដូច្នោះ ព្រឺព្រួចពុងពោះពុំមានស្បើយ
បើកទ្វារចេញមកថាលោកអើយ ហ៊ានយកឈ្នួតហើយជាបន្ទាល់ ។

នរណាផ្ដាំថានឹងឈ្នះទៅ ឲ្យអ្នកមកកួរនាំកង្វល់
ទុំថាបើបានតែដៃដល់ ប្រាប់មិនឲ្យឆ្ងល់សល់សេចក្ដី ។

ទាវថានរណាបានប្ដេជ្ញា កោតតែវាចាហ៊ានស្រដី
ចូរអ្នកវិលទៅលំនៅខ្មី កុំនៅធ្វើអ្វីឃើញពុំជា ។

ទុំថានរណាគេនឹងឆោត វិលទៅវិញសោតឲ្យឃ្លាតឃ្លា
នៅទាល់តែបានកែវពុំងា មូលមួយផងគ្នាមិនបែកបង់ ។

ខ្លួនប្អូនសព្វថ្ងៃប្រៀបដូចផ្កា ឯអ្នកឧបមាដូចកន្លង់
ហើររកឃើញផ្កាចូលត្រីបត្រង់ រួចមិនបង្អង់ត្រាច់លីលា ។

៤១៩. ទុំថាខ្លួនបងដូចរាជសីហ៍ ខ្លួននាងទាវស្រីដូចគុហា
រាជសីហ៍បើបានលំនៅជា មិនឲ្យឃ្លាតឃ្លាគុហាឡើយ ។

ទាវថាខ្លួនប្អូនដូចកំពង់ ខ្លួនអ្នកឆោមយង់ដូចទូកហើយ
ចាប់ចតអាស្រ័យអ្នកថ្លៃអើយ ចេញទៅកន្តើយមិននឹកនា ។

ទុំថាឱបងដូចត្រីធំ ខ្លួនទាវក្រមុំដូចគង្គា
ត្រីបានទឹកជ្រៅហែលវេរា កុំកែវពុំងាគិតសង្ស័យ ។

ទាវថាខ្លួនប្អូនដូចព្រឹក្សា អ្នកដូចសារិកាទំសព្វថ្ងៃ
ចតជាទ្រនំទំអាស្រ័យ ហើយហើរច្រៀងព្រៃទៅទីទៃ ។

ទុំថាខ្លួនបងប្រៀបដូចខ្លា ខ្លួនកែវកនិដ្ឋាប្រៀបដូចព្រៃ
ធម្មតាសត្វខ្លាមិនវិលវៃ ចៀសចេញចោលព្រៃណាំថ្លៃបង ។

៤២០. ខ្លួនប្អូនដូចឈើជាបង្គង ខ្លួនអ្នកប្រុសឈ្មងដូចឃ្មុំផង
មកទំធ្វើសាំហើរជាម្ដង ឈើសោតសៅហ្មងអសារនៅ ។

ទុំថាខ្លួនបងដូចដង្វី ខ្លួនប្អូនស្រស់ស្រីដូចអំពៅ
ដង្វីបានផ្អែមមិនដែលទៅ ឆ្ងាយពីអំពៅណាំអូនណាំ ។

ទាវថាឱះឱអ្នកថ្លៃអើយ នរណាដោយហើយកុំសង្កា
ពាក្យប្រុសភូតព្រាងអាងប្រាជ្ញា កុំណាំខ្ញុំថាកុំសង្ស័យ ។
ទាវមានវោហារប្រាជ្ញាដោះ ទុំគ្មានខ្លាចសោះចូលចាប់ដៃ
ថើបថៃថានែអ្នកមាសថ្លៃ នៅតែសង្ស័យមិនជឿចិត្ត ។
ទាវខឹងក្រញឹងឥតកោតក្រែង ចាប់ដៃកំហែងគ្មានអាណិត
នឹកទៅគួរក្នាញ់ម្នេញមិនស្និត កោតចិត្តហៅហានរុករានព្រៃ ។
៤២៥. ហ៊ានមកថើបថ្ពាល់ពាល់ដល់ដោះ ចិត្តគ្មានក្រែងសោះមិនខបថៃ
ទុំថាបើខុសសុំឲ្យថ្លៃ ស្រឡាញ់យូរថ្ងៃឥតឧបមា ។
នាងនោភីលៀងដឹងសេចក្តី ចរចុះចេញខ្ចីមិនមានថា
ក្រែងទាវអន់អៀនក្នុងកាយា ចិន្តាទាវព្រមល្មមបេតី ។
ទុំឱបបីបមថ្នមប្រឡែង ទាំងពីរឥតក្រែងរួមមេត្រី
នៅក្នុងគ្រឹះស្ថានក្សាន្តដូចក្តី ស្រស់ស្រីស្រួលស្រើបដោយតណ្ហា ។
ទាវស្រួលទទួលព្រមចូលជិត ទុំសោតស្នេហ៍ស្និទ្ធថើបភ័ក្ត្រា
ទាំងពីរហ៊ានស្បថប្រាកដថា ខ្ទាក់ស្លាប្តូរគ្នារួចទាវឆ្លើយ ។
អ្នកថ្លៃប្អូនអើយក្រែងអ្នកបង បានរួមស្នេហ៍ស្នងនៅកៀកកើយ
ចេញចាកចោលប្អូនទេដឹងអើយ អ្នកអើយអាសូរចិត្តប្អូនវ៉ា ។
៤៣០. ទុំថើបល្អួងលោមថ្លៃនួនល្អង ថាឱមាសបងដួងជីវា
បងមិនដោះដៃចោលកនិដ្ឋា បងផ្ញើអាត្មាអស់ជន្មជីព ។
ត្បិតប្អូនមានគុណប្រៀបដូចភ្នំ សុមេរុធារធំសង្កត់ទ្វីប
ខ្លួនបងធៀបដូចកលសូត្រីព ជន្មជីពផ្ញើលើព្រះរាមា ។
ទាវថាខ្លួនប្អូនដូចតារា ប្រុសថ្លៃស្នេហាដូចចន្ទ្រា
តារារះរាយលើមេឃា អមអង្គចន្ទ្រាមិនមានឃ្លាត ។

បងអើយយប់ហើយចូលសយនា ស្និទ្ធស្នាលស្នេហាលុះអធ្រាត្រ
ទុំសុំប្រាថ្នាជួបសព្វជាតិ ពុំឃ្លាតពុំឃ្លៀងរៀងតទៅ ។
ថ្លាថ្លែងពីនាងម្ដាយទាវវិញ មកពីបុណ្យ[1] វិញដល់លំនៅ
ទាវសោតបានដឹងដំណឹងកូវ ឲ្យទុំចេញក្រៅរួសជាម្ដង ។
៤៣៩. ពាក្យពេចន៍បានមត់នឹងនោគ្រប់ ទាវនៅក្នុងម្លប់ឥតមានហ្មង
ម្ដាយទាវមកដល់ផ្ទះដូចប៉ង ខ្ញុំប្រុសស្រីផងចូលមកដល់ ។
ម្ដាយទាវឃើញទុំទៅសួរថា អ្នកមកពីណាគួរពិភាល់
ទុំថាខ្ញុំមកពីឆ្ងាយសល់ ទើបដល់វេលានាថ្ងៃមិញ ។
ម្ដាយទាវសួរទុំចង់ដឹងដាន ថានៅប៉ុន្មានថ្ងៃវិលវិញ
ទុំថាខ្ញុំមកដើររកទិញ ទំនិញគោសេះស្លេះរំខាន ។
ត្បិតមកពីឆ្ងាយគ្នាពីរនាក់ ឲ្យនៅសំណាក់ក្នុងគ្រឹះស្ថាន
ផ្ទះគេចំណាំធ្លាប់រាប់អាន ពីដើមខ្ញុំបានស្មូត្រឲ្យស្ដាប់ ។
ម្ដាយទាវដឹងជាក់ហាក់ដូចស្រួល ទទួលឲ្យនៅហើយប្រាយប្រាប់
អ្នកកូននៅចុះទោះយូរឆាប់ ទំនួលទុំស្រោប់អរឥតក្រែង ។
៤៤០. ម្ដាយទាវសោតរៀបកន្ទេលខ្នើយ បម្រុងឲ្យហើយរួចចារចែង
អ្នកកូនដេកនៅទីកន្លែង យើងតែងរៀបទុកឲ្យអ្នកថ្លៃ ។
កាលនោះឯទុំឆោមពិសី នៅនឹងទាវស្រីរួមភិសម័យ
តាមដោយចិត្តគាប់បទអាល័យ យូរថ្ងៃមិនឲ្យគេដឹងដាន ។
ទុំភ្លេចភូមិស្រុកមិននឹកនា ពេជ្រប្អូនពុំងាជាពីរប្រាណ
ឥតមានទុច្ចរិតរឹតរំខាន សុខទុក្ខស្មគ្រស្មានតែពីរនាក់ ។

---

១. ច្បាប់ខ្លះថា មកពីក្រៅ ។

គ្រាក្រោយថ្លាថ្លែងពីម៉ឺនងួន	កូនលោកអរជូនមានមាសប្រាក់
យកមកផ្គាប់ផ្គុនទាវវរលក្ខណ៍	ប្រមាណ[1] ទាវស្ម័គ្រស្មោះនឹងខ្លួន ។
មិនដឹងកលកិច្ចគេឧបាយ	ទាវមានសហាយទេម៉ឺនងួន
សរសើរគេថាហៃប្អូនស្ងួន	នាងនួនល្អដាច់ស្រេចផែនដី ។
៤៤៥. ប្រសិនស្ងួនព្រមល្មមចិន្តា	បងថ្កមកនិជ្ជារួមមេត្រី
មិនឲ្យមានមួយជាពីរបី	បងថ្កមប្អូនស្រីកែវចរណៃ ។
ម៉ឺនងួនទៅមកមិនហ៊ានខាន	ម្តាយទាវរាប់អានស្រឡាញ់ក្រៃ
នាងទាវមិនស្បិតឥតសង្ស័យ	ទាវថប់វិស័យពុំស្រដី ។
រីឯដំណើរអំបាលនេះ	នឹងបញ្ឈប់ស្លេះទុកសិនខ្មី
ថ្លាថ្លែងពីអង្គព្រះចក្រី	ស្តេចគង់បុរីរដ្ឋរាជស្ថាន ។
ស្តេចគង់នគរកម្ពុជា	ឈ្មោះព្រះរាមារឹទ្ធិថ្កើងថ្កាន
អស់រាស្ត្រប្រជាសឹងសុខសាន្ត	រាជស្ថានស្តេចគង់បន្ទាយលង្វែក ។
មានវាំងដំណាក់ទីប្រាសាទ	ប្រសើរស្អាងស្អាតខ្ពស់អនេក
រោងរ័ត្ន[2] រោងរាំរបាំឯក	ល្អប្លែកបីដូចស្ថានសួគ៌ា ។
៤៥០. ស្តេចមានព្រះអគ្គមហេសី	រូបឆោមប្រិមប្រិយល្អសោភា
គ្រប់លក្ខណ៍ល្មសល្មន់ឥតគណនា	មិនមានរោគាព្យាធិអ្វី ។
ជុំញាតិវង្សាវង្សាវតារ[3]	អស់ទាំងសេនាមុខមន្ត្រី
ជាទីសំរាប់បុណ្យបារមី	គាល់អង្គចក្រីស្តេចរាមា ។

---

១. ច្បាប់ខ្លះថា ស្មានថា ... ។

២. ច្បាប់ខ្លះថា រោងរដ្ឋ ។

៣. ច្បាប់ខ្លះថា ជួបជុំព្រះញាតិវង្សា ។

មានរោងរាជយានអស្សតរ រាជរថបវរគជេន្ទ្រា
មានទីគ្រឿងល្បែងឥតគណនា សឹងនាំទ្រព្យាជាដង្វាយ ។
កាលនោះល្បីឈ្មោះបណ្ឌិតទុំ នៅខែត្រត្បូងឃ្មុំប្រុសប្រាជ្ញប្រាយ
ចេះច្រៀងឆ្លាស់រឿងសុសសព្វសាយ ក្នុងដែនដីអាយប្រៀបពុំបាន ។
មួយទៀតមានឈ្មោះបណ្ឌិតពេជ្រ ជាស្រេចចេះភ្លេងល្បែងប៉ុន្មាន
ឮល្បីឈ្មោះអ្នកទាំងពីរប្រាណ ក្សត្រក្សាន្តទ្រង់មានរាជឱង្ការ ។
៤៥៩. ស្ដេចត្រាស់បង្គាប់ឲ្យទៅយក ទុំនិងពេជ្រមកថ្វាយក្សត្រា
ចាត់រាជបម្រើតាមរាជការ ដោយព្រះចិន្ដាទ្រង់ប្រញាប់ ។
បម្រើឱនអង្គផ្ទង់កាមា ទទួលឱង្ការលាក្រឡាប់
ខំស្រូតរូតដល់កំពង់ឆាប់ ដល់អរជូនស្ដាប់ព្រះឱង្ការ ។
អរជូនទទួលទុកសិរី ចាត់បម្រើឱ្យចរយាត្រា
ទៅយកពេជ្រទុំឲ្យរួសរ៉ា ដូចបន្ទូលថាទ្រង់បង្គាប់ ។
យកទុំនិងពេជ្របានមកដល់ ឡើងគាល់អរជូនឱនគំនាប់
អរជូនប្រាប់ថាក្សត្រាសព្វ បង្គាប់បញ្ជូនខ្លួនទៅថ្វាយ ។
ពេជ្រទុំបង្គំឥតប្រកែក ថាទៅថ្ងៃស្អែករិះខ្វល់ខ្វាយ
រករៀបប្រដាប់សម្រាប់កាយ ចៅហ្វាយមេត្តាត្រាប្រណី ។
៤៦០. បម្រើពីហ្លួងថាអាណិត យើងនេះតាមចិត្តឥតថាអ្វី
ប៉ុន្តែអ្នករួសឲ្យឆាប់ខ្មី ត្បិតព្រះចក្រីត្រាស់បង្គាប់ ។
គ្រានោះបណ្ឌិតទុំនិងពេជ្រ ដឹងច្បាស់រឿងស្រេចវិលលីលាប់
លាកលាអរជូនវិលត្រឡប់ ថ្លែងសព្វដំណើរប្រាប់ទាវស្រី ។
ទាវអើយត្បិតមានព្រះតម្រាស់ ប្រាកដជាក់ច្បាស់ពីចក្រី
ឲ្យយកខ្លួនបងទៅឆាប់ខ្មី បងសូមលាស្រីថ្លៃឧត្ដម ។

ទាវឆ្លើយថាឱអ្នកថ្លៃអើយ   ទុក្ខប្អូនឥតស្បើយរឹងក្រៀមក្រំ
ប្អូនទប់មិនបានក្សាន្តទ្រទ្រាំ   ទុក្ខមាំក្នុងខ្លួនប្អូនមិនស្បើយ ។
ទុំថាឱថ្លៃនឹមនួនល្អង   សព្វថ្ងៃបានបងនៅកៀកកើយ
ពីនេះទៅស្អែកបែកគ្នាហើយ   ទាវអើយប្អូននៅកុំទុក្ខា ។
៤៦៥. ទាវថាឱទុក្ខប្អូនខ្លាំងម្ល៉េះ   មិនមានរបេះទៅត្រង់ណា
ប្អូនប្រាសប្រុសថ្លៃថ្លើមសង្សារ   ទាវខំប្រវារៀបផ្គូផ្គង ។
សំពត់ស្លាម្លូម្ជូរបារី   រៀបដាក់ហិបថ្មីឲ្យទុំផង
រួចទាវផ្ដែផ្ដាំថាអ្នកបង   ទៅហើយវិលផ្គងឆាប់រួសរ៉ា ។
វិលមកយកប្អូនណាំអ្នកថ្លៃ   ប្អូននៅក្រំក្ស័យបង់អសារ
ទុំថ្នមបីបមថើបភ័ក្ត្រា   ប្រវាឱបទាវកែវកល្យាណ ។
លង់លុះព្រឹកព្រាងស្វាងឡើងជាក់   តែងតួស្លៀកពាក់ចរចេញថ្កាន
បម្រើពីហ្លួងក៏ស្មោះស្មាន   បណ្ឌិតពីរប្រាណត្រាច់យាត្រា ។
ទុំគិតពិនិត្យជម្រាបទៅ   ខ្ញុំនេះឥឡូវសុំមេត្តា[1]
ជូនទៅបាភ្នំសួរមាតា   នូវគ្រូអាចារ្យមាមីងផង ។
៤៧០. បម្រើស្ដាប់ហើយមិនមានខាន   ថាជូនទៅបានដូចបំណង
ឲ្យបានលាម្ដាយនូវរៀមច្បង   ចរចេញត្រសងមិនសង្ស័យ
រួចដើរកាត់ព្រៃខែត្រត្បូងឃ្មុំ   ស្ដាប់សត្វយាសយំទុំអាស្រ័យ
ឈ្មោលញីទាំងពីរយំច្រៀងព្រៃ   ស្រមៃដូចទាវនៅនែបនិត្យ ។
ទុំថាឱទាវនឹមនួនល្អង   ថ្ងៃនេះអញបងឃ្លាឃ្លាតពិត
មិនបានរួមស្ពានដួងជីវិត   ម្ល៉េះសមឆោមស្និទ្ធនៅកំព្រា ។

---

១. ច្បាប់ខ្លះថា ទុំប្រាប់បម្រើដ៏ជាធំ ថាខ្ញុំនេះសុំលោកមេត្តា។

ដើរហើយពុំស្បើយរឹងចង្អៀត    ខំឆ្លៀតរំពៃក្នុងអធ្វា
ទុំរាប់ដើមឈើផងនានា    ដុះខាងមាគ៌ាជាជួរជ្រំ ។

មើលមានជ្រៃជ្រែសង្កែថ្វាន់    ត្រៀលត្រស់ក្រវាន់គុយស្រគំ
ស្រឡីស្រឡៅក្របៅក្ទម្ព    ទ្រនំអារអូជ្ជចង្អូរត្មាត ។

៤៧៥. ដង្កោទ្រយឹងខ្ទឹងក្រសាំង    អំពិលភ្លងភ្លាំងទាំងភ្លូបាត
គូលែនទុរេនមៀនលាំងសាត    មាក់បាតបង្គោញ្ញៅចាន់ចារ ។

ត្របែកត្រសេកអំបែងថ្ងៃ    អង្គ្រងស្មាច់ស្មែរោគរកា
ក្រូចក្រាយស្វាតស្វាយត្រាចត្រៀលស្វា    សេដាសណ្តាន់ថ្លាន់ជ្រែជ្រៃ ។

មានទាំងដកពាយវាយដកព    សង្ឃ័រពង្ររាក់រាំងស្មី
ភ្នំភ្នែងផ្កែស្រែងលោតលាំងដៃ    សន្ទៃក្រខុបងប់ក្រឡាញ់ ។

ច្រមាស[1] បុស្សនាគច្រកែងទួយ    ប្រផេញគោមួយឈើទាលត្រាញ់
រាជផ្តិសធ្មេញត្រីរៃអញ្ចាញ    អង្កាញ់អង្កោលកណ្តោលបាត ។

ត្រាចត្រៀកចង្រៀកច្រេសខ្ទឹមក្ទម្ព    គគីរវាំងភ្នំបេងបាយម៉ាត
ស្តុកស្តុរស្តិស្តៅត្រាវក្តួចក្តាត    លាំងសាតសត្បារកាស្រល់ ។

៤៨០. ទុំដើរក្នុងព្រៃរំពៃសត្វ    ស្រងូតស្រងាត់ក្នុងចិត្តសល់
វិតក្កក្នុងកាយគិតខ្វាយខ្វល់    នឹកដល់ទាវស្រីមិនមានស្បើយ ។

ទុំមៀងមើលយល់ផលបុប្ផា    ហើយសរសើរថាឱផ្កាអើយ
ផ្កាដុះនៅនិត្យជិតបង្កើយ    ពិដោរមកហើយក្លិនថ្មីៗ ។

ពិដោរផលាផ្កាកំភ្លឹង    ដូចបងនែបនឹងទាវពិសី
ពិដោរបុប្ផាផ្កាចំប៉ី    ដូចបងនែបស្រីទាវឥតហ្មង ។

---

១. ច្បាប់ខ្លះថា កប្បាស ។

ចម្ប៉ាចំពើបទើបជួបគ្នា ឥឡូវឃ្លាតឃ្លាទាវនួនល្អង
រំដួលអន់អួលពេកកន្លង ចិត្តបងអាល័យថ្លៃកនិដ្ឋា ។
ឱបងពិដោរផ្កាក្រវាន់ ដូចក្លិនទាវស្បាន់ជិតកាយា
ពិដោរថ្មីៗដូចក្លិនផ្កា ជាប់នៅជាយផាហ៊ុមក្រវាត់ ។
៤៨៥. ដើរដោយវាលវែងត្រែងដុះត្រា ទន់ទាបសុរិយាយាត្រាកាត់
មៀងមើលមេឃមីរពពកសាត់ ដូចកលបងខ្ចាត់ពីទាវមក ។
កន្លង់ក្រឡឹងផ្កាក្រឡាញ់ ដូចខ្លួនអង្គអញត្រាច់ដើររក
ពពេចពពូលហើរចូលជ្រក ដូចអង្គអញមកនៅរួមកាយ ។
គ្រលីងគ្រលោងគ្រលែងវែក ក្រឡុះហើរបែកគូហ្វូងហ្វាយ
ដូចបុងបែកទាវថ្លៃឆោមឆាយ មកដល់ឋានអាយអង្គឯកា ។
ឱបងស្រណោះសត្វតាវៅ យំក្នុងព្រៃជ្រៅសព្ទភាសា
ហាក់មាត់ទាវស្ងួននួនកនិដ្ឋា ចរចាសាសងបងស្រមៃ ។
ត្រយងយំឆ្លងឆ្លើយគូវា ហើរហើយបែកគ្នានៅច្រៀវព្រៃ
ដូចខ្លួនអង្គអញបែកទាវថ្លៃ យូរថ្ងៃពុំសុខទុក្ខឥតស្បើយ ។
៤៩០. បងស្តាប់សូរស័ព្ទរៃកណ្តឹង មាន់ព្រៃប្រប្រឹងរងាវឆ្លើយ
បងនឹករលឹកទាវទៀតហើយ ទាវអើយសមស្ងួននួនកំព្រា ។
ដើរដោយព្រៃជ្រងរំលងជ្រៅ ទទាហើយទៅទំទីមគ្នា
ត្រសិតត្រសងហើររេរា សេកនាំគូវាសសៀរទំ ។
សារិកាស្រែករកគូសប្បាយ ហើរឆ្ងាយនាំញីស៊ីស្រគំ
សព្វសត្វច្រវាត់ក្នុងព្រៃភ្នំ យាសយំឆ្លើយឆ្លងសងសម័យ ។
ថ្លាថ្លែងសម្តែងទុំនិងពេជ្រ ខំស្រូតដើរត្រាច់ទាំងយប់ថ្ងៃ
បានដល់ភូមិស្រុកទុក្ខអាល័យ ជួបម្តាយប្រស្រ័យសួរទៅមក ។

ទុំបានសាស័ព្ទប្រាប់ម្តាយថា ខ្ញុំកូនមានការស្តេចឲ្យយក
ខ្លួនខ្ញុំនិងពេជ្របួនពន្លក ទ្រង់ភ្នកហាឫទ័យល្បីទៅដល់ ។

៤៩៥. ជាអ្នកចម្រៀង[១] ល្បែងល្បីល្បាយ ហេតុនេះលោកម្តាយសុំតម្កល់
កុំអាក់កុំអន់កុំឲ្យសល់ ស្តេចស្គាល់ក្រមានក្នុងឋានអាយ ។

នាងម្តាយទុំស្តាប់សព្ទសម្តី កូនប្រាប់គប្បីអ្នកមាសម្តាយ
បើកូនអ្នកទៅប្រយ័ត្នកាយ ចូរថ្វាយខ្លួនអ្នកឲ្យជាក់ស្តែង ។

កុំបាធ្វេសធ្វេសប្រហែសខ្លួន កុំឃើញស្រីយួនពួនប្រឡែង
ប្រយ័ត្នកំចាត់នៅខាងល្បែង ខំស្វែងខំស្វះលះពីអាយ ។

ទុំក្រាបប្រណិប័តន៍ហត្ថសំពះ លាម្តាយរហ័សទាំងពីរកាយ
ដើរទៅដល់វត្តប្រាកដថ្វាយ បង្គំរ៉ាប់រ៉ាយដំណើរប្រាណ ។

ឱនអង្គក្រួញក្រាបទាំងពីរនាក់ លោកគ្រូស្មោះស្ម័គ្រព្រះទ័យក្សាន្ត
មានពុទ្ធដីកាសួរចង់ដឹងដាន ទុំសោតទូលថ្កានមិនមានល្អៀង ។

៥០០. ទូលថាស្តេចចាត់បម្រើមក ដល់ហើយរើសយកជាចម្រៀង
ទៅគាល់បម្រើជាភីលៀង គ្រូផ្ទៀងស្តាប់ជាក់ភ្ញាក់ស្មារតី ។

ពុទ្ធដីកាថាអើបម្រើក្សត្រ យប់ថ្ងៃប្រយ័ត្នខ្លួនកុំបី
កុំបាចូលចិត្តស្និទ្ធនឹងស្រី ខ្លាចអង្គចក្រីយកទោសា ។

បានចូលគាល់ក្សត្រប្រយ័ត្នប្រាណ ដំណេកទីឋានអង្គក្សត្រា
កុំចូលពេលស្ងាត់ប្រយ័ត្នការណ៍[២] គាល់អង្គក្សត្រាព្រះបពិត្រ ។

កុំបាប្រកួតនឹងចេស្តា ខ្លាចបារមីតាព្រះទ្រង់រិទ្ធិ
ព្រះអគ្គមហេសីកុំទៅជិត និងបង់ជីវិតពីព្រោះស្រី ។

---

១. ច្បាប់ខ្លះថា កូនចេះច្រៀង... ។

២. ច្បាប់ខ្លះថា ណាំអ្នកណាំ ។

ពេជ្រទុំប្រណម្យស្តាប់ពុទ្ធដីកា ក្រួញក្រាបហត្ថាដាក់សិរសី
បង្គំលាគ្រូចរចុះដី ចេញចាកឃ្មាតខ្មីចាំពុទ្ធដីកា ។

បំរើពីហ្លួងទាំងពួងនាំ ទុំពេជ្ររៀបចំចរយាត្រា
ដើរដល់កំពង់រង់ត្បិតថា ដោយនូវអាជ្ញារួសឆាប់វៃ

ចុះទូកចែវតាមទឹកទន្លេ ទុំគិតគ្នាន់គ្នេរិះរំពៃ
លង់លុះសុរិយាទៀបបាំងព្រៃ ទុំនឹកសន្លៃអន់អួលផ្សា ។

ដំណើរទុំទុកស្នេះបង្អង់ ថ្លែងទៅទាវផ្ចង់ប្រុងអាត្មា
តាំងពីទុំឃ្លាតឃ្លាកាលណា ទាវកើតទុក្ខាពុំមានក្សាន្ត ។

ចំណីបាយទឹកមិននឹកនា សាច់ជ្រួកមាន់ទាពោរពេញចាន
សល់នៅគ្រៀមផ្អសស៊ីមិនបាន រំខានវិយោគសោយសោកា ។

ទាវថាឱះឱប្រុសខ្លីមចិត្ត ប្អូនធ្លាប់ស្គាលស្និទ្ធរួមស្នេហា
ឥឡូវឃ្លាឃ្លាតរៀមភស្តា ចិន្តាប្អូនទ្រាំក្រំមិនស្បើយ ។

នាងនោល្អួងលោមឃាត់ទាវថា កុំសោយសោកាណាំថ្លៃអើយ
យូរឆាប់គង់ជួបពុំលែងឡើយ ទាវអើយបងឃាត់អត់កំសាន្ត ។

ទាវស្តាប់នោប្រាប់សព្វសេចក្តី រសាយទុក្ខខ្មីគ្រាន់ស្រាកស្រាន្ត
នោនាំទាវស្រីចរចូលថ្កាន សម្រាន្តលង់លក់លើសយនា ។

ដំណើរទាវទុំបង្អង់នៅ និយាយតទៅទុំទុក្ខា
ចែវទូកស្រូតរូតតាមគង្គា មៀងមើលមច្ឆាហែលរហង់ ។

រស់ឆ្តោកាហោរាជរាហូ ព្រួលប្រាទីពោព្រួយកន្លង់
ដរីក្អិតក្អឹប្ញស្សីច- ង្វាភ្លៀងរហង់រហ័សហែល ។

សណ្តាយក្រុសក្រាយឆ្កិនច្រកែង ផ្ទក់ក្រាញ់អណ្តែងច្រើនក្រាស់ក្រែល
សរសៃកំពតផ្សោតប្របែល ផុសផែលផុលផុងក្នុងគង្គា ។

៥១៩. ផ្លូញស្លាតសង្វាតសៀវសៀតក្បែរ ច្រកែងកែសកែត្រំគជ្រា
ប៉្លាម៉ាប៉ាមូចូលរេរា រ្វងរាមនាំគ្នាហែលត្រសង ។
ព្រលឹតដុះជិតដើមត្រកៀត ត្រកួនដុះបៀតដូចអង្គបង
ត្រកៀតដុះបៀតដូចនួនល្អង ត្រកួនដូចបងត្រកងបី ។
ព្រលូងពាំផ្កាព្រលឹតលង ទំនងដូចបងប្រឡែងស្រី
ឥឡូវនិរាសប្រាសចេញខ្ចី ម្លេះហើយសមបីទន្ទឹងផ្លូវ ។
យើងនឹងថ្លែងស្រូតរូតសាសព្វ មិនមានរៀបរាប់ផ្តាប់តម្រូវ
ថ្លែងកាលថែវទូកលឿនដល់ទៅ ចាប់ចតឈប់នៅកំពង់ហ្លួង ។
ឡើងដើរមៀងមើលអស់ទំនិញ អង្គុយលក់ទិញហូលផាមួង
គ្រប់សាសន៍គ្រប់សែខ្មែរទាំងពួង រួចមុខក្រសួងនាំរួសរ៉ៃ ។
៥២០. ទៅដល់ជើងវាំងអង្គក្សត្រា បម្រើនាំសារថ្វាយចក្រី
នាំទុំ និងពេជ្រស្រេចឥតបី ដល់ក្សត្រនរបតីអង្គឥស្សរា[1] ។
កាលអើយកាលនោះព្រះចមពង្ស ក្សត្រាស្តេចទ្រង់ព្រះបញ្ញា
បង្គាប់អស់ក្រុមមុខបណ្តា ត្រូវការរៀបចំឲ្យទុំច្រៀង ។
ក្រុមការរៀបរួចស្រេចសព្វគ្រប់ ចូលទូលចមភពមិនមានល្អៀង
ស្តេចរៀបស្រីស្នំក្រុមភីលៀង អង្គុយគាល់រៀងតាមលំដាប់ ។
បណ្ឌិតពេជ្រទុំផ្គុំហត្ថា ដាក់លើសិរសាប្រវាចាប់
ចាប៉ីសាដៀងដេញប្រញាប់ ទុំស្រែកសាស័ព្ទសងឆ្លងឆ្លើយ ។
ព្រះគុណប្រកបមានតេជះ តបៈបារមីឥតស្មើឡើយ
ទ្រង់មានចិន្តាត្រាស់ទៅហើយ ម្ចាស់អើយទ្រង់ភ្ញកយកខ្លួនខ្ញុំ ។

---

១. ច្បាប់ខ្លះថា រាមា ។

៥២៥. ជាអ្នកចម្រៀងច្រៀងប្រការ    ប្រកបចេស្ដាប្រោសសូមសុំ
ទោះទោសឆ្ពាំឆ្គងហ្មងពិតពុំ    ត្រឹមត្រូវត្បិតក្រុមជំនុំក្រៅ ។
ស្រែស្រុកខែត្រខ័ណ្ឌខាងត្បូងឃុំ    ចូលមកបង្គំច្រើនល្ងង់ខ្លៅ
ទ្រង់ប្រោសប្រណីសេចក្ដីនៅ    ខ្លួនក្មេងក្រែងហៅដៅដល់អង្គ ។
មិនមានរអែងក្រែងចេស្ដា    សូមទ្រង់មេត្តាប្រោសស្រោចស្រង់
គង់កើតជាខ្ញុំក្រុមក្រោមល្អង-    ធូលីទ្រង់សង្គ្រោះប្រោសប្រាណ ។
ស្ដេចទ្រង់សំរួលស្រួលព្រះទ័យ    ទុំអើយគប្បីអញគិតស្មាន
ថាឯងមិនផេះក្នុងជើងក្រាន    បើម្លេះសមខានមិនបានទៅ ។
ស្រុកភូមិទេតើទុំកុំភ័យ    កុំគិតនឹកអ្វីចូរឯងនៅ
អញឲ្យរបស់យសស័ក្តិត្រូវ    ទុំឯងឲ្យហៅថាម៉ឺនឯក ។
៥៣០. ម៉ឺនឯកចែកឈ្មោះយសស័ក្តិថ្មី    ស្ដេចទ្រង់ប្រណីខ្លាំងអនេក
នៅយឺតយូរថ្ងៃវិស័យបែក    ទុំភ្ញាក់សង្វេគសង្វែងបង់ ។
នឹកទាវទៀតទុក្ខមុខក្រៀមក្រំ    ទោមនស្សបារម្ភប្រាថ្នាត្រង់
ឲ្យជួបទាវស្រីជាសាច់ស -    ង្សារសូមព្រះអង្គទ្រង់ប្រោសប្រាណ ។
កាលអើយកាលនោះព្រះទ្រង់យស    បុណ្យខ្ពស់ចក្រពង្សទ្រង់កំសាន្ត
ភ្ញាក់ក្នុងព្រះទ័យវៃស្មោះស្មាន    ឱង្ការឈ្វេងយល់ដល់សង្សារ ។
នៅនគរកម្ពុជានាដែនភព    ខេត្តខណ្ឌគ្រាន់គ្រប់រាជសីមា
អញចង់ចាត់រកយកស្រីណា    មានលក្ខណាជាមហេសី ។
ស្រីចិនយួនចាមតាមសក្ដា    កុំថាតាមអញសព្វព្រះទ័យ
ទោះខ្មែរស្រុកស្រែចំការក្ដី    រួសរៃកុំបីគិតកោតក្រែង ។

៥៣៥. ទ្រង់មានចិន្តាកាលណាឈប់[1] ស្ដេចត្រាស់បង្គាប់ជៀងជាក់ស្ដែង
ឲ្យហៅកុងរ៉ូយបតីតែង បន្ទូលចាត់ចែងរើសមហេសី ។
សេនាចាត់ការតាមដោយហេតុ ចេញទៅគ្រប់ខែត្រឯកទោត្រី
បម្រើនាំសារក្នុងបុរី ចាមចិនខ្មែរក្ដីមន្ត្រីរាស្ត្រ ។
ខ្លះចេញទៅទ្រាំងខេត្តខាងក្រោម ភូមិកំពង់សោមបន្ទាយមាស
បាទីព្រៃកប្បាសច្រឡាសស្វាស នឿយហត់ឈប់ឈ្លៀសសេះដំរី ។
ជិះបរទៅខេត្តសំរោងទង ភ្នំស្រួចខេត្តថ្ពងគងពិសី
សង្ឃាតឱហាតខំឃ្មាតខ្មី រកស្រីផងគ្មានធ្យានរំពឹង ។
ឡប់ពីបាទីព្រៃកប្បាស អរបានស្រឡះដើរវិលវឹង
ចូលរកខេត្តស្អាងកណ្ដាលស្ទឹង ពុំដឹងព្រួយចិត្តគិតស្រូតឆ្លង ។
៥៤០. ទៅខេត្តលង្វែករលាប្អៀរ សសៀរទៅដល់ខេត្តខ្លុងក្រង
ខ្លះទៅពោធិសាត់បាត់ដំបង ឆ្លងស្ទឹងបាត្រែកំពង់ស្វាយ ។
ដើរកាត់ចាត់ចូលខេត្តជើងព្រៃ កំពង់សៀមវែងដល់បារាយណ៍
ខ្លះចេះវេះគេចនៅរៀងអាយ កៀនស្វាយល្វាឯមពាមតាឯក ។
ទៅខេត្តរំដួលចូលស្វាយទាប រៀងរាបបត់ទៅរមាសហែក
ទៅរកពាមជរមកលើកដែក ដើរបែកដល់ស្រុកមុខកំពូល ។
ខ្លះដើររកក្បែរមាត់ទន្លេ មិនបានគិតគ្នេរនាំគ្នាចូល
បង្គំទ្រង់រិទ្ធិនឹងពិតទូល ឆ្ងាយជិតមកមូលទូលចមត្រៃ ។
ទូលចប់ត្រឡប់លាភូបាល ឡើងខ្សាច់កណ្ដាលត្បិតសង្ស័យ
បាភ្នំព្រៃវែងទទឹងថ្ងៃ ក្រត្រៃមិនបានដូចបំណង ។

---

១. ច្បាប់ខ្លះថា ... ប្រាថ្នាជា ។

៥៤៥. សៀវសិករកក្នុងខេត្តរមាស　ភ័យស្មោសគិតឈ្លៀសរកទូកឆ្លង
ចែវស្រូតរហូតដល់ស្ទឹងត្រង់　សៅហ្មងព្រួយចិត្តគិតឈប់ឈរ ។
ប៉ុន្តែព្រួយប្រឹងនឹងរាជការ　ឡើងសាទៅខេត្តឆ្លងកញ្ជរ
ក្រចេះក្រូចឆ្មាររកាខ្នុរ　ស្រុកលោលបមកសួងសង្កែ ។
លង់លុះដល់ដែនខេត្តត្បូងឃ្មុំ　អរជូនជាធំមានចិនខ្មែរ
ចាមជ្វាចំនៀរខាងស្រុកស្រែ　ដើរហែមៀងមើលមិនត្រូវចិត្ត ។
ដល់ពោធិដើងខាលមានអណ្ដូង　ឃើញមនុស្សជ្រួលច្រូងឈរប្រកិត
អាជ្ញាខាងហ្លួងទាំងពួងពិត　មើលគ្មានពេញចិត្តដល់មួយឡើយ ។
លង់លុះសុរិយេទេវត្រជាក់　ទាវស្រីវរលក្ខណ៍ចេញលំហើយ
អាជ្ញារីកមុខទុក្ខផងស្បើយ　ថាគ្នាយើងអើយពេញហៅល្អ ។
៥៥០. យើងដើររកសព្វក្នុងបុរី　មិនបានរូបស្រីស្រស់បវរ ។
អាជ្ញាទាំងនោះឆ្កោះស្មោះសរ　អំណរពេកពិតឥតស្មើបាន ។
ចាំគ្នាមើលមៀងផ្ទៀងអង្គកាយ　អង្គីដែនអាយកបកល្យាណ
សមជាមហេសីមហាក្សត្រក្សាន្ត　ស័ក្តិសមអង្គប្រាណស្រស់ប្រិមប្រិយ ។
អាជ្ញាខាងហ្លួងទាំងពួងសួរ　រាស្ត្រផងគាប់គួរលុតលើកដៃ
ថាទាវល្អមែនហើយម្ចាស់ថ្លៃ　សព្វថ្ងៃបានទៅកូនអរជូន ។
អាជ្ញាឈ្លបឆ្លៀតសង្កេតសួរ　ចូរប្រាប់គាប់គួរឲ្យមែនមួន
ការហើយឬគ្រាន់តែជំនួន　កុំឡិបបំពួនលាក់លេងឡើយ ។
រាស្ត្រភ័យលើកដៃជំរាបថា　ថ្នាក់ត្រឹមស៊ីស្លាទេលោកអើយ
ជម្រាបតាមត្រង់ប៉ុណ្ណឹងហើយ　ស្ដាប់ពាក្យរាស្ត្រឆ្លើយមិនសង្ស័យ ។
៥៥៥. ទើបនាំឱង្ការទៅប្រញាប់　ខំស្រូតឲ្យឆាប់ទាំងយប់ថ្ងៃ
ដល់ឡើងអរជូនឱនលើកដៃ　ខ្លាចបារមីថ្លៃរួសម្ទីម្នា ។

ទៅដល់ម្ដាយនាងហើយប្រាប់ថា បន្ទូលព្រះមហាក្សត្ររាជា
ឲ្យនាំនាងទៅក្ដុំរួញរា ថ្វាយព្រះរាជាស្ដេចទ្រង់រិទ្ធិ ។

ម្ដាយនាងបានស្ដាប់បន្ទូលថ្លៃ ឱនក្រាបលើកដៃបង្គំគិត
ប្រាប់ញាតិសន្ដានបានដឹងពិត នាំនាងនោមស្និទ្ធទៅថ្វាយស្ដេច ។

អរជូនរួសរាន់រៀបទូកក្ដារ ប្រគល់អាជ្ញាប្រដាប់ស្រេច
ទូកមួយនាងជិះល្អបណ្ដាច់ ញាតិសាច់បងប្អូនជូននាងទៅ ។

កាលនោះម្ដាយនាងគិតជំនុំ នឹងអស់ចាស់ទុំថាឥឡូវ
យើងស្អាងនាងកូនឲ្យត្រឹមត្រូវ រួចចរចុះទៅទូកម្ទីម្នា ។

៥៦០. កំណែនច្រូងច្រាងខាងជើងទឹក ចាប់ចែវរញ្ជីកគ្រប់រាល់គ្នា
ខ្លះវាតខ្លះឆាកលៀកគាស់រា នាងលាសន្ដានច្រានចេញទៅ ។

ជិះទូកពុំសុខទុក្ខពុំស្បើយ នាងថានោអើយយើងឥឡូវ
បងជួយគិតប្អូនឲ្យត្រឹមត្រូវ គេយកប្អូនទៅថ្វាយស្ដេចហើយ ។

បងមិនអាណិតចិត្តប្អូនផង ទុក្ខធ្ងន់កន្លងពុំមានស្បើយ
សមប្អូនក្សិណក្ស័យទេដឹងអើយ ទុក្ខអើយទោម្នេញពេញជាថ្មី ។

ទុក្ខមួយព្រួយព្រោះអង្គក្សត្រា យកជាសង្សាររួមបេតី
ទុក្ខមួយឃ្លាតទុំនោមពីសី រស់ថ្វីសូវស្លាប់ទៅក៏ជា ។

កើតមកជាមនុស្សក្នុងលោកិយ ចាប់ជាតិជាស្រីរងវេទនា
សង្សារសម្លាញ់ក៏ឃ្លាតឃ្លា វេទនាចិត្តអ្វីអីម្ល៉េះណា៎ ។

៥៦៥. ម្ដាយនាងជិះទូកទៅជាមួយ ប្រុសស្រីរង្គួយមិនដឹងការណ៍
គិតស្មានទាវស្មគ្រនឹងក្សត្រា អរឥតឧបមានាំនាងទៅ ។

នាងសោតជាទុក្ខមុខក្រៀមក្រំ ខំអត់ទ្រទ្រាំនាំកំឡានៅ
កណ្ដែងកណ្ដោចកណ្ដាលផ្លូវ ទូកសោតលឿនទៅដោយរលក ។

សាត់លយលន់លឿនពន់ប្រមាណ ព្រះពាយផាត់ច្រានរិលពពក
អណ្ដែតលយសាត់ខ្ចាត់ទៅមក ចូលជ្រកបាំងវង់ព្រះចន្ទ្រា ។

ទាវថាឱអង្គព្រះចន្ទថ្លៃ ពណ៌ដូចចរណៃលើវេហាស៍
ដូចខ្លួនខ្ញុំបែកបង់ឃ្លាតឃ្លា រស្មីចន្ទ្រាក៏ត្រជាក់ ។

តារារះរុងរឿងជិតជុំ ដូចអញនិងទុំធ្លាប់រួមរ័ក្ស
តារារះរាយដោយចង្វាក់ ដូចអង្គអញស្ម័គ្រទុំថ្លើមថ្លៃ ។

៥៧០. លង់លុះម៉ោងបួនជួនយប់ស្ងាត់ ព្រះពាយផាយផាត់ត្រជាក់ក្រៃ
ទាវភ្ញាក់នឹកទុំព្រោះអាល័យ មមៀលលើកដៃឈោងប្រវា ។

លុះភ្លឺស្រាងស្រេចបំព្រាងខ្មី ទាវស្រីគយគន់ហ្វូងមច្ឆា
ហាក់ហែលផុសផែលក្នុងទឹកថ្លា ចង្វាផ្ទោងផ្ទក់អ្នកគជ្រា ។

ស្លូតស្លាតសង្វាតហែលប្រែប្រឹង កែកែសច្រឡឹងច្រឡំគ្នា
ក្តាមខ្យងត្រសងតាមហ្វូងវា ព្រលិតស្លាបទាលូតលលេច ។

ទូកសោតថែវស្រូតសសៀរឆ្លង ហួសខេត្តជាម្តងលឿនស្រួលស្រេច
ទាវនឹកដល់ទុំមិនមានភ្លេច រំពេចត្រូវខ្យល់ដល់កោះកុក ។

ថែវស្រូតទន្ទឹមពាមជីកង កាត់ឆ្លងទៅកោះឫស្សីស្រុក
អាសូរទាវសល់ខ្វល់វិតក្ក ពុំសុខក្រហាយក្នុងកាយេ ។

៥៧៥. ថែវដល់ព្រែកពោធិកងត្រណឹង រកាកោងនឹងដល់ល្វាទេរ
ទាវសោតជញ្ជឹងគិតរិះរេ គ្មាន់គ្នេររំពឹងរឹងថែថប់ ។

ដល់ព្រែកដំបងជ្រោយមេត្រី ភូមិស្លាតារីភូមិមាន់ជប់
ហួសពាមតាឯកព្រែកប្រសព្វ ថែវចប់ដល់កោះខ្សាច់កណ្តាល ។

ទាវទុក្ខក្រៀមក្រំជាំកាយា នឹកទុំណាស់សាធ្លាប់ស្និទ្ធស្នាល
ស្រីប្រុសស្រើបស្រស់ស្រួលឈឺឆ្អាល បណ្តាលឥតគិតដល់ប៉ុនល្អង ។

មិនមានអាសូរទ្រូងទាវសោះ ខំថែវស្រូតកោះកាត់កៀនឆ្លង
បានដល់ព្រែកហ្លួងព្រែកបង្កង ស្រូតឆ្លងកៀនឃ្លាំងជ្រោយចង្វា ។

ដល់ក្រុងភ្នំពេញដែនដីរាប រសៀលទន់ទាបព្រះសុរិយា
ឡើងមើលទំនិញគ្រប់តាមផ្សារ ត្រៀបត្រាចិនខ្មែរហែគឹកកង ។

៥៨០. ស្រេចចរចុះទូកថែវចេញទៅ មិនហ៊ានឈប់នៅខាចក្សត្រច្បង
ដល់ច្រាំងចម្រេះព្រែកព្នៅឆ្លង បំណងកាត់តាមពាមដូនស្តើង ។

ថែវដល់កោះស្បែកព្រែកកោះចិន បាយឆ្អិនស៊ីស្រេចលីលាឡើង
មើលអស់ទំនិញល្អថ្មីថ្កើង ស្រីប្រុសឈ្មិតឆ្មើង[1] ចចើងចរ ។

ទូកដល់កំពង់រង់រៀបខ្លួន ប្រាប់ទាវនឹមនួនឆោមបវរ
ទាវចុះងូតទឹកជ្រះល្អះល្អ ស្លៀកពាក់បង់កខ្លួនស័ក្តិសម ។

លង់លុះទេរទាបព្រះសុរិយា ទាវកើតទុក្ខានឹកដល់ទំ
ទន់ទាបជិតជិះរិះបាំងភ្នំ ស្រទំត្រជាក់ចរយាត្រា ។

ដើរតាមដោយផ្លាមាគ៌ាថែក ដល់បន្ទាយលង្វែកដូចចិន្តា
ជិតជើងរាជវាំងអង្គក្សត្រា មើលផ្សារត្រាត្រៀបរៀបរៀងរាយ ។

៥៨៥. ប្រាសាទប្រសើរលើជហ្វា នាគាដងក្តារសីមាលាយ
កំពោរបាយអភាគបន្ទាយ ស្រះស្រង់ទ្រង់ទ្រាយទូលាយធំ ។

រោងទ័ពរោងទងទំនងស្រួល ទាវមើលអន់អួលវិយោគយំ
ឮសូរសព្ទភ្លេងលេងរងំ គងធំយំយាមតាមលំដាប់ ។

ដោយនូវសក្តាមហាក្សត្រ មិនស្ងាត់សៀងសូរអ៊ូអឹងអាប់
យើងឈប់បង្អង់រឿងរៀបរាប់ នឹងចាប់សម្តែងតែងតទៅ ។

---

១. ច្បាប់ខ្លះថា ឆ្មាំឆ្មើង ។


T.CHEAT.

ថ្លែងពីទាវទុក្ខពុំសុខសោះ និកឡើងស្រណោះទុំដោយនូវ
យប់យូរស្ងប់ស្ងាត់បាត់ស្អុះក្តៅ ព្រះពាយផាត់ត្រូវរហើយប្រាណ ។
ទាវប្រះប្រាណប្រែបែររិតក្ក និកដេកពុំលក់ទុក្ខគ្មានក្សាន្ត
ថាឱព្រះពាយផាយផាត់ប្រាណ សមខ្ញុំប្រមាណអស់បានទុំ ។
ទុក្ខប្អូនទៀតហើយទុំអើយអ្នក នៅលើដំណាក់ក៏ភ្លេចខ្ញុំ
ឥឡូវប្អូនមកជ្រកដេកយំ ក្រាលក្រំដំបៅក្តៅឱភា ។
ព្រឹកនេះគេនាំខ្ញុំទៅថ្វាយ ស្តេចគង់ដែនអាយលើសិរសា
ខ្លួនឯងជារាស្ត្រតើលោកណា មេត្តាដឹងទុក្ខជួបមូលទុំ ។
ព្រឹកព្រាងភ្លឺស្វាងពណ៌រស្មី ទាវស្រីថែថប់កើតទុក្ខធំ
ទឹកភ្នែកស្រក់ស្រោកវិយោគយំ ធូន់ខ្លួនស្មើភ្នំរលំលើ ។
ស្រាកស្រន់អន់ធូរយូរបន្តិច ដៃស្រាយបង្វេចនៅស្ទាក់ស្ទើរ
មើលយល់ប្រដាប់សព្វសារពើ តែងស្លៀកពាក់ធ្វើលំអអង្គ ។
ស្លៀកពាក់ទាំងទុក្ខទាវនួនល្អង តែងស្រេចជាម្តងខំផ្ចិតផ្ចង់
លាបប្រេងផាត់ម្សៅពណ៌ផូរផង់ ត្រចះត្រចង់ដូចចន្ទ្រា ។
រៀបរួចស្រេចស្រាប់ប្រដាប់ផង ចរចេញត្រសងចរលីលា
ចូលដល់ឡប់ខ្សែក្បែរមាត់ទ្វារ រង់ចាំវាជាចុងរោងរម្យ ។
កាលអើយកាលនោះព្រះចមត្រៃ ក្សត្រថ្លៃស្តេចចេញចាកបន្ទំ
ស្នំស្និទ្ធទាសីស្រីក្រមុំ តូចធំគាល់អង្គព្រះជេដ្ឋា ។
ស្តេចចេញប្រថាប់នៅរោងធំ ចតុស្តម្ភបង្គំគាល់ក្សត្រា
ស្នំស្និទ្ធប្រតិតស្រីកញ្ញា គាល់អង្គមហាក្សត្រច្បាស់ច្បង ។
កាលអើយកាលនោះទាវស្រីថ្លៃ ពណ៌ស្រស់ប៉ប្រៃល្អឥតហ្មង
នាំគ្នាយាត្រាទៅត្រសង គាល់អង្គក្សត្រច្បងស្តេចទ្រង់រិទ្ធិ ។

ដល់ហើយឱនកាយថ្វាយអភិវាទ ខ្លាចព្រះនរនាថក្រាបជួញជិត
សេនាបតីស្រីស្នំស្និទ្ធ បង្គំទូលពិតអង្គឥស្សរា ។
៦០០. ស្តេចទ្រង់បែរបៀងទៀងទតជាក់ យល់ទាវវរលក្ខណ៍សមកាយា
ត្រូវព្រះហឫទ័យមានឱង្ការ ថ្លែងថារូបទាវគួរអាល័យ ។
ស្តេចមានបន្ទូលស្រួលសួរថា នែអស់កញ្ញាមហេសីថ្លៃ
រូបទាវល្អហើយឬសង្ស័យ ដួងចៃថាចុះខុសលើកលែង ។
មហេសីទូលថាល្អជាក់ស្បាន់ ប្រផូរប្រផាន់ត្រចះចែង
សមជាមហេសីនៃស្តេចស្តែង ស្តេចថ្លែងឲ្យហៅទុំច្រៀងថ្វាយ ។
ទុំឮសួរសៀងប្រឹងផ្ទៀងស្តាប់ ច្បាស់ហើយចូលឆាប់ឱនអង្គកាយ
លើកហត្ថរួចចាត់ចែងបរិយាយ ឃើញទាវឆោមឆាយម្តាយនាំដល់ ។
ប្រថុយគ្មានគិតជីវិតប្រាណ ក្តៅដូចភ្លើងក្រានជ្រប់ស្រងល់
ខ្លោចផ្សាឱរ៉ារឹតខ្វាយខ្វល់ ផ្ទញ់ផ្ទាល់មិនរអែងក្រែងចេស្តា ។
៦០៥. ថាឱព្រះចមត្រៃថ្លៃអនេក ជាឯកភូមិភពគ្រប់លោកា
លោកិយដែនដីឋានមនុស្សា ខ្លបខ្លាចចេស្តាព្រះបារមី ។
ទ្រង់មានឱង្ការចាត់ឲ្យរក ឲ្យរើសរូបមកជាមហេសី
ឥឡូវបានទាវស្រស់ប្រិមប្រិយ មិនគួរគប្បីទាស់ទទឹង ។
ខ្លាចព្រះចេស្តាម្ចាស់ទ្រង់រិទ្ធិ ទូលបង្គំសូមពិតឯទាវហ្នឹង
ជាក់ជាសង្សារប្រាថ្នាពឹង សន្មតរិលរឹងគ្រប់ជាតិ ។
ជាតិតាំងកំណត់សន្មតកើត យោនយកកំណើតជាប្រុសស្រី
ឲ្យជួបទាវស្ងួនន្ទួនពិសី ប្រាថ្នាកុំបីឲ្យឃ្លាឃ្លាត ។
ទាវស្តាប់សាសព្ទទុំច្រៀងថា ក្តៅក្នុងឱរាតឹងចង្អៀត
មិនហ៊ានងើបមើលមុខទុំទៀត ខ្លាចក្សត្រនរនាថយកទោសា ។

៦១០. ទុំច្រៀងរៀបរាប់ដំណាលសព្វ តាំងពីទុំធ្លាប់រួមស្នេហា
ទាវសោតក្រៀមក្រំអន់អួលផ្សា ក្តួលក្តៅឱរាមិនមានស្តី ។
កាលនោះឯអង្គព្រះចមត្រៃ ក្សត្រថ្លៃទ្រង់ខ្ញាល់នឹងទាវស្រី
ឈ្ងួងគួរ[១] សន្តោសប្រោសប្រណី ព្រះទ័យជញ្ជីងរំពឹងកាត់ ។
ទ្រង់ធម៌ថាអញយកទោសវា សមនឹងឃ្លាតឃ្លាសង្សារសត្វ
ព្រះធម៌មេត្តានឹងបង់បាត់ គួរជាត់ទាត់ចោលចេញទើបជា ។
មានព្រះតម្រាស់ប្រាប់មន្ត្រី ឲ្យយកទាវស្រីមកសួរវា
បើឆ្លើយទៅហើយត្រូវពាក្យគ្នា យើងលើកលែងវាតាមចម្លើយ ។
ស្តេចមានព្រះរាជឱង្ការ បន្ទូលសួរថានែទុំអើយ
ទាវសង្សារមែនចូរឯងឆ្លើយ កុំបិទបាំងឡើយប្រាប់តាមត្រង់ ។
៦១៥. កាលនោះទុំសោតខ្លាចបារមី ផ្ទៀងស្តាប់ជាក់ខ្មីលើកករផ្គង់
ទុំទូលក្សត្រាដោយស្មោះត្រង់ សូមទានព្រះអង្គប្រោសប្រណី ។
ករុណាសម្លាប់តាមទោសធំ ទុករស់ជាខ្ញុំព្រះបារមី
ទូលបង្គំជាខ្ញុំនឹងលាក់ថ្វី ឯនាងទាវស្រីសង្សារពិត ។
ទ្រង់ត្រាស់សួរទៅនាងទាវវិញ ទាវអើយខ្លួនមិញអញពិនិត្យ
ប្រាប់ដោយពិតត្រង់កុំភ័យភិត បានរួមផ្តេកផ្តិតឬមុសា ។
ទាវទូលទៅអង្គព្រះចក្រី បពិត្រនរតីសូមមេត្តា
ខ្ញុំនិងទុំពិតទៀងសត្យា ដូចព្រះករុណាទ្រង់ជ្រាបស្រាប់ ។
កាលនោះឯអង្គព្រះចមត្រៃ ក្សត្រថ្លៃបានទ្រង់ព្រះសណ្តាប់
ទ្រង់ឈ្ងួងជឿជាក់ទាវសាស័ព្ទ ស្តេចត្រាស់ប្រញ្ញប្តិ[២] ប្រាប់សេនា ។

១. ច្បាប់ខ្លះថា តែងឈ្ងួង... ។
២. ប្រញ្ញប្តិ=បញ្ញត្តិ, បង្គាប់ ។

៦២០. ទ្រង់ព្រះតម្រាស់នឹងកុង្សីយ៍ មាត្យមុខមន្ត្រីខ្ញុំរាជការ
ឲ្យរៀបប្រដាប់មង្គលការ ក្សត្រានឹងផ្សំទាវនិងឯក ។
ចតុស្តម្ភបង្គំលាចក្រី ទៅផ្ទះទីទៃវិញដោយឡែក
ប្រាប់គ្នាទៅមកថាថ្ងៃស្អែក កុំចាំរារែករួសរវៃៗ ។
ទើបក្រោកក្រាកចាកទែនមណី យាងចូលមន្ទីរក្សាន្តព្រះទ័យ
ផ្ទំលើសយនាថានប្រពៃ ទុំគាត់គិតតែគាល់រាជា ។
លង់លុះព្រឹកព្រាងស្វាងឡើងជាក់ ក្សត្រថ្លៃទ្រង់លក្ខណ៍ចាកនិទ្រា
ចេញគង់ចុងរោងជុំស្រីង្គារ មន្ត្រីរាល់គ្នាឡើងគាល់ក្សត្រ ។
ស្ដេចទ្រង់បង្គាប់ឲ្យរៀបចំ នាំទាវមកផ្សំឲ្យឆាប់ថ្វាត់
ទុំទាវចូលគាល់ឱនប្រណិប័តន៍ មហាក្សត្រស្ដេចឲ្យពរមង្គល ។
៦២៥. ជួបជុំបតីមន្ត្រីធំ ចតុស្តម្ភមូលមកជួយរវល់
ផ្សំផ្គុំទុំទាវថ្លៃនិម្មល ទសពលទ្រង់ក្សាន្តមានមេត្តា ។
សំពះចុងស្លឹកព្រឹកនោះស្រេច បរិបូណ៌សូរេចមង្គលការ
ម្ដាយទាវគាត់លាអង្គក្សត្រា នាំញាតិឡប់សាមកស្រុកវិញ ។
ឯទាវនួនល្អងល្អពិសី បានរួមមេត្រីនឹងគ្នាមិញ
ទាវសោតបានសុខឥតទុក្ខម្ទេញ ពិតពេញដូចចិត្តគិតចេតនា ។
ទុំនៅយូរទៅក៏សុខសាន្ត ឡើងគាល់ក្សត្រក្សាន្តអង្គឥស្សរា
នៅបិតរួមស្ថានក្សាន្តចិន្តា ឥតមានទុក្ខានឹងអ្វីឡើយ ។
ថ្លែងពីម្ដាយទាវវិលដល់ស្រុក វិតក្កព្រួយប្រាណពុំបានស្បើយ
ថាឱទាវថ្លៃកែវកូនអើយ ម្ដេចឡើយមកបានប្ដីកំសត់ ។

៦៣០. ពីព្រោះអាចោរចិត្តចង្រៃ កាចក្រៅវិស័យវាហ៊ានក្បត់
ថាទាវសង្សារវាប្រាកដ ស្ដេចអត់ពុំយកនូវទោសា ។
អញផ្ដាច់ពង្រាត់ពីអានេះ មិនមានសន្ទិះគិតសង្កា
កិច្ចកលឧបាយតាមប្រាជ្ញា ផ្ដាច់អាទុំចោរចិត្តទ្រុស្តក្បត់ ។
គិតផ្សំផ្គុំស្រេចនឹងម៉ឺនងួន កូនលោកអរជូនពិតប្រាកដ
អញឲ្យថ្មីអាទុំសាត់ព្រាត់ ពង្រាត់ចេញជាវេលាហ្នឹង ។
អញគិតឲ្យទៅលោកអរជូន ម៉ឺនងួនកូនគាត់គ្រាន់ទីពឹង
មានទ្រព្យស័ក្តិយសខ្ពស់ត្រដឹង តាមខឹងគិតខុសដល់យូរថ្ងៃ ។
កបពាររាត្រីស្រីម្ដាយទាវ ខេខឹងឆុលឆាវគ្មានសំចៃ
ស្ងូវចង់បង់ទ្រព្យធ្លាប់ដល់ក្ស័យ តាមចិត្តអាល័យមិនមានគិត ។
៦៣៥. ស្រេចហើយម្ដាយទាវចុះដើរទៅ ដល់ឡើងលំនៅធ្លាប់ស្ពាលស្និទ្ធ
ជន្លងនឹងគ្នាដោយទុកចិត្ត ជាមិត្តឥតមោះចោះថ្លាថ្លែង ។
គាត់ដល់អង្គុយផ្ចង់ស្មារតី លើកដៃសំពះថាខ្ញុំឯង
ជាស្រីហាក់ដូចបានតុបតែង ខ្លាចក្រែងខុសសល់លោកមេត្តា ។
ក្ដៅណាស់ចៅហ្វាយនឹងអាទុំ នាំឲ្យអាប់ឱនកេរ្តិ៍មេបា
ព្រហើនមិនមានខ្លាចនរណា ឥឡូវខ្ញុំថាសូមចៅហ្វាយ ។
វិះរកធ្វើនំផលចំណី ជ្រូកមាន់ទាត្រីស្រានូវបាយ
បន្លែគ្រប់មុខទុកពីអាយ បម្រុងចុតហ្មាយចាត់ដល់ទៅ ។
ទាវកូនឲ្យវិលមកប្រញាប់ ពាក្យពេចន៍សាស័ព្ទថាម្ដាយនៅ
ឯនាយឈឺធ្ងន់គ្រុនចុកក្ដៅ ផ្ដាំមកកូនចៅសាច់សន្ដាន ។
៦៤០. វិលឆាប់ទើបទាន់ម្ដាយផ្ដែផ្ដាំ រង់ចាំរឹតខ្លាំងភាំងប្រមាណ
កម្លាំងតិចណាស់ខ្វះក្នុងប្រាណ ម្ល៉េះខានឃើញមុខជាទុក្ខធ្ងន់ ។

បើបានទាវកូនមកដល់ហើយ បង្អង់អ្វីឡើយរៀបកែកុន
កែគិតឲ្យងួនជាប្រពន្ធ យើងផ្សំពីមុននឹងគ្នាស្រាប់ ។
ម្ដាយទាវវិលដល់ទីគ្រឹះស្ថាន គាត់គិតប្រមាណរួចប្រញាប់
រកស្ដីគេធ្វើសំបុត្រឆាប់ រៀបគ្រប់ប្រដាប់ប្រាប់ប្រើទៅ ។
ចាត់ឲ្យអ្នកនាំអង្គអក្ខរា គាត់ប្រាប់ផ្ដាំថាកុំអង់នៅ
ឲ្យយូរដំណើរត្បិតឥឡូវ ថាម្ដាយឈឺក្ដៅអត់ភោជនា ។
អ្នកទាំងអម្បាលកាលនោះមិញ ស្រុះស្រួលស្រស្រាញ់ដូចចិន្ដា
ចុះទូកចែវភ្លាមតាមជលសា ប្រាថ្នាបានដល់សកលនាយ ។
៦៤៥. ចតទូករួចឡើងទៅរំពេច ដល់ផ្ទះទុំស្រេចសួររួសរាយ
ទាវថាម្ដេចទៅអ្នកលោកម្ដាយ សប្បាយសុខសាន្តឬមានអ្វី ។
អស់អ្នកទាំងឡាយពីអាយស្ដាប់ ទាវសួររួចរាប់តាមសេចក្ដី
ស្រាយយកសំបុត្រឲ្យទាវស្រី មើលដឹងទាវភ័យស្លុតភាន់ភាំង ។
ទាវថាឱអ្នកវរលក្ខណ៍ប្អូន ម្ដាយខ្ញុំឈឺសូន្យស្មើរមរណំ
ថាអត់អាហារហោវស្គមស្គាំង ឥឡូវមានទាំងកំណត់ថា ។
ឲ្យខ្ញុំលាអ្នកបងទៅឆាប់ រួសរាន់ប្រញាប់តាមសញ្ញា
ឲ្យជុំកូនចៅញាតិកា សែនព្រេនមេបាខ្មោចក្នុងផ្ទះ ។
ទុំដកដង្ហើមធំថប់ថា ឱប្អូនសង្សារខំរូតរះ
ទៅហើយបើជាប្អូនរហ័ស កុំលះលន្លង់សុងយូរឡើយ ។
៦៥០. បងរៀបដំណើរឲ្យកល្យាណ ខ្លួនបងឈប់ខាននៅនេះហើយ
ធុរៈរាជការក្សត្រត្រាណត្រើយ ប្អូនអើយប្រយ័ត្នអង្គអាត្មា ។
ទាវលាទុំចរចុះទូកស្រេច ចែវស្រូតរូតលេចជ្រោយចង្វា
ខំចែវមិនចតឈប់ឡើយណា ចិន្ដាទាវទុក្ខមុខក្រៀមក្រំ ។

ទុក្ខមួយឃ្លាតប្ដីថ្មីឯកា ទុក្ខមួយមាតាឈឺដំណំ
ទាវថាឱអញម្ទេញចាកចំ បែងបង់បារម្ភក្រំច្រើនផ្លូវ ។
ថែវចប់ដល់ពាមភ្លាមដល់កោះ ស្រូតតាមចន្លោះមិនមានត្រូវ
គ្មានឈប់អង្គប្រាណសម្រាន្តនៅ ចតឈប់ឡើងទៅដល់ត្បូងឃ្មុំ ។
ទាវឡើងលើផ្ទះដាក់កាយា យង់យល់មាតាមាមឹងជុំ
សាច់ញាតិសង្ខាតមកជំនុំ រៀបភោជន័ផលនំផ្សំស្រាបាយ ។
៦៥៥. ដៃចាប់បាយនំអន្សមស្រា សែនថ្វាយដូនតាច្រូចថ្វាត់ថ្វាយ
ថាអស់ខ្មោចតាយាយនូវម្ដាយ អញ្ជើញមកអាយសេពសោយផល ។
សោយស្រេចឲ្យពរមកកូនចៅ សាច់ផៅប៉ុន្មានកុំឲ្យសល់
ឥឡូវទាវកូនទើបមកដល់ ចូរកូនតម្កល់គិតវែងឆ្ងាយ ។
ទាវមកដល់ហើយកូនអើយស្ដាប់ ម្ដាយនឹងសាស័ព្ទបទបរិយាយ
ធម្មតាកូនកើតមានរូបកាយ ល្អល្អះឆើតឆាយចាយសម្ដី ។
ឮឈ្មោះចំពោះដល់មហាក្សត្រ យកទៅថ្វាយថ្វាត់ទ្រង់ប្រណី
ប្រែឲ្យម៉ឺនឯកឥតមានអ្វី ក្រក្រីធនធានគ្មានស៊ីសោះ ។
ហេតុនេះម្ដាយប្រែកែគិតផ្សេង អរជូនជញ្ជឹងគួរស្រណោះ
គេមានស័ក្ដិបុណ្យធនរបស់ បណ្ដោះទាវទុកគ្រលុកការ ។
៦៦០. ផ្សំនឹងម៉ឺនងួនកូនគេមាន ស័ក្ដិយសធនធានតាមប្រាថ្នា
ខាងជើងទឹកទូកថែវធាក់ក្ដារ ចិត្តចង់ប្រាថ្នាក៏មានគ្រប់ ។
ដំរីរទេះសេះគោខ្មែរ សិវិកាត្រែតបិទបាំងម្លប់
មានភ្លេងល្បើយល្បែងទាំងថ្ងៃយប់ ម៉្លេះហើយទាវថប់អ្វីស្រីម្ដាយ ។
ទាវស្ដាប់ម្ដាយជាក់ស្ទើរធ្លាក់ថ្លើម ហៀបផុតដង្ហើមក្តួលក្ដៅកាយ
ថាឱព្រះមេមានគុណឆ្ងាយ ម្ដេចប្រែកែក្លាយឃ្លាតធម៌អាថ៌ ។

បើម៉ែកែឲ្យកូនមានប្ដី ទុំហ្នឹងដូចក្ដីស្និទ្ធស្នេហា
នេះកូនក៏ព្រមល្មមស្នេហា ផ្ទប់ផ្ទាល់រក្សាគ្នាតទៅ ។
ថាបើម៉ែមិនមានមេត្តា ឲ្យខ្ញុំព្រមការម៉ឺនងួនទៅ
សមក្ស័យជីវិតត្បិតមិនត្រូវ អង្វរម៉ែឪសុំប្រកែក ។
៦៦៥. នាងម្ដាយសម្លក់សម្លឹងមុខ កើតទុក្ខព្រោះកូនគិតអល់ឯក
ជេរថាមេចោររឹងដូចដែក អញចាប់មាត់ហែកបែកឥឡូវ ។
អញប្រាប់ឲ្យមានបានថ្លុំថ្លើង ហ៊ានហួសចចើងស្ដីគ្មានត្រូវ
ស្រឡាញ់អាទុំគ្មានម៉ែឪ គ្មានគិតអាស្រូវភាសខ្មាសគេ ។
មិនស្គាល់គេមានរបស់ទ្រព្យ ហងចង់ប្រសព្វអាឥតមេ
ឥតបាងណាកើតដល់កេរ្ដិ៍ ចំណេរទៅលង់គង់តែក្រ ។
ទាវឮម្ដាយខឹងក្រញឹងខ្លាំង ឆ្លើយឆ្មៀតតតាំងសូមអង្វរ
ម្ដាយស្ងៀមស្ងាត់ចុះទៅស្មោះសរ ចាកចរដើរដល់ឡើងគ្រឹះស្ថាន ។
ឧកញ៉ាអរជូនខ្លួនមានបុណ្យ ឃើញហើយអរលន់ពន់ប្រមាណ
ថាអ្នកអញ្ជើញមកកំសាន្ត ព្រួយប្រាណនឹងអ្វីអីដល់ខ្ញុំ ។
៦៧០. នាងជាជន្លងឆ្លងឆ្លើយថា ចៅហ្វាយរៀបការឲ្យសុខុម
ជម្រាបអ្នកស្រីចាត់ធ្វើនំ ហៅភ្ញៀវជួបជុំស្រេចជាម្ដង ។
យើងឈប់អង់សិនមិនសម្ដែង ថ្លាថ្លែងទាវកើតទុក្ខសៅហ្មង
មិនឃ្លានអាហារភោជន៍ផលផង ទុក្ខធ្ងន់កន្លងកន្លែងគិត ។
ប្រះប្រាណវិយោគសោកឡឹងឡង់ អញអើយម្ល៉េះបង់ដល់ជីវិត
ក្សិណក្ស័យព្រោះឆ្ងាយទុំថេរបិត គ្មានដឹងគំនិតគេខឹងខ្លាំង ។
ទៅបញ្ឆោតខ្ញុំមកមែនហើយ ទុំអើយឥឡូវគេបង្ខាំង
បង្ខានបង់ប្រាណដល់មរណំ ខ្ញុំតាំងសច្ចាចិន្តាថ្វាត់ ។

ទាវទុក្ខបណ្ដើរធ្វើអក្ខរី សរសេរស្រេចស្រីទាវប្រយ័ត្ន
បត់បិទរុំជិតនឹងស្លាថ្នាត់ បារីស្លឹកកាត់ចាត់បម្រើ ។

៦៧៥. មនុស្សដែលទាវទុកចិត្តស្និទ្ធស្នាល ឈើឆ្កាលជាសាច់ញាតិប្រសើរ
ប្រសប់ដំណឹងដឹងផ្លូវដើរ រហ័សហាក់ហើរប្រើទៅខ្មី ។

នាអ្នកច្បាស់ជាក់ទាវប្រើហើយ មិនបង្អង់ឡើយនាំអក្ខរី
អក្ខរានិងស្លាថ្នាត់ថ្មីៗ បារីទាវខ្ចប់សព្វឥតខ្វះ ។

ចរចុះចំពោះចេញលីលា ដល់ដានមាគ៌ាភ្លែតរហ័ស
រហើយខ្លួនប្រាណបានរូតរះ រួសរាន់ស្វែងសួរប្រទះទឹក ។

រួចស្ដីប្រុសស្រីនៅទន្លេ ចម្លងទទេគេគិតនឹក
អាណិតអ្នកមួយព្រួយពន្លឹក ចុះទូកចូកទឹកចែវលឿនលន់ ។

លុះដល់សកលខេត្តដែនដង សួរអស់អ្នកផងអ្នកអើយម-
ណ្ឌលទីទុំទាវមកផ្កាប់ផ្គុន ថ្លៃកែវមានបុណ្យជនចូលជិត ។

៦៨០. មូលមកពឹងតេជបែកអំណាច ប្រជាជនខ្លាចដោយសុចរិត
សត្រូវខ្ចាត់ឆ្ងាយមិនហ៊ានជិត ខំប៉ះល្មោចល្មិតជីវិតគ្មាន ។

នាអ្នកចម្លងវិលដល់ផ្ទះ ស្រឡះរួចកែបែរនិទាន
បម្រើទាវទៅដល់មិនមាន បារម្ភពើបពានឈានដើរដល់ ។

ផ្ទះទុំទុកចិត្តស្និទ្ធស្នាលស្រាប់ ទុំឆាប់ស្រដីសួរគ្មានសល់
ថាមកសុខសាន្តឬកង្វល់ អ្វីគួរពិភាល់ឆ្ងល់សូមប្រាប់ ។

អ្នកទៅពីអាយស្រាយសំបុត្រ ទុំមើលស្រយុតដៃឈោងចាប់
ស្រាយមើលឃើញស្លាមានជន្លាប់ ប្រដាប់បារីស្រីបងផ្ញើ ។

ឱ! ទាវនួនល្អងបងកើតទុក្ខ ឆ្អល់ភ្លែតណែនចុកទៀតហើយតើ
រីតរឹងព្រលឹងបងចាត់ប្រើ ដំណើរដូចដឹងឬផ្សឹងទៀត ។

៦៨៥. ឱ! ទាវអើយទៅពីព្រោះម្ដាយ    មិនដឹងប្រែក្លាយមានប្រើស្នៀត
ទាវអើយទុក្ខទុំធំចង្អៀត    ស្តាត់ស្លៀតដូចភ្នំរលំលើ ។
ទាវអើយទាវស្រីប្រណីបង    មែនពិតជាម្ដងទើបហ៊ានធ្វើ
អក្ខរីទាវស្រីប្អូនចាត់ប្រើ    ដំណឹងដំណើរឲ្យឆាប់ដល់ ។
ប្អូនអើយទុក្ខបងម្ដងហ្នឹងធ្ងន់    ពេញពៀបទូរន់សួន្យស្រងល់
ស្រងាត់ដូចហាក់អកុសល    ខ្វាយខ្វល់ឡឹនឡង់អង្គរាយមាយ ។
ទាវអើយប្រសិនខ្លួនបានគេ    បងនៅទទេមិនឈប់ងាយ
ស៊ូបង់ជីវិតដូចសឹកនាយ    ស្លាប់ក្នុងបន្ទាយចំណោមធំ ។
ធម្មតារាជការមេកងសឹក    មិនមានភ្លូកភ្លឹកស៊ូរលំ
គេបាញ់គេចាក់គេធាក់ច្រំ    នេះសមស៊ូប្ដូរផ្ដាច់ជន្មា ។
៦៩០. ថាឲ្យបងឈប់មិនឈប់ឡើយ    ទាវថ្លៃប្អូនអើយបើមរណា
ស្លាប់យកជាតិទៀតទៅក៏ជា    ច្បាំងដូចមារាវេលាហ្នឹង ។
ទុំទុក្ខមុខគួរតែសង្វេគ    ទុក្ខទាវបាក់បែកក៏ស្វាត់ឈឹង
វិយោគយល់ស្វាត់បាត់ព្រលឹង    ប្រះប្រាណស្លុកស្ដឹងលើផែនទី ។
ដំណេកធ្លាប់ដេកនៅនេះហើយ    ទាវថ្លៃបងអើយធ្លាប់ពេលស៊ី
ភោជន៍ផលចំណីស្រីឃ្លាតពី    បង់បោះចាកនិរាសប្រាសឆ្ងាយ ។
សង្ឃឹមម្ដាយស្រីចង្រៃធំ    គាត់នាំបំបែកឲ្យខ្វាត់ខ្វាយ
រកកលសម្លាប់បង់អន្តរាយ    ទាវអាយសមស្រស់អស់បានយល់ ។
ទុំយល់ប្រដាប់ជន្លាប់ស្លា    ហួលព្រៃក្រមាពួកខ្មើយខ្នល់
កន្ទេលចៀមចំក្រុំទុពិល    ឃើញហើយសសុលក្រុងក្រាបលក់ ។
៦៩៥. ក្រោកក្រេកប្រវាល្ងកហត្ថឈោង    គៀនកើយត្រកងក្រហាយចុក
ផ្អែតផ្អល់ខ្វល់ចិត្តវិតវិតក្ក    ពុំសុខក្រោកក្រាកចាកចេញចរ ។

ចុះដីរំពៃមើលអាកាស ស្រឡះស្រឡេតល្ហេតស្លូតក
ស្ងាត់កាន់តែយប់ផ្អប់ត្រដរ រាប់រៀបតំណាទៀបទៅព្រឹក ។
ថាឱព្រះពាយជាយផាត់ជូន ពពកពពូនទាវប្អូននឹក
រីខ្លួនស្ងួនខ្វាត់បាត់រលឹក ទាវអើយបងធឹកទឹកតាងបាយ ។
ទុក្ខបងដូចដល់ស្រងល់ងោង ធេងធោងប្រៀបដូចកូននឹងម្ដាយ
ប្រាសស្លាប់ទៅរ៉ាមិនយល់កាយ បងប្រាសទាវឆ្ងាយឃ្លាតឃ្លាខ្លួន ។
ឃ្លាតសព្វដំណេកដេកទែនទី គ្រឿងស៊ីគ្រឿងតែងប្រេងក្រមួន
ក្រមិនយល់សោះអស់ជួបជូន ទាវស្រីជ្រកពួនងួនជាប្ដី ។
៧០០. ថាបើទាវបានទៅងួនពិត ស៊ូប្តូរជីវិតព្រោះប្អូនស្រី
គេយកពីទ្រូងទៅថ្មីៗ គ្មានគិតប្រណីភ័យប៉ុនល្អង ។
ម៉ឺនឯកសង្វេគបែកទាវស្រី លុះព្រឹកព្រាងខ្មីដៃត្រកង
ចាប់នេះចាប់នោះរបស់ផង ទុកដាក់ជាម្ដងប៉ងយាត្រា ។
ចរចុះដើរដល់វាំងមហាក្សត្រ ចូលកាត់ទុំគ្មានខ្លាចនរណា
ដល់ដាក់អង្គគាល់ផ្ទាល់ព្រះមហា- ក្សត្រទ្រង់ចេស្ដាបុណ្យបារមី ។
ទុំលើកហត្ថេប្រែប្រួញប្រុង ផ្គុំផ្គងបំរុងទុកសិរសី
ទុំថាទូលបង្គំជាខ្ញុំស្រី ចេញទៅមានប្ដីថ្មីស្រឡះ ។
តាមទ្រង់ចមចេរមេត្តាប្រោស ទោសានុទោសទុក្ខធ្ងន់ណាស់
ករុណាសូមសុំព្រះអម្ចាស់ ចាត់ឱង្ការត្រាស់ទ្រង់ដល់ទៅ ។
៧០៥. ឧកញ៉ាអរជូនខេត្តត្បូងឃ្មុំ ខ្លួនលោកជាធំឈរនិត្យនៅ
សំបុត្រថាម្ដាយទាវឈឺក្ដៅ ផ្ដាំឲ្យកូនចៅផៅសន្ដាន ។
ទាវទៅទុកការនឹងម៉ឺនងួន ទាវស្រីភ័យខ្លួនមិនហ៊ានខាន
ចាត់នាំកំណត់មកបើបាន បន្ទូលទៅថ្កានឆាប់ទើបទាន់ ។

ស្ដេចទ្រង់សណ្ដាប់សព្ទវាចា ទ្រង់មានឱង្ការត្រាស់រួសរាន់
អាចោរអរជូនដូចពងមាន់ វាភ័ន្តហ៊ានភព្វនឹងម្លប់ពោធិ ។

មិនដឹងខុសត្រូវស្រូវស្រងែ អាចោរដូចឆ្កែស៊ីសាច់គោ
វាហ៊ានទទឹងទោសត្រូវស្មោរ អញស្រាវរាវរកស្មោរខ្ទះដែក ។

អាចោរពួនព្រៃរំពៃព្រេច ផ្លាប់ចៀសវេះគេចដូចសត្វខ្វែក
អាស្វាមិនស្គាល់ព្រនង់បែក ក្បាលវាស្អែកៗសង្វេគទៅ ។

៧១០. កាលអើយកាលនោះព្រះរាមរាជ ទ្រង់ព្រះអំណាចក្រោធក្រឡៅ
ទ្រង់មានតម្រាស់ត្រាស់ឲ្យហៅ ថាចូរអស់ចៅក្រមសាលា ។

នាម៉ឺនមាត្យមុខមន្ត្រីធំ ឮហើយចូលជុំមកស្ដាប់ការណ៍
គាល់ព្រះមហាក្សត្រឱនសិរសា ក្រួញក្រាបហត្ថាដាក់សិរសី ។

ស្ដេចទ្រង់ទតទៀងទៅនឹងក្រុម នាម៉ឺនតូចធំមុខមន្ត្រី
ត្រាស់ថាចតុស្ដម្ភក្រុមកុង្សីយ៍ ចាត់ចែងសេចក្ដីបន្ទូលឆាប់ ។

អាណិតម៉ឺនឯកបែកប្រពន្ធ ថាម្ដាយឈឺធ្ងន់គេមកប្រាប់
ទាវទៅដល់ក្នុងវង់កណ្ដាប់- ដៃអរជូនចាប់ប្រញាប់ការ ។

ផ្សំនឹងម៉ឺនង្ហួនកូនវាពិត វាហ៊ានមិនស្បិតខ្លាចនរណា
អញផ្សំឲ្យឯកព្រោះត្បិតថា ទាវជាសង្សារវាប្រាកដ ។

៧១៥. ឯទុំបើបានបន្ទូលទៅ រួសរាន់ឲ្យត្រូវតាមសន្មត
បើវាមិនស្ដាប់ឯងឆាប់បត់ វិលមកឈប់អត់ឲ្យមើលវា ។

មន្ត្រីបានស្ដាប់បន្ទូលថ្លៃ លើកដៃបង្គំរៀងរាល់គ្នា
ថយមកដល់ក្រៅវាំងរាជា រួសរ៉ាឈប់ទ្រឹងកឹងអាល័ក្សណ៍ ។

ជំនុំចាត់យកក្រដាសឯក ប៉ាកកែចម្លែកធ្វើនឹងប្រាក់
សរសេររួចចូលទៅដល់ថ្នាក់ ចាត់ចាក់យកត្រាសង្ហារធំ ។

បោះបត់ជាផ្គត់ចិទជិតជាប់ ទទួលគំនាប់បានហើយរុំ
សំពត់ព្រៃសូត្រឈ្នួតផាហ៊ុម ស្រេចទុំជំនុំនឹងពេជ្រថា ។
ពេជ្រអើយទុក្ខបងម្តងហ្នឹងធ្ងន់ ប្រពន្ធគេយកទៅរៀបការ
ចូរពេជ្ររួសឆាប់ប្រញាប់ណា៎ រករៀបទូកក្តារច្រវាចែវ ។

៧២០. នូវគ្រឿងស៊ីសព្វប្រអប់ស្លា ក្រមាហូលព្រៃដបតែកែវ
បម្រុងទាញទូកមកខាងចែវ ហៅក្រុមយើងចែវចេញឥឡូវ ។
ទុំចរចាកចុះដល់ទូកស្រេច ចែវចេញលយលេចលឿនដោយត្រូវ
ព្រះពាយផាត់ជូនទុំសូន្យនៅ ក្នុងទូកគ្រហៅក្តៅខ្លោចផ្សា ។
ទ្រាំទ្រមិនបានប្រាណប្រះប្រែ យល់ផ្កាយជិតខែហែទុំថា
ឱអង្គព្រះចន្ទជុំតារា ទ្រង់ប្រោសករុណារំដោះទុក្ខ ។
ព្រះចន្ទចាំងចែងទែងរស្មី ដូចពណ៌នាវស្រីមិនយល់មុខ
ទុំរាប់រៀបរៀងច្រៀងទំនុក មើលស្រុកមើលស្រីមើលត្រីត្រែង ។
ឱឈើជិតជួរតួរអ្វីអញ ប្រាសទាវសម្លាញ់ម្ទេញចម្បែង
មិនដូចដើមត្រស់ក្រកោះត្បែង ដូចស្លែងដុះស្លាប់ជាក់ជិតជ្រៃ ។

៧២៥. ទុំរាប់ដើមឈើបណ្តើរទៅ មើលយល់ទឹកជ្រៅឃើញហ្វូងត្រី
ចង្វាភ្លៀងផ្ទោងលោតឡើងខ្ទី ខ្លួនអើយគួរបីបែកចែកឋាន ។
ចាកចរចេញជៀតឆ្ងៀតរកប្តី មានដូចហ្វូងត្រីក្នុងជលសា
មិនបែកគូគត់រត់ទៅបាន ហ្វូងវាប៉ុន្មានក្សាន្តសប្បាយ ។
មើលស្រុកគេគាប់រាប់តម្រូវ ត្រើយខាងកើតកូវផ្កាប់រាប់រាយ
ភូមិច្បារអំពៅនូវកៀនស្វាយ ទុំសោតក្រហាយក្នុងកាយធំ ។
ដល់យប់យូរយន់ពន់ពេកស្ងាត់ ព្រះពាយបក់ផាត់ត្រជាក់ខ្លាំង
ទុំទាញសំពត់គ្របចិទបាំង ភាន់ភាំងក្រោកក្រេសរិះរឺតរឹង ។

កង្វល់ក្នុងប្រាណមិនបានល្ហែ    ព្រួយណាស់គិតតែដេកសន្ទឹង
ស្រែកព្រាវថាទាវថ្លៃព្រលឹង    ប្អូនប្រាសសូន្យឈឹងនឹងបងទៅ ។

៧៣០. បងដល់សកលដែនអាយហើយ    ទាវអើយបានគេឬប្អូននៅ
ធ្វើម្ដេចឲ្យស្រេចដឹងឥឡូវ    មានស្លាបហោះទៅឲ្យដល់ឆាប់ ។

ចែវកាត់ច្រូតឆ្លងបំណាងនឹង    ទ្វិរិះជញ្ជីងប្រឹងចាំស្ដាប់
សូរខ្យល់រលកទូកស្ទើរផ្កាប់    ទុំសាប់សង្វាជាឱកម្ម ។

រូបកើតអភ័ព្វងាប់ទៅជា    នៅរស់វេទនាជាចំណាំ
ចំណែកបែកទាវស្រីស្រងាំ    ស្រងាត់ខ្វាត់នាំឲ្យវេទនា ។

ទុំរៀបរាប់ភូមិតាមទន្លេ    ហួរហែផ្សៀងផ្ទេរថាឱល្វ-
ទេរតោងកបកោងនៅរកគ្នា    ឈើចេះភ្ជាក់ងារមិនឃ្លាឃ្លាត ។

ចេះម្ល៉េះប្របេះប្របៀតបាន    ដូចសាច់សន្ដានព្រៀងលានញាតិ
រការកគិតគំនិតមារយាទ    ឈើនឹងធម្មជាតិចេះជាងគេ ។

៧៣៥. មិនដូចអរជូនខ្លួនជាមនុស្ស    មានបុណ្យសក្ដិយសខ្ពស់ចំណេរ
គ្មានគិតលិចលង់ក្នុងនិរយេ    ចំណង់ចង់ចេរមិនថេរនៅ ។

ទុំរាប់ផ្កាប់ផ្គង់ចង់ចែវចាត់    មើលទឹកស្រងាត់ស្រងោចជ្រៅ
មើលត្រើយខាងជើងត្រណឹងស្ងៅ    ឆ្លងកាត់សំដៅផ្ទះកណ្ដាល ។

ខាងក្រោយចុងបឹងប្រឹងឃ្មាតខ្មី    ទន្ទឹមឬស្សីស្រុកស្រើបស្រាល
ចាស់ក្មេងកំប្លែងលេងដំណាល    ត្រអាលសាកសួរមិនជួឆ្មើង ។

ថាអ្នកចែវទូកចូកប្រញាយ    អ្នកថ្លៃឆោមឆាយខំចែវឡើង
ហាក់ដូចរួសរាន់ទាន់ខ្យល់ប៉ើង    ចចើងចង់ឆាប់ប្រាប់ខ្ញុំផង ។

អ្នកសួរគួរដែរតែមិនស្ដី    ព្រោះទុំឃ្មាតខ្មីដោយមួហ្មង
មួយខំចែវច្រូតរូតនឹងឆ្លង    ត្រូវពាមជីកងបំណាងនឹង ។

ថែវកាត់កោះកុកកោះសុទិន   បាយផ្អិនឈប់ទូកគិតជញ្ជឹង
បានបោះបង្គោលចូលឈប់ទ្រឹង   រំពឹងសុរិយេក៏ទេរទៅ ។

បង់បាត់រស្មីព្រះសុរិយំ   ទុំភាំងទន់ខ្លួនជួនយប់ជ្រៅ
រួចបាយក្រហាយក្រហល់នៅ   ដោយត្រូវត្រជាក់ធ្លាក់ជំនោរ ។

ទុំស្រែកថាឱព្រះពាយផាត់   ទាវអើយបែកបាត់ផុំពិដោរ
ជាប់តែក្លិនក្លែបអែបគន្ធ-   រសរូបទាវចោរចើកចោលប្ដី ។

ឲ្យនៅតែឯងតែអញសោះ   ទាវគ្មានស្រណោះកោតចិត្តស្រី
ចិត្តស្រស់ឥតធ្យានគ្មានប្រណី   បានងួនជាប្ដីមិនខ្វីទុំ ។

ឱ! ទាវអើយទុក្ខបងចម្លែក   បងឡើងដល់ស្អែកទីត្បូងឃ្មុំ
ម៉្លេះសមអរជូនគេគិតគុំ   ហៅភ្ញៀវជួបជុំសម្លាប់បង ។

ស្លេះឈប់អង់សិនមិនសម្ដែង   នឹងចាប់ចារថែងទាវសៅហ្មង
ជាទុក្ខរីតខ្លាំងភាំងម្ដងៗ   ទាវផ្សងប្រាថ្នាតែប្រុសថ្លៃ ។

ប្រុសធ្លាប់ផ្ដាប់ប្អូនខ្លួនមូលមិត្រ   ឥឡូវគេគិតគ្មានសំចៃ
សមចាកព្រាត់ប្រាសគ្នាពីថ្លៃ   ប្រាសរស់ឬក្ស័យអ្នកថ្លៃប្អូន ។

ប្រុសថ្លៃមកហើយឬអ្នកនៅ   ទន្ទឹងមើលផ្លូវបាត់ឈឹងសូន្យ
រំពឹងអ្នកម្ដាយកំចាយកូន   មិនដោយជំបូនជំបន់គ្មាន ។

គាត់អាងឲ្យគេមានយសស័ក្តិ   កែវកងមាសប្រាក់ទ្រព្យធនធាន
ទុំអើយខ្លួនអ្នកខ្សត់មិនមាន   ម៉្លេះសមមិនហ៊ានរុករានមក ។

ទើបបានប្រុសបាត់ឈឹងជ្រងំ   ទុក្ខប្អូនស្មើភ្នំយំក្រំក្រោក
ទៅណាមិនដល់ខ្វល់ជ្រុលជ្រក   ប្អូននៅនឹកភ្នកគ្រប់វេលា ។

ធ្វើម្ដេចបានដឹងជាយូរឆាប់   គ្មានគេទៅប្រាប់ឆាប់មិម្នា
នឹងបានជួបជល់យល់មុខគ្នា   សោះប្អូនវេទនាជាទុក្ខខ្លាំង ។

ឥឡូវគេគិតមកឆាប់ៗ រៀបប្រុងប្រដាប់ផ្គងសម្រាំង
សម្រេចគេចូលមូលមានទាំង ឈ្មួលមហាទីតាំងបង្ខាំងទុក ។
យើងអង់ស្នេះសិនមិនសម្តែង ទាវទុក្ខម្នាក់ឯងមិនមានសុខ
ថ្លាថ្លែងសម្តែងតទៅមុខ ម្តាយទាវអផ្សុកវិតក្កប្រាណ ។
ព្រួយព្រោះនៅយូរគួរគិតដល់ ក្រហាយក្រហល់មិនបានក្សាន្ត
គាត់គិតចរចុះដើរទៅថ្កាន ដល់ឡើងលើឋានដានលំនៅ ។
ផ្ទះអរជូនជុំប្រពន្ធកូន ម្តាយទាវមិនសួន្យជំរាបទៅ
លើកហត្ថាផ្គុំផ្គងតម្រូវ ថាសូមឥឡូវខ្ញុំមកដល់ ។
៧៥៥. មិនគិតខ្មាសគេចំណោរលង់ ទោះបីខ្លៅល្ងង់តាមបន្ទាល់
ជំរាបចៅហ្វាយមិនឲ្យសល់ ងឿងឆ្ងល់ក្នុងគ្រាវេលាហ្នឹង ។
ទាន់ពារពេលាជាមង្គល ស្រេចលោកឈ្វេងយល់ខ្ញុំរំពឹង
មាននៅលោកស្រាប់ឆាប់ព្រួយប្រឹង ចៅហ្វាយតឿនតឹងទើបទាន់ចិត្ត ។
មើលពារពេលាខែថ្ងៃណា ជួបជុំមេបាដោយសុចរិត
មង្គលការនេះរិះឲ្យល្អិត ព្រោះត្បិតយូរខានមិនបានទេ ។
ទុក្ខចិត្តម្តេចទុំបារម្ភទៅ ដោយក្តៅព្រោះហេតុប្រពន្ធគេ
ខ្ញុំសូមជំរាបលាវិលវេ រិះរេចាត់ចែងក្រែងក្រក្រោយ ។
វេលាគ្រានោះឯអរជូន លំឱនអរអឹងប្រឹងបណ្តោយ
ប្រាមប្រាប់ប្រពន្ធកូនថាឲ្យ កុំធ្លោយប្រហែសធ្វេសរាល់គ្នា ។
៧៦០. ប្រាប់ស្នងបាឡាត់ចាត់មេស្រុក រកជ្រូកព្រៃកុកគោមាត់ទា
នៃប៉ូវខ្ទឹមម្រេចដំឡូងជ្វា គ្រឿងភ្លាផ្ទីផ្ទីជីរបារាំង ។
គ្រឿងទេសគ្រឿងតែងបន្លែគ្រប់ ទុកមនុស្សប្រសព្វទិញស្រាខ្លាំង
សាច់ក្រកសាបក្រៀមសាច់ចៀមអាំង បបែលទំពាំងក្រសាំងខ្យង ។

គ្រប់ម្ទេសស្លឹកគ្រៃខ្ទឹមរំដេង ក្រអៅរលីងឈ្ងួកសម្រង
ស្ពៃក្តោបស្ពៃលាភ្លាអង្គ្រង បង្កងស្នងគោន្ទុវខ្ទុរល្ហុង ។

បន្លែចិតចាក់ថែងឲ្យរក បានមកច្រកជាលហាលបម្រុង
ស្ងួតស្រួលប្រមូលច្រកការុង កុំអង់យឺតយូរគួរគិតឆាប់ ។

ខ្លះនាំឈើព្រៃឫស្សីផ្តៅ កាំបិតប៉ូវថៅខ្វិតដង្កាប់
យកទៅធ្វើរោងប្រុងប្រញាប់ ចាត់ប្រាប់ព្រៀងលានសន្តានឆ្ងាយ ។

៧៦៥. ក្នុងខេត្តប៉ុន្មានបានដឹងផង ត្បិតអ្នកជន្លងគាត់រាប់រាយ
ថារៀបអាងួនទាវឆើតឆាយ ខ្វល់ខ្វាយរួសរាន់ទាន់ពេលា ។

ចាត់រកអាចារ្យខ្មែរធ្វើធ្មេញ អាចារ្យមួយដេញថ្ងៃដោតជា
ឫក្សរួមខ្មើយខ្ពល់តម្កល់ពារ រូបរួមមូលគ្នាជាយូរទៅ ។

មនុស្សផងអឺងកងភ័យទោស រកទិញរកឈ្នៀសគ្រប់គ្រឿងគ្រៅ
បានស្រេចនាំស្រូតរូតដោយនៅ អរជូនតម្រូវតម្រេកគេ ។

រត់ឡើងប្តឹងថាមេត្តាអត់ ទុក្ខទោសកំណត់មិនធ្វេសធ្វេ
ចាត់ប្រើយើងខ្ញុំក្រុមដោយមេ ដោយមុខគិតគ្នេរគិតគ្នាសែង ។

យកដល់ទៅទុក្ខរោងចុងភៅ ប្រដាប់ណាត្រូវតាមតុបតែង
បម្រុងរៀបស៊ីស្លាកន្សែង ចាត់ចែងចែកចាំរបាំភ្លេង ។

៧៧០. នាំទៅគ្រប់គ្រឿងរឿងទាំងឡាយ ចែកចាយទ្រទ្រាំកុំនាំលេង
រោងមួយធ្ងនធំមាំល្វឹងល្វេង ម្តៃប្រាំល្វែងតែងជ្វាលា ។

អុជអស់ប្រទីបគោមរយ៉ា មេបាព្រៀងលានសម្លាញ់ភ្ងា
ចរចូលមិត្រមូលជួបជុំគ្នា ក្នុងគ្រានោះឯងមិនក្រែងក្រ ។

ទើបតែជួបជុំចូលរោងថ្មី ប្រុសស្រីចាស់ក្មេងលេងអែបអរ
ស៊ីនំស៊ីបាយស៊ីសម្ល ស៊ីខស៊ីហុងវង់ផឹកស្រា ។

ចាស់ៗប្រុសស្រីស្ដីរកគ្នា ថាយើងពេលពារវេលាណា
ឡើងចុះចំពោះលើលោកមហា ពិសារួចរាប់បង្គាប់មក ។

ថៅមហាអាចារ្យចេះគន់គិត ពិនិត្យថាយើងនឹងរិះរក
ពារពេលថ្ងៃស្អែករួចរៀបស្ដុក ឡើងយកកំណាត់ប្រាកដហើយ ។

៧៧៥. រៀបរួចស្រេចស្រាប់បង្គាប់គ្នា អាចារ្យចោទនាឆ្លងឆ្លាស់ឆ្លើយ
មេបាខាងលើពុំលង់ឡើយ រួមខ្មើយថ្ងៃណាអាចារ្យចែង ។

អាចារ្យដើមការឯខាងប្រុស ពីកាលគ្រានោះគាត់សម្ដែង
ថាឲ្យរៀបគ្រឿងគ្រប់តុបតែង តំណែងទំនៀមមិនស្មៀមស្ងាត់ ។

មានរានពេលាជាមង្គល បាយសីស្លាធម៏ស្លាប្រាំម៉ាត់
សំពត់ឆ្នេងស្ដាំចាំប្រណិប័តន៍ ប្រយ័ត្នថ្លោះធ្លោយឲ្យមនុស្សចាំ ។

នេះត្រូវចាត់អាចារ្យពេលា ខាងលើគ្រីហាតាមចំណាំ
អាចារខ្មែរខ្ទុកសសុកត្រាំ មានក្អមដាក់ថ្នាំផ្ដាំឲ្យរក ។

បង្គាប់ថាត្រូវស្រូវកញ្ចើ ឯគ្រឿងខាងធ្វើធ្មេញឲ្យយក
ចន្ទន៍សក្រហមសសំបក ឆ្លូកឆ្លូកឆ្លែកគ្នាជាច្រើនមុខ ។

៧៨០. បុកបត់កញ្ចប់កប់អង្ករ ច្រកក្នុងពកថ្ងូស្លចាកចុក
ក្នុងក្អមមានចបជីកសសុក ផ្កាប់មុខពីលើទើដើងក្រាន ។

ប្រដាប់ធ្វើរានមានរាជវីតិ ឆត្រទង់បែងបត់ដោយប្រមាណ
បាយស៊ីចំណីដាក់តុបាន រៀបបានសព្វគ្រប់ឈប់ស្លេះនៅ ។

ទើបនឹងបែរបត់ប្រាកដថា និយាយរឿងការទុកតទៅ
សម្ដែងពីទុំសម្ងំក្ដៅ ក្នុងទ្រូងដំបៅហៅពេជ្រថា ។

ពេជ្រអើយអង្គអញប្រុងប្រឹងស្ដាប់ ឮដូចសូរស័ព្ទស្គរគេការ
ទាវងួនហើយតើឈប់ដល់ណា រៀបចតទូកក្ដារយុថ្កាបោះ ។

ទុំពេជ្រលេចឮសួរទៅដល់ កើតទុក្ខស្រងល់មិនស្បើយសោះ
ទឹកភ្នែករហែងរែងស្រណោះ ថ្លែងថាឱអស់សន្តានអាយ ។

៧៨៥. គ្មានគិតទ្រូងទុំក្រំស្មើរបែក ខ្លួនអើយថ្ងៃស្អែកសមអន្តរាយ
បង់ខ្លួននឹងទាវថ្លៃឆោមឆាយ ទាវអាយគ្មានស្តាយទុំដល់តិច ។
ទុក្ខអើយពុំស្បើយដល់ប៉ុនល្អង ទុំថាមាសបងយកបង្វេច
ម្ល៉េះហើយពេជ្រអើយនឹងធ្វើម្តេច ប្រថុយតាមកិច្ចតាមកម្មខ្ញុំ ។
ទុំស្រាយបង្វេចយកសំពត់ ស្លៀកពាក់រន្ធត់ស្រេចស្រែកយំ
ដៃគរគក់ទ្រូងដៅដាលដំ ក្រៀមក្រំវិយោគសោយសោកា ។
ពេជ្រប្រាប់ថាទុំកុំយំសោក ចូរបងប្រឹងក្រោកខំកំឡា
ស្លៀកពាក់ប្រដាប់អង្គអាត្មា ឆាប់ណាអ្នកណាកុំអង់នៅ ។
ទុំឮពេជ្រប្រាប់ចាប់សំពត់ ហូលព្រែទាំងផ្ទត់ទុំមើលទៅ
យល់ឈ្នួតផាហ៊ុមសូត្រពណ៌ខ្មៅ សំពត់ព្រះថៅប្រោសប្រទាន ។

៧៩០. ទុំស្លៀកហូលចាក់ជរបីជាន់ រូបមាន់សូត្រខ្សែសយមាសមាន
ពាក់អាវបែតងបំណងធ្យាន ឈោងឈានបត់បែរប្រែស្រដី ។
ថាពេជ្រប្អូនអើយរៀបប្រដាប់ ឲ្យស្រេចឆាប់ៗពេជ្រយកប៉ី
យកចិញ្ចៀនបងទើបទិញថ្មី ទុំពាក់ម្រាមដៃត្បូងសូរ្យកាន្ត ។
ពេជ្រស្លៀកចរបាប់ចាប់អាវស្វាយ ពាក់ដើរកែក្រាយទាំងពីរប្រាណ
ចរចេរលីលាយាត្រាបាន ដល់ក្នុងស្មសានប្រមាណពេល ។
ពេលាថ្ងៃនោះឆ្ពោះប្រាកដ ពេលស៊ីកំណត់ក្រាលកន្ទេល
កំពុងផឹកស៊ីដេកននេល ទ្រហែលរាល់ខ្លួនរត់ពួនព្រៃ ។
គ្មានដឹងខ្លួនសោះគេកោះកាប់ បង់ខ្លួនទាល់ស្លាប់មិនគិតភ័យ
អាត់តែស៊ីផឹកដួលទីទៃ ខ្លះវែរត់ឆាប់ចាប់សាច់គោ ។

៧៩៥. អ្នកធ្វើឈ្នួលមយាការប៉ុន្មាន សប្បាយរាល់ប្រាណសើចចៀវឆោ
ធ្វើសាច់សាភ្លាមាន់ទាស្ងោរ ស្រុសកោរកោះវះថ្លើមស្ងួតសព្វ ។
ដំណើរទុំពេជ្រលេចពីព្រៃ គ្មានគិនភិតភ័យចូរបន្លប់
បន្លំមនុស្សច្រើនទ្រង់ចំប្រប់ គ្មានថប់ព្រួយចិត្តឥតព្រឺប្រាណ ។
ជាកម្មអកុសលផ្តល់គាត់ហើយ ជនអើយចូរស្តាប់ចាប់ចាំបាន
យកទុក្ខដាក់ខ្លួនពួនចេញថ្កាន ចៀសសង្សារសាន្តខានឃើញទុក្ខ ។
គួរយកធម៌អាថ៌ជាទីពឹង ពំនឹងសីលទានស្ពានទៅមុខ
ស្ទួសៀវចៀសចាកផុតនរក កុំធ្វើឆោតឆុកនៅខ្លៅល្ងង់ ។
កុំយកតម្រាប់គាត់ពេជ្រទុំ នៅទីត្បូងឃុំអ្នកលេងផុង
លេងភព្វស្រីទាវល្អមានទ្រង់ លិចលង់លុះបានប្រាណមរណា ។
៨០០. គ្រានោះនាអ្នកទាំងពីរប្រាណ ចូលដល់ប្រមាណពេលវេលា
សុរិយេទេរទាបប្រហែលជា ភ្ញៀវមកជុំគ្នាទំពាឡើង ។
លើផ្ទះសំពះសួរគួរគាប់ មេបាចាស់ផ្កាប់មិនជួឆ្មើង
ទុំត្រូវស្រាខ្លាំងតាំងចចើង ឬកពាហាត់ថ្កើងដំឡើងត្រូ ។
ដំឡើងគ្រប់សព្វរាប់រៀបរាយ ច្រៀងថាទាវអាយគ្មានគិតគួរ
គេចវេះស្អប់ទុំដេកទទូរ បងឡើងមកយូរហើយមិនយល់ ។
ទាវទុក្ខមុខស្ងួតរួតរីងរីត ទាវឆ្លើយឆ្លងឥតមានឆ្ងាយឆ្ងល់
ថាអ្នកថ្លៃប្អូនសូន្យទុពីល មកដល់ដៀលថាមេត្តាខ្ញុំ ។
ឥតមានហេតុសោះស្រណោះគ្រប់ រាល់ពេលថ្ងៃយប់ទុំអើយកុំ
សង្ស័យសង្សារករុណាសុំ លន់តួវាយដំខំក្សីណក្ស័យ ។
៨០៥. ទុំថាឱទាវស្រស់នួនល្អង នួនល្អហ្មត់ហ្មងដូចចរណៃ
បងមកដល់យូរគួរអាល័យ ទាវថ្លៃលាក់ខ្លួនពួនដល់ណា ។

ទាវឆ្លើយថាឆាប់ម្ដេចថ្លៃអាយ ប្អូននេះខ្វល់ខ្វាយខ្លាំងខ្លោចផ្សា
ប្អូនមួរបារីចំណីស្លា ប្អូនចេញដងស្រាពីសាលេង ។
ជូនប្រុសថ្លៃខ្ញុំសុំចិត្តម្ដង មាត់តែសាសងចេញទន្ទេង
ទន្ទឹមជិតទុំយំគគ្រេង ទុំឈ្វេងប្រណីស្រីកំសត់ ។
ទាវទ្ហួញយំសោកបោកប្រះប្រាណ រាប់រៀបដើមដានបានសន្មត
ផ្កាថ្លៃខ្ញុំអើយសមអ្នកអត់ ស្រឡាញ់ប្រាកដប្រកែកថ្មី ។
ទុំយំតបថាឱមាសបង មាសបែកបំណងមកមានប្ដី
បំណាច់ប្អូនប្រាសចាកចេញខ្មី ឱតមកបងបីស្រីសម្លាញ់ ។
៨១០. ទុំឱតជិតជួបរួមត្រកង បីហើយថើបផងថាទាវអញ
ទាវអាងទុំប្ដីឥតគិតកាញ់ ខ្លាចគេចាក់បាញ់ចាញ់នរណា ។
ទុំថាមាសបងដងស្រាមក បងដឹកសឹមក្រោកនាំកល្យាណ៍
កល្យាណទៅក្រុងគាល់ព្រះមហា- ក្សត្រាទ្រង់ប្រោសសន្ដោសទុក្ខ ។
ទាវស្ដាប់សាស័ព្ទទុំស្រដី ហុចស្លាបារីទុំស៊ីជក់
ដងស្រាឲ្យផឹកទាវមើលមុខ ឆ្អែតឆ្អល់ខ្វល់ចុកវិតក្កខ្លាំង ។
ទាវចរចូលក្នុងកំឡុងឋាន ប្រះប្រាណសោយសោកទុក្ខភាន់ភាំង
ននៀលប្រមៀលប្រឫបជញ្ជាំង ខ្លះរូតរនាំងខ្ទាំងខ្ទប់ជិត ។
នាងម្ដាយទាវទប់ឈប់មិនបាន មោហ៍មកបាំងប្រាណឲ្យងងឹត
ទោសាទោសៈមកបាំងបិទ មិនគិតមិនគន់ធន់មិនឈ្នះ ។
៨១៥. ស្រែកថាអរជូនខ្លួនមានបុណ្យ មិនគិតកែកុនឆាប់រហ័ស
ចាប់អាទុំចោរចិត្តមានះ ទាញពីលើផ្ទះទម្លាក់ទៅ ។
ហៅអស់ពួកក្រុមនាំវាឆាប់ ចាក់បាញ់សម្លាប់កុំឲ្យនៅ
ធ្ងន់ផ្ទះធ្ងន់ដីអប្រិយត្រូវ កើតកើ្ដអាស្រូវឥឡូវហើយ ។

ហ៊ានហួសនរនាទមារយាទវា ពុះពារអាងអីអាត្មាត្រើយ
កៀកកកូនអញកុំលែងឡើយ ហៅទាវឲ្យឆ្លើយកើយប្រឡែង ។
ថើបថែវសព្វសាច់ច្របាច់ដោះ គ្មានគិតកោតក្រែងកោះម៉្លោះអាងឯង
ប៉ីថើបសម្រើបធ្វើជាល្បែង គ្មានចេះរអែងក្រែងនរណា ។
កាលអើយកាលនោះឯអរជូន មុឺនងួនជាកូនគិតរៀបការ
បង្កើតអកុសលដល់អាត្មា ឥតមានករុណាមេត្តាទុំ ។
៨២០. ទុក្ខម្ដោទោម្ដេញក្នាញ់ឆុរឆាវ កន្ត្រាក់បានដាវស្ទុះចូលជុំ
ចូលចាប់ចាក់កាប់ឥតជំនុំ ចង់ទុំក្រញឹតស្លឹតស្លាបសេក ។
ទាវឮគេថាចោមចាប់ប្ដី ក្ដួលក្ដៅទាវស្រីនឹកសង្វេគ
ទុំថាទាវអើយសមបងបែក បងលាទៅដេកលើផែនដី ។
គេចាប់វាយដំក្រំសព្វសាច់ ឈាមហូរគ្មានដាច់បែកសិរសី
ឈាមកកខាន់ស្ទះបម្រះស្ដី ផ្ដែផ្ដាំទាវស្រីប្ដីលាប្អូន ។
នៅចុះណាំនួនស្ងួនសម្លាញ់ គេចាក់គេបាញ់បងស្លាប់សូន្យ
ស្លាប់គឺគាត់ម្ដាយកំចាយកូន ឲ្យសូន្យបាត់ឈ្មោះមិនរស់នៅ ។
ទាវឮអង្វរគេទៅថា សូមលោកករុណាមេត្តាទៅ
ចងទុំលោកកុំចងនឹងផ្ដៅ ចងនឹងឈ្នួតខ្មៅប្រោសប្រទាន ។
៨២៥. គេចោមចាប់ទុំចងនឹងខ្សែ ចាក់មុខបង្អែឥតគិតធ្យាន
គិតធ្យោគប្រណីដល់តិចគ្មាន ធ្វើទោសបំពានឥតមានខុស ។
ទុំឈឺជម្ងឺងើងងឹតមុខ ឈាមចុកឆ្អល់សៀតក្ដៅដូចស្រុស
ដូចស្រេកទឹកពេកណាផ្លាយពោះ សាច់សុសធ្លុះសាច់ដាច់សរសៃ ។
សោះសោកវិយោគយំខ្សឹកខ្សួល ដុនដាបដល់ដួលអួលលើកដៃ
ប្រណម្យបង្គំព្រះរ័តន៍ត្រៃ ទ្រទ្រង់សព្វថ្ងៃថ្លែអនេក ។

ម្ចាស់អើយបើខ្ញុំនឹងមរណា សូមម្ចាស់ជួយជាបន្ទាយដែក
ផាត់ទាត់ទោសទុក្ខសុខដោយឡែក សូមចែកចាកបានឋានសួគ៌ា ។

មនុស្សចាប់ចំណាប់ពួកពូកែ មានគួរខ្លះដែរជូនកាចជា
វាប្រាប់ថាទុំខំភាវនា យកព្រះធម្មាវេលាហ្នឹង ។

៨៣០. នាំដល់ខាងថ្នល់នៅទីល្ហាល បៀតពោធិជើងខាលដួលភ្លឹកភ្លឹង
ប្រុះប្របហាបផុតរលត់ឈឹង ខ្យល់ចេញរឹងៗសន្ធឹកស្កូក ។

ស្លាប់ផុតរលត់សង្ខារា រូបទុំអនិច្ចាដូចដំបូក
ដំបន់នៅជុំជាមនុស្សលោក រាប់អានគរគោកយោគប្រណី ។

ស្រឡាញ់ស្នាលស្និទ្ធឥតមានមោះ ទុំស្លាប់នេះខុសពីព្រោះស្រី
សម្លាប់សង្ហារនាលោកិយ លោកអើយគប្បីវេះវាងវៀរ ។

មនុស្សនាំទុំយកទៅសម្លាប់ ស្រេចស្រាប់ក្រឡាប់មកម្ចីម្នា
ដល់រោងដល់ផ្ទះសំពះគ្នា សួរសងសន្ទនាគ្រានោះឯង ។

លុះពេលវេលាជាយប់យូរ ទាវដេកទទូរទុក្ខចំបែង
នាងនោភីលៀងឆៀងសម្តែង ទាវអើយបងឯងគេងលបស្តាប់ ។

៨៣៥. ពួកគេខ្សឹបខ្សៀវជៀវជុំៗ ថាចាប់យកទុំទៅសម្លាប់
ពេលស៊ីកំណត់គេព័ទ្ធចាប់ នាំទៅប្រញាប់ដូចចិន្តា ។

ទាវឮនោស្តីថាប្តីស្លាប់ ទាវស្ទុះឡើងឆាប់ស្រែកខ្ទញថា
ឱប្រុសសម្លាញ់ពេញស្នេហា ប្រុសអើយកាលណានឹងយល់មុខ ។

ប្អូនស្តាយប្រុសថ្លៃអាល័យពេក ស្តាយណាស់នឹងដេកធ្មេចមិនលក់
ពេលស៊ីប្អូនអត់បទតែទុក្ខ ទុំឆ្មុកឆោតឆុងផុងដល់ក្ស័យ ។

ទុំអើយប្រុសធ្លាប់រាប់អានខ្ញុំ មិនដែលវាយដំហេតុអាល័យ
ប្អូនចាំមើលផ្លូវរាល់ខែថ្ងៃ ស្តាយណាស់ប្រុសថ្លៃសង្ស័យមក ។

តាមខ្ញុំប្រុសទុំមិនដាច់ចិត្ត ដល់បង់ជីវិតគេនាំយក
ទៅចោលក្នុងព្រៃថ្លៃពន្លក ទុំអើយអ្នកជ្រកដេកដោយដី ។

៨៤០. ប្រុសយកប្រិថពីជាពូកខ្នើយ ទុំអើយប្រុសយកពពកខ្មី
បាំងជាពិតានស្មសានព្រៃ ត្រឈឹងត្រឈៃព្រលឹងប្អូន ។

ទុំអើយម្លេះហើយទាវមិនរស់ សូវស្លាប់តាមប្រុសឲ្យសោះសូន្យ
ម្ដាយឥតមេត្តាករុណាកូន មិនដោយដំបូន្មានប្រដៅ ។

ម្លេះហើយម៉ែអើយម៉ែនៅចុះ ខ្ញុំរស់គ្រាន់ម៉ែរាប់រកហៅ
ឥឡូវម៉ែចិត្តដូចចិនឆៅ កើតក្ដៅព្រោះខ្ញុំមិនព្រមងួន ។

អើនឹងខ្លួនម៉ែការនឹងគាត់ ទទួលកំណត់រួចប្រុងខ្លួន
បទអុយប្រថុយត្បិតជួបជួន ភៀវមកក្រាស់ក្រួនងួនកម្លោះ ។

ខ្ញុំសូមលាស្លាប់ថ្ងៃនេះជាក់ ដូចហាក់អកុសលផ្ដល់ផ្ដាច់សោះ
នោះហើយខ្ញុំផ្សងនឹងផ្លេកផ្លោះ នោកុំស្រណោះណាំនោណាំ ។

៨៤៥. ទាវផ្ទប់ឈប់អង្គផ្ចង់ចិត្តខ្មី លើកហត្ថទាំងទ្វីដាក់សិរសា
ប្រណម្យហើយមានវាចាថា ខ្ញុំសូមនមស្ការដល់ព្រះពុទ្ធ ។

ព្រះធម៌ព្រះសង្ឃអង្គអរហន្ត នៅក្នុងបច្ចុប្បន្នសូមចំហុត
អង្គឥន្ទទេវិន្ទទាំងទេវបុត្ត សូមជួយឆាប់ឆុតដូចសច្ចា ។

ខ្ញុំផ្សងបំណងនឹងលាក់ខ្លួន ពីងពួនឲ្យបាត់សូមទេវតា
បាំងខ្ញុំកុំឲ្យមាននរណា យង់យល់ដូចថាចិន្ដាផ្សង ។

នោអើយសូមនោបងអាណិត ទៅយកកាំបិតស្លាឲ្យផង
នោបានកាំបិតចេញទាំងសង បំណងចរចុះឆ្ពោះដើរទៅ ។

ដល់វាលចូលព្រៃរំពៃទុំ ឃើញក្មេងជៀរជុំវាលេងនៅ
ឃ្វាលគោក្របីក្រែងស៊ីស្រូវ ទាវឈរស្រែកហៅមកប្រញាប់ ។

ទាវសួរដោយគួរហើយសាស័ព្ទ ថាចូរប្អូនស្ដាប់បងរ៉ាប់រ៉ាយ
ប្អូនទៅដល់ផ្ទះអ្នកជាម្ដាយ ក្មេងអាយចូលដល់ទាល់ផ្ទះការ ។

កំពុងតែស៊ីខ្លះគេផឹក រអឹកចូរប្អូនអ្នកច្រៀងថា
អស់លោកចាស់ទុំស្ដាប់ខ្ញុំរ៉ា លោកការនរណាទាវទៅក្ស័យ ។

មូលមួយនឹងគ្នាជាបីប្រាណ ស្លាប់ក្នុងស្មសានតាំងពីថ្ងៃ
ដែលលោកយកទុំទៅប្រល័យ ស្លាប់តែហោងហោមក្រោមដើមពោធិ ។

ចាំណាំក្មេងណាំបងលាអ្នក យកចិញ្ចៀនពាក់ដើរឃ្វាលគោ
ទាវដើរទៅដល់យល់ជ្រងោ ខ្មោចទុំហៅនោយកកាំបិត ។

ទាវប្រះប្របប្ដីដៃប្រវា បានកាំបិតស្លាអាឆៀងនិត
ត្រូវដាច់បំពង់កក្ស័យពិត កៀកកិតកើយគងទំនងជុំ ។

ទាំងបីស្រីប្រុសស្រុះខាងស្លាប់ ខ្មោចទុំគេកាប់គ្មានជំនុំ
ឯខ្មោចស្រីៗស្លាប់ព្រោះទុំ ទៅជុំចាក់កអន្ដរធាន ។

តាំងថ្លែងពីក្មេងតែងចាំជាក់ ពាក្យទាវវរលក្ខណ៍ចាំមិនមាន
ភ្លេចសោះចំពោះឡើងរុករាន វាហ៊ានអង្គុយប្រថុយថា ។

ច្រៀងជ្រួចគ្រលួចគ្រលែងក្បាល នៅក្នុងកណ្ដាលវង់ភ្លេងការ
ស្រែកឡើងកន្លែងហៅមេបា ឱអស់លោកតាលោកយាយខ្ញុំ ។

ស្ដាប់ចុះប្រុសស្រីសេចក្ដីហ្នឹង រំពៃរំពឹងគួរឈប់កុំ
លោកការនរណាទាវជ្រងំ ផ្ដាំខ្ញុំមកប្រាប់ស្លាប់មូលគ្នា ។

មេបាខ្លះស្ដាប់មិនទាន់ជាក់ ទំលាក់ចានចោលឈរក្រទា
ថាវ៉ឺយកុំមាត់ចាំស្ដាប់វា ស្ទុះមកម្ទីម្នាធ្វើក្រញូវ ។

សួរថាអាវ៉ាច្រៀងម្ដងទៀត សង្កិនសង្កៀតអាកូនឪ
ឲ្យច្បាស់បានបាយស៊ីឥឡូវ បើត្រូវមិនអីទេអានាង ។

ក្មេងច្រៀងម្តងទៀតត្បៀតសំឡេង	លាន់ឮប្រែផ្សេងឆ្លើយវាសវាង
លោកអើយទុំទាវស្លាប់ចង្ក្រាង	ស្លាប់ទាំងខ្លួននាងនៅខ្ញុំស្រី ។
ខ្ញុំស្រែកស្រាបាយតាអើយយក	សុំបាយមួយស្ពកមានចំណី
មានសាច់ជ្រូកក្តាន់មាន់ទាត្រី	ក្មេងស៊ីចំណីលែងស្តីសោះ ។
នាអ្នកទាំងឡាយប្រញាយទៅ	មើលក្នុងលំនៅឈ្វោកគៀនកោះ
រកទាវនឹងនោឥតចន្លោះ	មិនអស់ចិត្តជឿក្មេងស្រដី ។
កញ្ញាស់ជាម្តាយក្រហាយប្រាណ	ក្តៅដូចភ្លើងក្រានឆេះឆួលស្រី
ម្តាយទាវទទ័រញ័រសិរសី	ស្ញើតស្លក់ឥតបើឥតបានយល់ ។
៨៦៥. ជាទុក្ខមុខស្ងួតរួតរឹងខឹង	ក្រញេវក្រញឹងរឹងខ្វាយខ្វល់
ជេរគេឥតក្រែងថាង៉ែងស្គាល់	ដឹងទេនៅផ្ទាល់ផ្សៀងមើលវា ។
ទាំងអស់មេឯងឥតគំនិត	កំណើតទុកចិត្តវារាល់គ្នា
មេចោរចើកចាប់កាប់ពុះពារ	អំបែងក្បាលជាប្រាំពីរភាគ ។
ហាងឯងហ៊ានឲ្យកូនអញបាត់	មិនមានប្រយ័ត្នបានតែពាក្យ
ជំហរតែភូតស៊ីចុះរាក	ងងាកឃើញប្រុសស្ទុះចន្លន់ ។
មិនដឹងអីសោះកំឡោះពាល	ឃើញហើយរោលរាលចើកគ្មានអន់
ហ៊ានមនុស្សប៉ុនគ្នាមើលមិនទាន់	ហាងហ៊ានថាភាន់ដូចមាន់ទា ។
មេដែងបាវខ្ញុំជុំប៉ុន្មាន	ឆ្លើយថ្កានថាធំកុំខំពារ
យើងមនុស្សមិនខ្មោចទេរាល់គ្នា	ទាវជាកូនគាត់ប្រាកដថា ។
៨៧០. នាងចុះទៅនោះជុះទេតើ	យើងខ្ញុំបានស្មើគ្រប់ប្រការ
ប៉ុន្តែប្រកែកថ្វីយាយតា	ធម្មតាវីមនុស្សខុសចិត្តគេ ។
ឯយាយហ្នឹងទៀតឆ្មៀតរៀបទាវ	ធម្មតាឈាមវាវគ្មានចេះគ្មេរ
ខឹងខ្លាំងទៅតាមខូចមិនមេ	បាជេរប្រដៅហៅតែស្តី ។

គ្មានចេះស្តាប់យកពាក្យនរណា យាយតាទៀតដែរដឹងសេចក្តី
ទាវនេះជាក់ច្បាស់ជាមានប្តី ហ្លួងប្រោសប្រណីថ្វីមិនដឹង ។
ម្តាយទាវស្តាប់ជាក់ស្ទើរធ្លាក់ថ្លើម ទាវអើយពីដើមកូនចិត្តផ្សឹង
កូនកាត់ពីម្តាយឆ្ងាយដូចឆ្អឹង ម្តាយរឹងនឹងព្រោះចំពោះប្រាប់ ។
ម្តាយថាឲ្យកូនស្ងួនទៅគេ ម្ល៉េះហើយគេជេរគេចាក់កាប់
គេបាញ់គេបោះគេកោះចាប់ សម្លាប់ទៀតទេគេផ្តាសា ។
៨៧៥. ម្តាយនឹងប្រថុយខុសអុយចុះ ឲ្យតែកូនរស់បានរៀបការ
បំណាច់អរជូនបង់បណ្ណា ចិញ្ចៀនខ្សែចារុំប្រាថ្នាជូន ។
ឲ្យកូនពាក់ទ្រង់អង្គកាយា របស់គេថាជាជំនួន
ឥឡូវមាសថ្លៃទៅក្បួយសូន្យ ទាវកូននាងទុកតែគ្រឿងគ្រប់ ។
កាលនោះម្តាយទាវទុក្ខម្នាក់ឯង ចំបែងវិលវល់ខ្វល់មិនឈប់
ដើរដួលខ្នាញ់ខ្នួលទាំងថ្ងៃយប់ គិតសព្វដើរទៅហៅគេឯង ។
កាយនោះអស់មនុស្សការប៉ុន្មាន ចោលចានដបល្អីចាប៉ីច្រែង
ចោលឆ្នាំងចោលខ្ទះរះទាត់ប៉ែង ខ្លះសែងសាច់គោស្ងោរស្រុសស្រាប់ ។
ភ័យខ្លួនពួនជ្រករត់រកហៅ កូនចៅទៅផ្ទះរហ័សឆាប់
ចូលព្រៃរំពៃខ្លាចគេចាប់ សម្លាប់ដូចទុំជំនុំគ្នា ។
៨៨០. ឧកញ៉ាអរជូនងួនកូនគាត់ ខឹងណាស់ខំអត់ស្ទុះម្នីម្នា
ចរចេញទៅដល់ទើបស្គាល់ជា ទុំទាវនោវាមរណាពិត ។
ចូលទាញខ្មោចទុំដែលរុំនៅ គិតគ្នាយកទៅកប់ឲ្យជិត
ស្រាយយកផាហ៊ុមមើលពិនិត្យ យល់ជ្រុះធ្លាក់ស្បិតគិតសង្ស័យ ។
លួកហត្ថប្រញាប់ចាប់លាកលា មើលដឹងស្គាល់ជាបន្ទូលថ្លៃ
អរជូនភ័យខ្លួនខ្លាចលើកដៃ សំពះនិស្ស័យដល់ចេស្តា ។

កប់ខ្មោចវិលមកបានដល់ផ្ទះ ចង់ឈ្នះហៅម្ដាយទាវប្រាប់ថា
កញ្ចាស់ចោរចើកបើកចង្ក្រា ហ៊ានពេកណាស់សាប្រាជ្ញាវា ។

ឃើញអញមានទ្រព្យផ្កាប់តម្រូវ ថាដូចបង្ខូចពូជមាយា
មារយាទកញ្ចាស់ច្បាស់ជាក់ជា បញ្ចូលអ្នកងារទាំងវាឯង ។

៨៨៥. រឿងនេះបើថ្លែងរឹងវែងទៅ អង់ស្ងេះឈប់នៅមិនសម្ដែង
យើងនឹងតាំងទៀតផ្លៀតចារចែង នឹងថ្លែងពញាពេជ្រលេចពួនព្រៃ ។

ពួនប្របខ្លបខ្លាចបុណ្យអរជូន អាង្គួនជាកូនគិតបំភ្លៃ
បំផ្លាញជីវិតទុំគិតតែ គិតកើតមានភ័យដល់រាល់ប្រាណ ។

ពេជ្រគិតថ្មោះស្រេចត្រាច់ម្នាក់ឯង ក្នុងព្រៃត្រោកត្រែងត្បែងជើងក្រាន
ឈើទាលឈើទាបក្នុងស្មសាន ចុះថ្កានដល់ទូកប្រេះស្ដូកស្ដឹង ។

ជាទុក្ខមុខស្ងួតរួតរឹងរិត ភ័យភិតស្ទើរបែកបាត់ព្រលឹង
ព្រលប់យប់យូរស្ងាត់សូន្យឈឹង ពេជ្ររឹងសង្វេគបែកបាត់ទុំ

ពេជ្រផ្ទប់មិនបានប្រាណវិតក្ក នឹកដេកមិនលក់មុខក្រៀមក្រំ
លើកដៃគងថ្វាសស្រឡះយំ ទុំអើយចោលខ្ញុំក្រំចំបែង ។

៨៩០. ស្រឡាញ់ប្រាកដក៏ព្រាត់ទៅ ទុំអើយពេជ្រនៅតែម្នាក់ឯង
ប្អូនដេកដោយដីព្រៃត្រោកត្រែង សព្វសត្វក្អែកខ្លែងតែងជាគ្នា ។

ខ្ញុំនាំប្រុសថ្លៃទាំងថ្ងៃយប់ មិនឈប់ដើរលេងគ្រប់វេលា
តាំងតែពីយើងនៅវិហារ ធំបិតជុំជាមិនដែលហ្មង ។

មិនដែលមានបែកចែកចាកឋាន លុះបានហ្លួងទ្រង់ជ្រាបជាម្ដង
ទុំអើយយើងចូលគាល់ក្សត្រច្បង ប្រឡងចំណោះចេះជាងគេ ។

ហ្លួងទ្រង់សន្ដោសប្រោសប្រណី ប្រទានទាវស្រីព្រះទ័យត្មេរ
មេត្តាទុំពេជ្រគេចមិនថេរ ង្គួនឯងបង់កេរ្តិ៍ចំណោរទៅ ។

ពញាពេជ្រគេចមុខទុក្ខទួញយំ　　លើកដៃបង្គំប្រណម្យនៅ
ថាខ្មោចទុំអើយប្អូនឥឡូវ　　ថ្ងៃនេះខុសត្រូវខ្ញុំសូមលា ។
៨៩៥. ទុំអ្នកនៅចុះប្រុសថ្លៃខ្ញុំ　　ចរទុំកុំចងពៀរវេរា
ឡើងទៅសោយសុខឋានសួគ៌ា　　យើងសូមជួបគ្នាជាតិក្រោយទៀត ។
នេះនឹងស្រដីដំណើរពេជ្រ　　រិះរៀបធៀបគេចមានស្មើស្មៀត
ថ្លាថ្លែងពេជ្រទុក្ខតឹងចង្អៀត　　ខំឆ្លៀតឆ្លើយប្រាប់បង្គាប់គ្នា ។
ជាគូកនភឿនតឿនប្រញាប់　　ពេជ្រប្រាប់ថាស្រាយទូកម្ទីម្ទា
ពាក់ចែវបង្គោលដោលចេញជា　　កុំឲ្យយូរយាររាចេញទៅ ។
កនពេជ្រស្រុះស្រេចស្រីបរញ្ញី　　កាប់ចែវផ្អើលត្រីរត់ស្លុងស្លៅ
ខ្លះមុជខ្លះហែលចូលជ្រកស្មៅ　　ចែវកាត់សំដៅជ្រោលន្លង់ ។
សន្ទឹមលេចដល់ក្បាលកោះស្វាយ　　សុរិយេទេឆ្ងាយបែរបៀតវង់
ចំទិសបច្ចិមេជ្រេសំយុង　　សុរិយេបាត់អង្គក្នុងគិរី ។
៩០០. ខិតខំចែវជឿនលឿនទៅបាន　　ឈប់ទូកសម្រាន្តក្នុងជលធី
អែបអបប្របច្រាំងតាំងគិតស៊ី　　ពេជ្រនឹកដើមពីទុំកំសត់ ។
ពេជ្រពុំស្រេកឃ្លានគ្មានស៊ីសោះ　　រីងរីតស្រណោះផ្អស់ប្រាកដ
នឹកដើមដល់ទុំយំខំអត់　　ទុំអើយបងព្រាត់បាត់ទៅណា ។
ពុំឃើញទុំពិតជីវិតថ្លើម　　ប្រុសឆ្មើមប្រាសឆ្នែងបែងបេក្ខា
បែករស់ជាមនុស្សប្រុសមិនថា　　ទុំប្រាសសង្ខារអស់សង្ស័យ ។
ហ៊ានបង់ជីវិតមិនគិតគ្នា　　ផ្តាច់ប្តូរជន្មាដល់ក្សិណក្ស័យ
គ្មានគិតគ្នាន់គ្នេរគែលកលៃ　　ព្រោះទាវចង្រៃម្តាយផ្តែផ្តាំ ។
មកដល់អកុសលផ្តល់ទាំងគ្រប់　　គេនៅប្រទប់ហេតុមិនចាំ
លោកគ្រូគួរលេខថាមានកម្ម　　ពាក្យត្រូវដាក់ដាំថ្នាំឱសថ ។

៩០៥. មួយទៀតដូចដែកដុលប្រហារ    វាយលើនរណាស្លាប់ផុងផុត
មិនគង់ជីវិតដូចកុលបុត្រ    តាមធម៌ព្រះពុទ្ធទ្រង់សម្តែង ។

លុះព្រឹកព្រាងព្រះរះសូរ្យសាយ    ពេជ្រក្តៅក្រហាយតែម្នាក់ឯង
ប្រាប់គ្នាថាយើងខំស្វះស្វែង    ស្រួតរូតតឹងតែងក្រែងពុំដល់ ។

អ្នកចែវប៉ុន្មានមិនបានឈប់    លង់លុះព្រលប់ជិតស្រងល់
ស្រងាត់បាំងបាត់ចូលសកល    ទៀបទាល់ក្បែរខាងស្វាងរស្មី ។

រើរៀបប្រដាប់ចាប់ចែវលី    ចរចូលមន្ទីររំពេចឱ្មី
ខ្លះបែកទៅផ្ទះសំពះស្តី    ស៊ើបសួរគួរបីបត់បែកគ្នា ។

ទើបមនុស្សទាំងឡាយពីអាយជុំ    កាលទៅត្បូងឃ្មុំបានសុខជា
ខ្លះប្រាប់ថាទុំគាត់មរណា    រួចលាចរចូលព្រះមហាក្សត្រ ។

៩១០. ឡើងដល់ដាក់អង្គផ្គង់ហត្ថា    លើកលើសិរសាក្រាបប្រណិប័តន៍
បង្គំទូលថាទ្រង់ត្រាស់ចាត់    បន្ទូលបញ្ញត្តិសត្វជាខ្ញុំ ។

ក្រោមល្អងធូលីទីទុក្ខា    អរជូនប្រហារជីវិតទុំ
តាមទ្រង់ប្រណីភ័យបារម្ភ    ប្រោសសុំជីវិតឋិតតទៅ ។

ទុំស្លាប់ព្រមគ្នាជាបីប្រាណ    ប្រុសស្មានជាទាវនោរស់នៅ
មិនដឹងកាលកម្មនាំមកត្រូវ    ឥឡូវទាវនោក៏ស្លាប់ដែរ ។

ស្តេចទ្រង់សណ្តាប់ពេជ្រថ្លាថ្លែង    ទ្រង់ខ្ញាល់ស្ងប់ស្វែងប្រាប់ថានែ
ប្រាប់ក្រុមកាំភ្លើងគ្រឿងសំសែ    មហាតលិកដង្ហែឲ្យរួសរាប់ ។

ទៅហៅឧកញ៉ាវាំងចក្រី    ក្រឡាហោមក្តីឲ្យប្រញាប់
ឲ្យរៀបទីនាំងតាំងសម្រាប់    ប្រដាប់ដើងទឹកព្រឹកនេះហើយ ។

៩១៥. ប្រាប់កងសេនាពួកទាហាន    ពុំមានបង្អង់ឲ្យលង់ឡើយ
ទៅចាប់អាចោរចិត្តឥតត្រើយ    ហ៊ានហើយប្រឡេះជាផេះផង់ ។

វាហ៊ានទទឹងនឹងអញច្នោះ    ទោសកាប់ស្មោរស្រុសវាស់ជីកបង់
ជីកបុកក្នុងដីក្ស័យរូបអង្គ    កុំសង្ស័យសោះអាអរជូន ។

ហ៊ានហែកដុតចោលបន្ទូលអញ    ទោសវាចងចាញ់អាងួនកូន
ធ្វើទុក្ខធ្វើទោសឲ្យអស់សូន្យ    សន្តានបងប្អូនបញ្ចូលងារ ។

គ្រានោះនាម៉ឺនរឿនហ្លួងស្តាប់    បន្ទូលថ្លែងប្រាប់ឱនលូនវារ
ថយទៅដល់ផ្ទះជួបជុំគ្នា    ជាឆាប់ម្ទីម្នាមិនរារង់ ។

រួសរាន់ឲ្យទាន់តាមបញ្ញត្តិ    បន្ទូលស្តេចចាត់ឲ្យប្រៀបប្រុង
ប្រៀបប្រាប់ប្រដាប់ទុកបំរុង    សព្វសាច់ហាន់ហុងការុងចាន ។

៩២០. ច្រកស្បៀងលៀងលំព្រមពួកបោយ    ពួកបង់ព្រះស្មោយគ្រឿងប៉ុន្មាន
រៀបរួចរាចូលឡើងទូលថ្កាន    ក្សត្រក្សាន្តទ្រង់ជ្រាបរៀបព្រះអង្គ ។

ទ្រង់អស់គ្រឿងគ្រប់សព្វសុទ្ធមាស    មកុដកែវសោភាសស្រស់បញ្ចង់
ទ្រង់ព្រះទម្រង់វជីរផ្គង់    ពាក់មាស១០ស្រង់ស្រប់ភក្ត្រា ។

ស្រាប់ស្រេចស្តេចគង់ប្រថាប់នៅ    ត្រាស់ហៅមហេសីស្រីកញ្ញា
ត្រាស់ទ្រង់ថានង្គនួនជីវា    ជីវិតកនិដ្ឋានបាបុត្រច្បង ។

នៅចុះណាំនួនស្ងួនពន្លក    កុំភ្នកគិតនឹករឭកបង
នួនអ្នករក្សារាជ្យស្នាប់ស្នង    វាំងវេនក្រុមកងពួកពលពង្ស ។

រលឹកដាស់តឿនរឿនក្នុងក្រៅ    ចាត់ហៅប្រយ័ត្នប្រយោជន៍គង់
កេរ្តិ៍ឈ្មោះចំពោះលើឆោមយង់    រ៉ាប់រងចាំចាត់ភ្លាត់រក្សា ។

៩២៥. អញទៅមិនយូរប៉ុន្មានទេ    វិលវិញឆាប់ដែរកុំសង្កា
ត្បិតអញទ្រង់រាជ្យជាក្សត្រា    នៅចុះព្រះមហាអគ្គមហេសី ។

ផ្តាំស្រេចសម្តេចព្រះរាមរាជ    ទ្រង់មានអំណាចលើផែនដី
ផែនដិនទេវិន្ទព្រះចក្រី    យាងចាកចុះទីលីលាដល់ ។

យាងយាសវាសវង់វាំងជុំបី　　អស់ពលសេនីយ៍តាំងតម្កល់
តម្កើងគ្រឿងហែក្បែរខាងថ្កល់　　ទៀបទាល់ទីនាំងតាំងភូមា ។
បីបទប្រាកដបាញ់កាំភ្លើង　　ក្សត្រថ្កើងយាងឡើងគង់នាវា
ទីនាំងសម្រាប់ព្រះរាជា　　ពលចុះជុំគ្នារាចែវចេញ ។
ទន្ទេងទន្ទាំលលាំទៅ　　ស្លុងស្លៅលឿនលយក្រោយប្រដេញ
ប្រជិតទីនាំងក៏ស្លុងស្លេញ　　លលេញលលោលលាន់ក្តុង ។
៩៣០. គង្គានាវាព្រះមហាក្សត្រ　　ពួកពលពិជាតក៏ប្រៀបប្រុង
ប្រលោកប្រលែងព្រះនោមយង់　　ប្រាជ្ញប្រុងបើកបទប្រាកដថា ។
សកវាទីឱណាំព្រះចមភព　　ជាម្លប់គ្រប់ដែនដែនទិសា
ព្រះចៅរាមរាជអំណាចក្លា　　ចេស្តាអានុភាពប្រៀបពុំបាន ។
សកវាទីព្រះពាយជាយពពក　　សាត់មកបាំងសែងព្រះសូរ្យឆាន
ត្រជាក់ហាក់អ្នកបក់ផាត់ប្រាណ　　ម្ចាស់ក្សាន្តព្រះទ័យឥតអ្វីឡើយ ។
សកវាទីយើងខ្ញុំក្រមុំក្មេង　　សម្លេងមិនមានណាំម្ចាស់អើយ
ត្បិតយប់ងុយងប់ឈ្លប់ណាស់ហើយ　　ប្រះកើយស្តេចគងទំនងស្រួល ។
ទើបស្តេចប្រែអង្គទ្រង់ត្រាស់ផ្ទំ　　សម្ងំពុំក្សាន្តវិតក្កខ្វល់
វិតក្កគ្មានល្ហែអន់អាក់អួល　　ប្រែប្រួលក្រោកក្រេសរវៀសវៃ ។
៩៣៥. រវល់ខ្វល់គិតដល់មុឺនឯក　　ស្លាប់បាត់ខ្ចាត់បែកព្រះជៀស្ធជ័យ
ចៀសចាកចោលក្សត្រស្វាត់ព្រះទ័យ　　មមៃមាញឹកនឹកដល់ទុំ ។
ដល់ទៀតហៀបហាក់ត្រជាក់ទន់　　សុរិយេបៀតមណ្ឌលប្រជុំ
ប្រែជិតងងឹតពួកបោយភ្ញុំ　　បង្គំលើកហត្ថចាត់ហុចគ្នា ។
ថ្វាត់ថ្វាយព្រះស្ងោយស្តេចសោយក្សាន្ត　　ក្រមការប៉ុន្មានប្រជុំគ្នា
មេដែងក្មេងស្រីប្រាំបីជា　　តែសព្វគ្រប់ពារគ្រប់ពេលផ្ទំ ។

ចូលដល់គាល់អង្គព្រះចមចក្រ ចមចៅរិទ្ធិស័ក្តិអង្គបរម
គាល់ជិតបៀតអង្គករផ្គងផ្សំ សម្លេងក្រមុំត្រសុំសាយ ។
សកវាទីយើងខ្ញុំបង្គំគាល់ បង្គំជិតផ្ទាល់ព្រះនោមឆាយ
ព្រះនោមឆើតបាត់ហាក់បែកឆ្ងាយ បែកបាត់អង្គកាយទ្រង់ស្តាយទុំ ។

៩៤០. ស្តេចស្តាយឆ្ងាយប្រាណពុំបានសុខ ប្រះផ្ទំមិនលក់ភ័ក្ត្រក្រៀមក្រំ
ជព្រួំរលឹកស្ទើររលំ មិនសមបីបែកបង់អសារ ។
អសោចីខ្លោចខ្លាំងភាំងម្តងៗ ក្សត្រច្បងទ្រង់ថ្ងូបខំកម្លា
ពួកពលប៉ុន្មានដែលត្រូវការ ប្រឹងព្រួយត្បិតការរាជការស្តេច ។
ចែវព្រះទីន័ងទាំងតែសាយ គេហៅមិនឆ្ងាយលឿនរដាច់
រដែតតាមក្រោយរជយត្រាច់ រហិចរហាលបានដល់កោះ ។
រៀបរៀងឲ្យទៀងទូលចមភព ជាម្លប់ផែនដែនសែនស្រណោះ
សេនាទាំងឡាយក៏រាប់អស់ ចេញស្មោះគិតស្មានប្រមាណចាំ
ទ្រង់សួរកោះនេះតើឈ្មោះអ្វី សូមទានពុំចេរតាមចំណាំ
ព្រែកពោធិតាឯកព្រែកតាអាំ វការទោតាមទៅរកគ្នា ។

៩៤៥. ស្តេចសួរដោយគួរថាអ្វីទៀត នាយឮបែរបៀតទូលម្ចីម្នា
ក្រាបទូលត្រើយខាងជើងនិងយារ ជ្រុះកងភ្នាក់ងារជាយូរថ្ងៃ ។
សួរស៊ើបទើបអ្នកម្ចាស់កងឆ្លើយ អ្នកអើយជ្រុះត្រង់ណឹងអ្នកថ្លៃ
ក្រាបទូលគេយកពាក្យឧបមេយ្យ ប្រស្រ័យឲ្យឈ្មោះចំពោះត្រង់ ។
អ្នកទូលស្រួលទៅតាមប្រថុយ ប្រាសហ្នឹងព្រែកកុយទូលព្រះអង្គ
ទៅមុខនោះទៀតមិនបែកបង់ តម្រង់តម្រូវឥឡូវដល់ ។
ឈ្មោះស្រុកថ្លុកជ្រៅត្រូវជាម្តង ព្រែកពាមជីកងទូលគ្មានសល់
រាប់ខាងទៅលើឥតទើសទាល់ សកលទៀតទេរជីហែហើយ ។

ទៅទៀតដល់ភ្លាមពាមផ្កាយម្រេច ទើបស្ដេចតើនចាកបន្ទំសៀ្បយ
ស្រឡះស្រប់ស្រង់ពុំលង់ឡើយ ទ្រង់សួរពេជ្រឆ្លើយទូលសាសង ។

៩៥០. ពេជ្រប្រែឆ្ពោះភ័ក្ត្រហាក់ខ្វាល់ខ្វេរ វារចូលស្លុងស្លេវក្រាបទូលឆ្លង
ថាទានស្មាក់ស្មើរប្រោសក្រោមល្អង ល្ហចណាស់ជាម្ដងយាងពុំបាន ។

ទើបអស់ពួកពលក្រុមព្រះស្នោយ ពួកបោយរៀបភាជន៍ស្ងោចខាត់ចាន
ខាត់កែប្រដាប់ទាំងប៉ុន្មាន ដាក់គ្រឿងពេលស្ពានកំសាន្តសោយ ។

ចាត់ហៅក្រុមភ្លេងក្មេងពិផាត រើសរករូបស្អាតចូលមកឲ្យ
ជួបជុំគ្រប់គ្នាប៉ុន្មានដោយ អង្គុយលេងលយលេចឮលាន់ ។

សកវាទីព្រះមហារាមរាជរិទ្ធិ លើត្បូងជីវិតព្រះទ័យគ្នាន់
ប្រទានឲ្យយល់ឲ្យយើងទាន់ សោភ័ណសុភាពរាបរៀងទៅ ។

សកវាទីឱផ្កាក្រវាន់ព្រៃ រសៀលឧទ័យក្រអូបនៅ
ក្រអែបក្លិនក្លែបដល់យប់ជ្រៅ ឥឡូវចិន្ដាប្រាថ្នាយាង ។

៩៥៥. ម្ចាស់អើយមានបុណ្យធ្ងន់អនេក ព្រះដំណើរឡើងស្អែកភ្លឺបំព្រាង
ព្រះសូរ្យសាយសព្វច្រវាត់ភ្លាង ទ្រង់រាងរៀវតូចស្រស់ច្រឡឹង ។

ច្រឡំទេវបុត្តច្បុតយក ពីស្ថួគ៌ាមកទើបដូចថ្មឹង
ទើបត្រាស់ផ្ដានថាបើយើងនឹង រំពឹងរំពៃវៃប្រញាប់ ។

ឡើងទៅផ្លូវណារាជការនេះ នាម៉ឺនឈប់រិះទូលសាស័ព្ទ
ថាទានក្រាបទូលកុំរួសឆាប់ ស្ដេចយាងប្រថាប់គង់ពន្លា ។

ទ្រង់គង់ចាំចាត់ព្រះបន្ទូល វង្គូរវង្កេរចេរចាត់គ្នា[១]
រាជទូតឲ្យស្រូតរូតលីលា ដល់នាអរជូនខ្លួនវាស្រាប់ ។

---

១. ច្បាប់ខ្លះថា អនុកូលវង្សកេរ្តិ៍ចេរបាត់គ្នា ។

កែនកងប្រជាជនទាំងឡាយ ខ្វល់ខ្វាយធ្វើផ្តល់ផ្លូវប្រញាប់
បើរឹងទទឹងយកគ្នាចាប់ សម្លាប់កុំទុកមុខវាឯង ។

៩៦០. ស្តេចទ្រង់សណ្តាប់អស់យោធា ក្រាបទូលរាជាទើបត្រាស់ថ្លែង
ថាអាចាត់ឆាប់កុំគិតក្រែង ចាត់ចែងរួសរាន់ទាន់ឥឡូវ ។

នាម៉ឺនពួកក្រុមផ្គុំលើកហត្ថ បង្គំស្តេចថ្វាត់សរសេរទៅ
រួចបោះសង្ហារចាត់នាំទៅ សំដៅរួសឆាប់ច្បាប់រាជការ ។

ចម្រើននាំព្រះបន្ទូលដល់ ឡើងផ្ទាល់លើផ្ទះប្រាប់ទៅថា
អរជូនរៀបរួចអស់បណ្ណា ទទួលសង្ហារបន្ទូលថ្លៃ ។

ឧកញ៉ាអរជូនកូនប្រពន្ធ ពួហើយស្ទើរគ្រុនញ័រជើងដៃ
រន្ធត់ញ័រមាត់ហត់ហៀបក្ស័យ វិស័យមុខខ្មោចខ្លោចខ្មៅជាំ ។

ខំស្ទុះប្រញាប់ចូលក្នុងឋាន យកបានតុតោកមកប្រចាំ
តម្រួតថ្ដល់ត្រង់រងទាំងប្រាំ ចំណាំដោយខ្លាចព្រះចេស្តា ។

៩៦៥. លើកហត្ថប្រណម្យផ្គុំទាំងសង ក្រាបរាបជាម្តងផ្គងហត្ថា
ដាក់ដល់តម្កល់លើសិរសា សច្ចាទទួលផ្តួលក្រាបនៅ ។

ប្រុងផ្ទៀងចាំស្តាប់សព្វបន្ទូល ថ្លែងប្រាប់តាមស្រួលឲ្យធ្វើផ្លូវ
ធ្វើផ្តល់តម្កល់ឲ្យត្រឹមត្រូវ ស្តេចយាងឡើងទៅទតភូមិឋាន ។

បម្រើនានាំបន្ទូលស្តេច ឲ្យអរជូនស្រេចវិលវឹងថ្កាន
យើងឈប់បង្អង់រង់ស្លេះបាន ថ្លែងអរជូនបានដឹងសេចក្តី ។

វិតក្កខ្វាយខ្វល់វល់ក្នុងប្រាណ ប្រមាណជាស្តេចពុំប្រណី
ជាទុក្ខយំសោកបាត់ស្មារតី អញអើយសមបីក្ស័យជន្មា ។

និយាយនឹងកូនប្រពន្ធថា កូនអើយបិតាមានវេរា
សមនឹងស្លាប់ខ្លួនទាំងអស់គ្នា វេទនាដល់ប្រាណព្រមជាម្តង ។


T.CHEAT

សមជាព្រះមហាក្សត្រាថ្លៃ យកទោសដល់ក្ស័យត្បិតក្សត្រច្បង
ឲ្យព្រះបន្ទូលមកទុំផង ថាឯងមិនចងចិត្តទុកដាក់ ។
ខ្លបខ្លាចអំណាចព្រះចេស្ដា ស្ដេចធ្វើទោសាមិនតែម្នាក់
ស្នួរសាច់សន្ដានស្មានជាក់លាក់ និងព្រះចមចក្រឥតកំបាំង ។
អរជូនជាទុក្ខខ្លាចស្លាប់ខ្លួន ណាព្រួយប្រធួនទ្រង់ឲ្យតាំង
ធ្វើផ្លូវធ្វើថ្នល់ដល់កម្លាំង កែនកងចូកចាំងជំរះឆ្ការ ។
ស្រេចហើយអរជូននាំកូនដើរ កែនកងចាត់ប្រើគ្មាននរណា
ហ៊ានទាស់ទទឹងនឹងរាជការ ខ្លបខ្លាចព្រះមហាក្សត្រធិបតី ។
សឹងកាន់ពូថៅខ្វែវកាំបិត កាប់គាស់ល្មោចល្មិតឈើឫស្សី
នរណាគ្មានប្រុសកោះយកស្រី លើកដីទូលលីបាវវែកសែង ។
ខ្លបខ្លាចអំណាចបុណ្យបារមី ឮហើយភិតភ័យព្រឺស្ញប់ស្ញែង
អរជូនវិលដល់ផ្ទះសំបែង តាក់តែងរៀងខ្លួនចុះទៅថ្វាយ ។
បង្គំទៀបទាល់ដល់មហាក្សត្រ ប្រយ័ត្នរៀបរកភ័ស្ដុទាំងឡាយ
ត្នោតដូងស្លាចេកម្នាស់ខ្នុរស្វាយ ខ្វល់ខ្វាយរកសព្វសត្វក្ង ។
ក្ងោកលលកព្រាបប្រើសព្រៃ សាច់វារសរសៃគ្រឿងសម្ល
សម្លាប់យកស្នែងភ្លុកកុយថ្ម ត្រដរព្រួញប្រាណពុំមានឈប់ ។
រកបានភ័ស្ដុផលថ្កុលតុតាំង សាច់ឆ្អើរសាច់អាំងរមាំងនប់
រៀបដាក់ដោយឡែកចែកសព្វគ្រប់ ចាត់ហៅជិទប់ជំទាវធំ ។
មូលមកស្រីប្រុសអរជូនចាត់ ហាមឲ្យប្រយ័ត្នប្រយោជន៍កុំ
យកកូនចៅទៅក្រែងវាយំ ជូនស្ដេចទ្រង់ផ្ទុំពុំប្រណី ។
រៀបរួចសព្វគ្រប់មិនឈប់ឈរ ទូលលីឈូឆរទាំងប្រុសស្រី
វែកសែងជាលច្រែងថាសតុល្អី រទេះក្របីដឹកគ្រាប់បេង ។

ថ្វាយក្រុមអស់អ្នកអគ្គមហេសី ដុះលាបម្សៅបារីស្រីក្មេងៗ
បញ្ចើជជើលព្រើលខាងល្បែង គិតឈ្មោងឈ្លូនរអរចែកគ្នា ។
ចរចេញពីឋានបានដល់ទៅ ព្រះថៅស្ដេចគង់ព្រះពន្លា
នាម៉ឺនតូចធំក្រុមភ្នាក់[1]ងារ គាល់ព្រះរាមាជាចមត្រៃ ។
ចក្រិនមហិន្ទមហោធរ បវរចមចក្រឯកអគ្គំណៃ
ទ្រង់ឥទ្ធិរិទ្ធិជីវិតថ្លៃ គ្រងក្រុងជាញជ័យលើចតុរង្គ ។
ឧកញ៉ាអរជូននាំមហាជន ទាំងកូនប្រពន្ធទៅប្រៀបប្រុង
ជិតទៀបយល់អង្គព្រះនោមយង់ ស្ដេចគង់ជួបជុំក្រុមបរិវារ[1] ។
៩៨៩. នាម៉ឺនចតុស្ដម្ភក្រុមកុង្សីយ៍ មាត្យមុខមន្ត្រីគាល់ត្រៀបត្រា
អរជូននាំគ្រឿងបណ្ណាការ ស្មានថាក្សត្រាប្រោសប្រណី ។
ស្រេចលើកគ្រប់គ្រឿងរឿងដង្វាយ លើកហត្ថថ្វាត់ថ្វាយលើសិរសី
តម្កល់ដាក់ត្រឹមប្រជុំបី ស្ដេចគ្មានមេត្រីទ្រង់សាទរ ។
សម្ដេចរាមរាជអំណាចបុណ្យ រក្សាមហាជនជាជំហរ
គ្រប់ដែនដែនភូមិព្រមចូលមក៍ ញ្ញូខ្ញុំរសឹងខ្លាតខ្ទេចជាម្ដង ។
ក្រឡេកទតជាក់ហាក់ពុំស្រួល អន់អួលអស្សុជលធារាហ្មង
មួម៉ៅក្ដៅក្ដួលរំជួលចង ព្រះទ័យបំណងបំនួននៅ ។
ខ្នាញ់ខ្នួលពុំស្រួលពុំស្រប់ស្រង់ ពុំចង់ឲ្យអរជូនវិលទៅ
មិនល្ហែមិនល្ហើយមិនស្បើយក្ដៅ ត្រាស់ហៅយករាជអំណាចខ្លាំង ។
៩៩០. ចូរអស់នាម៉ឺនជំនុំទោស ឃើញកុំសន្ដោសអាចោរខ្មាំង
អាចោរខ្មោចចូលប្រមូលអាំង កាន់ក្រាំងកត់ត្រាឃាត់ខាឃុំ ។

---

១. ច្បាប់ខ្លះថា ...ក្រុមសេនា ។

ស្ដេចមានបន្ទូលប្រាប់កុង្សីយ៍ សេនាបតីឲ្យជំនុំ
នាម៉ឺនប៉ុន្មានចូលមកជុំ បង្គំទៀបទាល់គាល់ផ្ទាល់ភ័ក្ត្រ ។
ស្ដេចទ្រង់ត្រាស់ថាអស់កុង្សីយ៍ បតីជំនុំរកដោយថ្នាក់
អាណាមានទោសខ្ទោះច្រវាក់ ត្រូវដាក់គុកងឹតគិតតាមទោស ។
កុំមានប្រណីស្រីប្រុសប្រើ ដំណើរឡើងទៅត្រូវកាប់អួស
ឬស្សីឈើក្ដីចាំងចូកបោស រលីងកើបកោសឲ្យអស់ធេង ។
ជាទីទុកជីកជាអន្លង់ រណ្ដៅធំផុងទូលាយវែង
វាយវាត់បន្ទាត់បត់ខ្វាត់ខ្វែង ដំណែងដំនៀបរៀបឲ្យហើយ ។

៩៩៥. ចតុស្ដម្ភបានស្ដាប់សព្វព្រះប- ន្ទូលខ្ជាល់ចន្លន់ពុំលង់ឡើយ
សេនាបតីមន្ត្រីឆ្លើយ ស្ដេចពុំក្សាន្តស្បើយល្ហើយពីទុក្ខ ។
កុង្សីយ៍មួយមានប្រាជ្ញវាងវៃ ឈ្លាសយល់សេចក្ដីក្រមគ្រប់មុខ
ក្រុមនគរបាលបែកបែងលុក ត្រូវខ្នោះឬគុកមេស្រុកក្រម ។
បតីមួយឆ្លើយឆ្លងឡើងថា អាជ្ញាអរជូនមិនគួរសម
អានេះវាចេះគិតសម្ងំ វាហ៊ានរៀបចំគិតការកួន ។
សេនាបតីមួយទៀតឆ្លើយ ថាឱអ្នកអើយកុំអ្នកប្អូន
ថានោះត្រូវដែរព្រោះមិនសូន្យ ទំនៀមពីដូនទួតលួតលា ។
ថាមានជើងក្រោយដោយជើងមុខ ទោសនឹងត្រូវផុតពួកកនវា
អរជូនម្ដាយទាវឬក្នុយមា សន្ដានពង្សាញាតិកាស្និទ្ធ ។
១០០០. មន្ត្រីជំនុំតាមដោយថ្នាក់ កាត់ដាក់ដោយយល់ស្គាល់សុចរិត
ទៀងតាមក្រមគ្រប់ឈប៉រិះគិត ជជែកល្អោចល្អិតពិនិត្យត្រូវ ។

ក្រមក្រុមជំនុំមិនទាន់ព្រម មួយឆ្លើយថាល្មមយើងឥឡូវ
អស់លោកកុំកាត់បើមិនសូវ ព្រមគ្នាតម្រូវខុសទោសប្រាណ ។
សេនាបតីតែងប្រកែក ថាយើងថ្ងៃស្អែកភ្ញុំទើបបាន
ស្រេចចូលជុំចោទសួរសងសាន លោកកុំប្រមាណដោយយោបល់ ។
កុង្ស៊ីយ៍គិតសព្វមិនថប់សោះ ថាទោសទាំងអស់លោកកុំឆ្ងល់
ឯមនុស្សដែលមកជួយកង្វល់ គ្នាមកតាមកលតាមគេឯង ។
នឹងខានមិនបានខ្លាចបុណ្យគេ គេវាយគេជេរគេកំហែង
ទោសអស់មនុស្សនោះខ្ញុំថ្លាថ្លែង ចាត់ចែងបញ្ចូលជាអ្នកងារ ។
១០០៥.ឯទោសអរជូនកូនប្រពន្ធ នឹងអស់ទ្រព្យធនគ្រប់ពង្សពា[1]
សន្តានបងប្អូនជីដូនវា ម្តាយទាវព្រមជាគំនិតមួយ ។
ទោសត្រូវកាប់គាស់រាស់ឬភ្ជួរ បោះស្មោរក្នុងខ្ទះឲ្យរលួយ
រលាករលត់ផុតគេជួយ ភូឈ្លួយកាត់ឆាប់ប្រាប់ជាម្តង ។
កត់ត្រាបញ្ជាក់ពេលថ្ងៃខែ ប្រាប់គ្នាហូរហែឲ្យដឹងផង
ទើបហៅប្រជុំគ្នាមូលម៉ង ចូលទូលក្សត្រច្បងសងសូត្រថា ។
លើកហត្ថាចាប់ច្បាប់ជំនុំ ដាក់ជើងពានផ្គុំលើសិរសា
ថ្វាត់ថ្វាយចំពោះឈ្មោះបណ្ឌា យើងខ្ញុំករុណាកាត់សេចក្តី ។
ព្រះចមចក្រពង្សទ្រង់ទតសព្វ ត្រាស់វិញត្រឡប់រំពេចខ្មី
ថាអើត្រូវហើយមែនកុង្ស៊ីយ៍ ប្រាកដឥតបីបែរបែកបង់ ។
១០១០.ទ្រង់ត្រាស់ប្រាមប្រាប់ប្រញាប់ភ្លាម ថ្ងៃស្អែកព្រហាមកុំបង្អង់
រៀបរកទីនាំងណាស្លូតត្រង់ ដ្បិតក្មេងស្រីចង់ហែអញទៅ ។

---

១. ច្បាប់ខ្លះថា ... ពង្សា ។

ឧកញ៉ារាជកុលយល់សេចក្ដី ចក្រីចក្រិនទេវិន្ទថៅ
ចមចក្រពង្សមិនគង់នៅ ក្រើនហៅពួកក្រុមប្រជុំចូល ។
មូលគ្នាជួបជុំប្រាមប្រាប់ថ្វាត់ ថ្វាយព្រះមហាក្សត្រជាតិវង្ករ
ស្ដេចយាងឥឡូវត្រូវប្រមូល ចាត់ចងដំបូលក្ដូបកើយកល់ ។
ប្រដាប់ស្រោមភ្លុកមុខកញ្ចោង កញ្ចែញ៉ែងគងក្រពាត់ខ្នល់
ខ្នប់ខ្នើយពូកព្រំហ៊ុមបាំងខ្យល់ ប្រុងប្រៀបថ្កបថ្កល់អង្គព្រះពុទ្ធ ។
រករៀបទីនាំងតាំងប្រដាប់ សម្រាប់គ្រឿងភ្ញីទីវិសុទ្ធ
ទីនាំងដាក់ព្រះមុនបំផុត តែងតាមដោយបទពីព្រេងមក ។
១០១៩. កាលអើយកាលនោះឯអង្គព្រះ រាមរាជតេជះតបះពន្លក
ពន្លឹកស្ងប់ស្ងែងស្ដេចយាងក្រោក ពួកពលចុះស្រោកករកាន់គ្រឿង ។
មហាតលិកលៀវលយដោយលំដាប់ មុខក្រោយស្រៀបស្រាបរឹទ្ធរុងរឿង
ស្ដេចគង់ហត្ថីរស្មីគ្រឿង ភ្លឺផ្លេកព្រាតព្រឿងភ្លឺស្ងប់ស្ងែង ។
អស់ពួកនារីស្រីអ្នកក្នុង ជិះហត្ថីមង្គលទីតែង
បរក្រោយស្ដេចគង់ទ្រង់ចិញ្ចែង បញ្ចើឥតរអែងក្រែងនរណា ។
នាម៉ឺនចតុស្ដម្ភក្រុមសេនីយ៍ សឹងជិះហត្ថីហែក្សត្រា
ខ្លះជិះសេះសបរត្លៀវត្លា កាន់គ្រឿងថ្លៃថ្លាស្នាកាំភ្លើង ។
ហែហាមអមបាំងក្លស់អភិរម្យ ត្រសាយត្រសុំសប្បាយថ្កើង
ទាហានរានរុកមុខចចើង ហែឡើងតាមផ្លូវដល់ពន្លា ។
១០២០. ដល់ហើយត្រៀមត្រៀបរៀបហែស្ដេច តម្រេកយាងត្រាច់ចរលីលា
ទ្រង់ទតភូមិស្ថានរាស្ត្រប្រជា យាងយាសឡប់រាប្រថាប់គង់ ។
ពួកកងសេនាបណ្ដាស័ក្ដិ ធំតូចដោយថ្នាក់រួចរៀបរង់
រៀបរៀងខុនណាងក្មេងជំទង់ ប្រៀបប្រុងប្រាមប្រាបក្រាបទទួល ។

បើកបទប្រាកដតាមដំណើរ សរសើរឲ្យត្រូវតាមទំនួល
ឆ្លាស់ឆ្លើយស្រែកឡើងចាំទទួល សម្រួលតាមភ្លេងសម្លេងស្រី ។
សកវាទីឱណាំអនិច្ចាចិត្ត មុខគួរអាណិតដ្បិតប្រណី
ម្ចាស់យើងយាងមកភ្នកព្រះទ័យ ដោយក្ដីស្នេហាចិន្ដាគិត ។
ទៀងទតសកលដល់ត្បូងឃ្មុំ បាត់ទុំកុំសត់ប្រាកដពិត
ធ្លាប់សព្វព្រះទ័យព្រះទ្រង់រិទ្ធិ គួរស្ដាយជីវិតឥតបានយល់ ។
១០២៥. សកវាទីឱណាំផ្កាកំភ្លឹកព្រៃ ស្ងប់ស្ងួតព្រះទ័យទសពល
ទសពិធមានរិទ្ធិឥតទប់ទល់ ទ្រង់ខ្វល់ឆ្ងល់ឆ្ងាយស្ដាយអនេក ។
សកវាទីឱណាំផ្កាចំប៉ី ចំពប់ដោយក្ដីទ្រង់សង្វេគ
សង្វាតយាងដល់កម្មអ្វីបែក សង្វេគរាល់ខ្លួនបំនួននៅ ។
អនិច្ចាទ្រង់ប្រោសសន្ដោសខ្ញុំ បង្គំអម្ចាស់លាកលាទៅ
រកថ្ងូបលំហើយព្រោះស្អុះក្ដៅ រួចហៅគ្នីគ្នាលីលាលេង ។
ព្រះចមចក្រពង្សទ្រង់កំសាន្ត ត្រាស់ថ្កានព្រះអង្គបញ្ឈប់ភ្លេង
នូវក្រុមកុមារីស្រីក្មេងៗ ស្ដេចថ្លែងត្រាស់ថាឲ្យចេញទៅ ។
ទ្រង់ត្រាស់កំហែងថ្លែងឱង្ការ ត្រាស់ថាយមរាជអាចតម្រូវ
ជំនុំកាត់ទោសឲ្យត្រឹមត្រូវ ហើយហៅនគរបាល[1] ឆាប់ថ្វាត់ ។
១០៣០. នគរបាលបង្គំព្រះចក្រី ត្រាស់ឱ្យស្អុះភ្លាមទៅចែកចាត់
ធ្វើតាមទោសានុទោសសត្វ ត្រូវចាត់ផាត់មូលចូលរណ្ដៅ ។
ជីកលុងក្នុងដីជ្រៅច្រហ ប្រមាណត្រឹមករួចចាត់ហៅ
ប្រាំពីរសន្ដានច្រានកូនចៅ សាច់ឆៅភពផុងក្នុងវេទនា ។

---

១. សាស្ត្រស្លឹករឹតថា (អង្គរបាន) ក្លាយតាមសម្ដីអ្នកស្រុកពីបុរាណ ។

ទើបយកក្របីទឹមរនាស់ ដែកដឹករួចរាស់ទោសមួយឃ្លា
នគរបាលបែងមិនប្រែងវា កម្មពៀរវេរាស្នាលាហើយ ។

ចែងចាត់អ្នកទោសដែលធំៗ ប្រជុំចូលដល់ពុំលង់ឡើយ
ត្រូវស្មោរឥឡូវទោសអ្នកអើយ ឥតមានចម្លើយចំលើប្រាណ ។

ដុតភ្លើងដាំទឹកពន្លឹកពុះ ដាក់ឧសបង្គរខ្ពស់ប្រមាណ
ឆេះលេចអណ្តាតផុតជើងក្រាន បោះប្រាណផ្លែម្ទិចលិចរលួច ។

១០៣៩. រលត់ផុតខ្យល់ដល់សង្ខារ អនិច្ចំអនិច្ចានរណាជួយ
រលាយជីវិតខ្លួនមួយៗ ទុក្ខព្រួយព្រោះកម្មនាំវង្វេង ។

វិលវល់អំពលក្នុងសង្សារ រាល់រូបបណ្តាវាចាលេង
គួរយកទុក្ខំតាំងវិះឈ្វេង អនិច្ចំនោះឯងពុំទៀងនៅ ។

ព្រោះអនត្តាថាសួន្យសោះ ពុំដឹងត្រើយកោះនឹងស្លាប់ទៅ
នរណាធ្វើបាបដរាបត្រូវ ចុះជ្រៅលិចលង់ក្នុងអវិចី ។

ចូរអស់មហាជនជាតិស្រីប្រុស កើតមកជាមនុស្សក្នុងលោកិយ
បានមើលស្តាប់ដឹងក្នុងច្បាប់ថ្មី ចូរមានស្មារតីគិតឲ្យយល់ ។

ដើមដានប្រមាណតាមបញ្ញា ព្រះទ័យសត្វាចង់បានផល
បានភព្វប្រសព្វសឹងមិនឆ្ងល់ គ្មានទីទើសទាល់លស់សេចក្តី[១] ។

១០៤០. ថ្លាថ្លែងសម្តែងរឿងបទបាឋ សង្វាតកើតកបក្នុងជាតី
ជាតំតំណាំងនាលោកិយ ទោះបីសិស្សសង្ឃអង្គសាមណេរ ។

សំណាក់ក្នុងពុទ្ធសាសនា អាចារ្យចេះស្តីបាលីប្រែ
វីអ្នកច្បាស់ជាក់រឿងហួរហែ ចេះតែអធិប្បាយស្រាយស្រង់ស្រួល ។

---

(១) ចាប់ពីនេះទៅដល់ចប់ យើងបានផ្ទៀងផ្ទាត់ឲ្យដូចច្បាប់ដើមឡើងវិញ ព្រោះបោះលើកមុនមានការកាត់ចោលខ្លះ ។

ដំណើរទាវទុំផ្ទឹចងជា  និទានយូរយារអន់អាក់អួល
ទិនត្រង់មិនត្រូវតាមទំនួល  ប្រែប្រួលត្បិតពាក្យងាករិលវល់ ។
ចូរជនយកកាយនូវវាចា  វាចិត្តកុំថាប្រមាណយល់
ប្រមើលឃើញស្រាប់ច្បាស់កុំឆ្ងល់  តម្កល់ទុកតតំណទៅ ។
គិតថាលោកគ្រូបទុមត្ថេរ  ព្រះសង្ឃវរវង្សគង់នឹងនៅ
ទីឋានអារាមវត្តកំព្រៅ  ដោយខ្លៅខ្លីឃ្លៀងល្ងៀងវោហារ ។

១០៤៩. សន្មតថាចប់សព្វសេចក្ដី  ថ្លាថ្លែងអំពីកាលក្សត្រា
ស្ដេចយាងចុះចាកត្រឡាប់សា  ឧកញ៉ាគ្រប់ក្រុមផ្ទុំមិត្តមូល ។
ទើបស្ដេចយាសយាងគង់ទីនាំង  ពួកពលខ្លះខ្លាំងចែវចេញខ្ទួល
ឱ្យឃ្លាតសង្វាតស្រុះស្រើបស្រួល  ជ្រះជ្រោងដង្កួលទំនួលដល់ ។
ស្ដេចយាងឡើងគង់វង្សវរៈ  ចមចក្រពង្សស្ដេចគង់ស្កល់
ពួកក្រុមនិកាយមិនឆ្ងាយឆ្ងល់  ប្ដូរដែនសកលរចល់ជុំ ។
ក្រាបលាក្រស័ត្រកាត់រកផ្ទះ  កូនចៅរហ័សថាឱអុំ
អញ្ជើញទៅដល់ខេត្តត្បូងឃ្មុំ  ជំនុំទោសស្រេចស្ដេចវិលដល់ ។
គង់ក្នុងរាជវាំងតាំងទសពិធ  អំណាចរឹងឫទ្ធិទ្រង់ស្អាងផល
ជរាបៀតអង្គផ្ទង់តម្កល់  អកុសលកាយកម្មចាំចងជល់ ។

១០៥០. រលាយរលត់ផុតសង្ខារ  មិនទៀងឋានណាត្បិតមិនយល់
បន្ទូលមិនមានមិនបានផ្ដល់  តាមផលសំណាងសាងមកស្រាប់ ។
**ឯខ្ញុំ**តែងតាំងតាមវោហារ  យើងសន្មតថាទុកជាច្បាប់
ស្រេចនូវប្រការជាអណ្ដាប់  សាសព្ទចែងចប់ម្ល៉េះឯងហោង ។

## យើងបម្រើសេវាកម្ម :

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

## WE SERVE :

- book and teaching-aid developmen
- printing
- distribution to schools

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (គ.ប.ច)

PUBLISHING AND DISTRIBUTION HOUSE ( PDH )

# បណ្ណាគារ គ.ប.ច

# PDH BOOKSHOP

១៤៨ មហាវិថីព្រះនរោត្តម ភ្នំពេញ ទូរស័ព្ទ: ០២៣ ៦៣ ៦៣ ០៣៣ 148, Norodom Boulevard, Phnom Penh, Tel: 023 63 63 033

## មានលក់ :

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

## SELLING :

textbooks , teacher's manuals , workbooks , supplementary readers teaching-aids and stationary !